មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ

## ឯកសារសង្ខេបសំរាប់បង្ហាញសិក្ខាកាមអំពី

# គោលការណ៍ណែនាំជាតិស្ដីពីការគ្រប់គ្រងព្យាបាល ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

ឆ្នាំ ២០១០

# ម៉ូឌុលទី ១

# មូលដ្ឋានគ្រឹះស្តីពី
# ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ



# វត្ថុបំណងនៃការសិក្សា

នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :

— កំណត់បានត្រឹមត្រូវនូវបែបផែននៃការឆ្លងជំងឺកាមរោគ និងកត្តាដែលជះឥទ្ធិពលដល់ការចំលងរោគ

— ពន្យល់បានច្បាស់លាស់អំពី :

- វិសាលភាពនៃការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ ជាពិសេសអំពីប្រេវ៉ាឡង់នៅក្នុងចំណោមក្រុមគោលដៅនៅក្នុងប្រទេសកម្ពុជា
- គាពធ្ងន់ធ្ងរនៃផលវិបាកនានាដែលបណ្តាលមកពីការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជដែលមិនព្យាបាល ឬមិនបានបង្ការ
- បែបផែននៃទំនាក់ទំនងរវាងជំងឺកាមរោគ និងការឆ្លងរាលដាលនៃមេរោគអេដស៍
- ហេតុផលដែលធ្វើអោយការទប់ស្កាត់ជំងឺកាមរោគមានការលំបាក និងវិធានការណ៍នានាដែលត្រូវធ្វើ ដើម្បីធ្វើអោយកាន់តែប្រសើរឡើងនូវសមត្ថភាពនៃការទប់ស្កាត់នេះ។



# តើការបង្ករោគនៅប្រដាប់បន្តពូជ (Reproductive Tract Infections : RTIs) មានអ្វីខ្លះ?

១- ការបង្ករោគតាមការរួមភេទ **(Sexually Transmitted Infections : STIs)** ( ជំងឺកាមរោគ)

២- ការបង្ករោគដែលកើតពីក្នុងខ្លួនមនុស្ស **(Endogenous infections)**

៣- ការបង្ករោគដោយវិធីសាស្ត្រផ្នែកវេជ្ជសាស្ត្រផ្សេងៗដែលគ្រូពេទ្យបានប្រើប្រាស់ **(Iatrogenic infections)**



# ១. ការបង្ករោគតាមការរួមភេទ (ជំងឺកាមរោគ) (Sexually Transmitted Infections : STIs)

- ការចំលងបង្កឡើងដោយសារដៃគូរួមភេទមានជំងឺកាមរោគ
- វាឆ្លងរាលដាលទៅដៃគូរួមភេទដទៃៗទៀត តាមរយៈការរួមភេទ
- ការបង្ករោគដែលកើតមានជាញឹកញាប់នៅប្រទេសកម្ពុជាយើងគឺ :
  - ប្រមេះទឹកបាយ (Gonorrhoea)
  - ប្រមេះទឹកថ្លា (Chlamydia)
  - ស្វាយ (syphilis)
  - សង់ក្រឺមូ (chancroid)
  - ទ្រីកូម៉ូណាស់ (trichomoniasis)
  - ពងទឹក/ពងបែកលើប្រដាប់បន្តពូជ (genital herpes)
  - ដុះសាច់ (សិរមាន់) លើប្រដាប់បន្តពូជ (genital warts)
  - អេដស៏ (HIV)











# ២. ការបង្ករោគដែលកើតពីក្នុងខ្លួនមនុស្ស (Endogenous infections)

- ជំងឺទាំងនោះបង្កឡើងដោយសារអតិសុខុមប្រាណ (organisms) ដែលរស់នៅជាធម្មតាក្នុងទ្វារមាសរបស់ស្ត្រី
- អតិសុខុមប្រាណទាំងនោះមិនឆ្លងរាលដាលពីមនុស្សម្នាក់ទៅម្នាក់ទៀតទេ ក៏ប៉ុន្តែការរីកលូតលាស់លើសពីធម្មតានៃអតិសុខុមប្រាណទាំងនោះអាចបង្កអោយមានជារោគសញ្ញា (symptoms)
- ភាគច្រើននៃរោគសញ្ញាទាំងនោះបង្កដោយ :
  - ផ្សិត (Yeast infection)
  - បាត់តេរីដែលរស់នៅក្នុងទ្វារមាស (bacterial vaginosis : BV)



# ៣. ការបង្ករោគដោយវិធីសាស្ត្រផ្នែកវេជ្ជសាស្ត្រផ្សេងៗ ដែលគ្រូពេទ្យបានប្រើប្រាស់ (Iatrogenic infections)

- ការបង្ករោគទាំងនោះអាចកើតឡើងដោយសារមូលហេតុពីខាងក្នុងឬក្រៅខ្លួនមនុស្ស: ការបង្ករោគដែលកើតពីក្នុងខ្លួនមនុស្ស (នៅទ្វារមាស), ការបង្ករោគតាមការរួមភេទ (នៅមាត់ស្បូន ឬទ្វារមាស) ឬការឆ្លងរោគពីក្រៅខ្លួនមនុស្ស ។
- ការបង្ករោគទាំងនោះកើតឡើងដោយសារវិធីសាស្ត្រផ្នែកវេជ្ជសាស្ត្រផ្សេងៗ ឬបន្ទាប់ពីការពិនិត្យជំងឺ ឬអន្តរាគមន៍នានានៅពេលមានផ្ទៃពោះ, សំរាលកូន, រយៈពេលក្រោយការសំរាលកូន ឬក៏ការប្រើប្រាស់មធ្យោបាយពន្យាកំណើត (ឧ. ការដាក់កងក្នុងស្បូន) ឬក្នុងពេលពិនិត្យរោគស្ត្រី ។
- ការបង្ករោគនេះអាចបង្កឡើងដោយសារការរុញបញ្ចូលមេរោគឆ្លងកាត់តាមរន្ធមាត់ស្បូន ចូលទៅក្នុងប្រដាប់បន្តពូជផ្នែកខាងលើ ហើយបង្ករោគនៅក្នុងតួស្បូន, ដៃស្បូន និងសរីរៈផ្សេងៗទៀតនៅក្នុងប៉ែលវីស ។



# ៣. ការបង្ករោគដោយវិធីសាស្ត្រផ្នែកវេជ្ជសាស្ត្រផ្សេងៗ ដែលគ្រូពេទ្យបានប្រើប្រាស់ (Iatrogenic infections)

- ការចំលងរោគតាមរយៈសំភារៈផ្សេងៗទៀត ដែលរុញបញ្ចូលទៅក្នុងស្បូន ហើយមិនបានសំឡាប់មេរោគអោយបានត្រឹមត្រូវតាមវិធីសាស្ត្រនៃការបង្ការជាសកល (Infection control) ។
- ការបង្ករោគដេលកើតមានជាញឹកញាប់គឺ :
  - ជំងឺរលាកប៉ែលវីស បន្ទាប់ពីការរំលូតកូន
    ឬការប្រើប្រាស់វិធីសាស្ត្រវេជ្ជសាស្ត្រផ្សេងៗឆ្លងកាត់តាមមាត់ស្បូន ។
  - ការបង្ករោគមួយចំនួនដែលជាផលវិបាកក្នុងពេលមានផ្ទៃពោះ និងក្រោយពេលសំរាលកូន ។



# Female anatomy



# Male anatomy






# តើជម្ងឺកាមរោគអាចឆ្លងតាមបែបណាខ្លះ?

- ភាគច្រើននៃជំងឺកាមរោគ ឆ្លងតាមរយៈការរួមភេទដោយស៊កបញ្ចូល ហើយមិនបានប្រើមធ្យោបាយបង្ការ (ឧ. ស្រោមអនាម័យ)



- រួមភេទតាមទ្វារមាស
- រួមភេទតាមទ្វារលាមក
- រួមភេទតាមមាត់







***<u>កំណត់ចំណាំ</u> : ចូរចងចាំថា បែបផែននៃការឆ្លងមេរោគអេដស៍គឺ ដូចគ្នានឹងការឆ្លងមេរោគកាមរោគផ្សេងៗទៀតដែរ ។***



ការរួមភេទដោយស៊កបញ្ចូលលិង្គទៅក្នុងទ្វារមាស



ការរួមភេទដោយស៊កបញ្ចូលលិង្គទៅក្នុងទ្វារលាមក



ការរួមភេទដោយការប៉ះពាល់ប្រដាប់ភេទនិងមាត់



# តើជម្ងឺកាមរោគអាចឆ្លងតាមបែបណាខ្លះ?

ឆ្លងពីម្តាយទៅកូន (Mother-to-child transmission : MTCT) :

- នៅពេលកំពុងមានគភ៌ (e.g. HIV and syphilis, …)
- នៅពេលកំពុងសំរាល (e.g. gonorrhoea, chlamydia, HIV, …)
- នៅពេលបំបៅដោះកូន (e.g. HIV, …)







# តើជម្ងឺកាមរោគអាចឆ្លងតាមបែបណាខ្លះ?

ឆ្លងតាមឈាម ឬផលិតផលឈាមដែលគ្មានសុវត្ថិភាព :

- ការប្រើប្រាស់សឺរ៉ាំង ឬ ម្ជុលរួមគ្នា
- ការបញ្ចូលឈាម ឬ ផលិតផលរបស់ឈាម
- ការប៉ះពាល់ ឬ ប្រឡាក់ឈាមលើរាងកាយដែលមានរបួសដាច់រលាត់
- ការប្រើប្រាស់វត្ថុមុតស្រួចចាក់ទំលុះស្បែក







# បែបផែននៃការឆ្លងតាមឈាម ឬ ផលិតផលរបស់ឈាម





# តើកត្តាអ្វីខ្លះដែលបង្កើនការប្រឈមមុខនឹងការឆ្លងកាមរោគ?

កត្តាជីវសាស្ត្រ (Biological factors):

- អាយុ
- យេនឌ័រ (gender)
- ភាពស៊ាំនៃបុគ្គលម្នាក់ៗ (immune status)

កត្តាទាក់ទងនឹងឥរិយាបថប្រព្រឹត្ត (Behavioural factors):

- ការរួមភេទរបស់បុគ្គលម្នាក់ៗ (Personal sexual behaviour)
- កត្តាសង្គម (Social factors)
- ឥរិយាបថផ្សេងៗទៀតរបស់បុគ្គលម្នាក់ៗ ដែលប្រឈមមុខនឹងការឆ្លង
- ឥរិយាបថនៃដៃគូ (Behaviour of the partners)



# តើក្រុមមនុស្សណាខ្លះដែលងាយនឹងឆ្លងជំងឺកាមរោគ?

- ក្រុមមនុស្សវ័យជំទង់ (ប្រុស-ស្រី) ដែលចូលចិត្តការរួមភេទ
- ស្ត្រីបំរើសេវាផ្លូវភេទនិងអតិថិជន រួមទាំងក្រុមបុរសស្រឡាញ់បុរសផងដែរ (Men who have sex with men : MSM)
- បុរស ឬស្ត្រីដែលមានដៃគូរួមភេទច្រើន
- បុរស ឬស្ត្រីដែលប្រកបការងារឃ្លាតឆ្ងាយរយៈពេលយូរពីដៃគូរួមភេទជាប់លាប់របស់ខ្លួន ដូចជាអ្នកបើកបររថយន្តទៅឆ្ងាយៗ, ទាហ៊ាន, កម្មករចល័ត,...

# អត្រាប្រេវ៉ាឡង់ជំងឺកាមរោគចំពោះមនុស្សពេញវ័យ

# នៅឆ្នាំ ១៩៩៩






# ការប្រៀបធៀបប្រេវ៉ាឡង់ជំងឺកាមរោគ តាមការអង្កេត

# ស្រាវជ្រាវប្រចាំឆ្នាំ ចំពោះស្ត្រីបំរើសេវាផ្លូវភេទ






# ការប្រៀបធៀបប្រេវ៉ាឡង់ជំងឺកាមរោគ តាមការអង្កេត

# ស្រាវជ្រាវប្រចាំឆ្នាំ ចំពោះប៉ូលីស




For purposes of comparison, provinces include: Battambang, Kampong Cham, Sihanouk Ville, Banteay Meanchey and Phnom Penh.



# ប្រេវ៉ាឡង់ជំងឺកាមរោគ ចំពោះបុរសរួមភេទជាមួយបុរស

# តាមការអង្កេតស្រាវជ្រាវនៅតាមកន្លែងនីមួយៗ



# ផលវិបាកនៃជំងឺកាមរោគ (១)

- គ្រប់ជំងឺកាមរោគ ទាំងមានរោគសញ្ញា និងទាំងគ្មានរោគសញ្ញា អាចវិវត្ត ទៅរកផលវិបាកធ្ងន់ធ្ងរ
- ផលវិបាកដែលធ្ងន់ធ្ងរបំផុតនិងពិការភាព (ផលវិបាកយូរអង្វែង) នៃជំងឺកាមរោគដែលមិនព្យាបាល ច្រើនកើតមានចំពោះស្ត្រី និងទារកដែលទើបនឹងកើត ។ ផលវិបាកទាំងនោះមាន មហារីកមាត់ស្បូន, ជំងឺរលាកប៉ែលវីស (រលាកដៃស្បូន), ឈឺចុកចាប់រ៉ាំរ៉ៃនៅផ្នែកខាងក្រោមនៃពោះ, ទារកស្លាប់ក្នុងផ្ទៃ, គភ៌ក្រៅស្បូននិងជំងឺផ្សេងៗដែលទាក់ទងនឹងការស្លាប់របស់ម្តាយ ។



# ជំងឺរលាកប៉ែលវីស

## Pelvic Inflammatory Disease (PID)






## ប្រដាប់បន្តពូជស្ត្រី ក្នុងសភាពធម្មតា



Female genital tract



## ឧទាហរណ៍មួយនៃផលវិបាកជំងឺកាមរោគចំពោះស្ត្រី



Stricture ⟶ Ectopic pregnancy



Obstacle ⟶ Infertility



## ផលវិបាកនៃជំងឺកាមរោគចំពោះបុរស



# ផលវិបាកនៃជំងឺកាមរោគ (២)

- ជំងឺដែលបង្កដោយមេរោគ *Gonococcus* និង *Chlamydia* គឺជាមូលហេតុចំបងនៃអសមត្ថភាព បន្តពូជ (អារ) ជាពិសេស ចំពោះស្រ្តី ដែលនាំ អោយមានផលវិបាកយូរអង្វែងដល់សង្គម ។ ការបង្ករោគដោយ*Chlamydia* គឺជាមូលហេតុ ចំបងនៃជំងឺ *Pneumonia* ចំពោះទារកដែល ទើបនឹងកើត ។ ចំពោះការបង្ករោគ ដោយ *Gonococcus* ចំពោះទារកដែលទើបនឹងកើត អាចបណ្តាលអោយទារកនោះខ្វាក់ភ្នែក ។





# ផលវិបាកនៃជំងឺកាមរោគ (៣)

- ជំងឺស្វាយពីកំណើតគឺជាមូលហេតុដ៏ធ្ងន់ធ្ងរដែលនាំអោយទារកឈឺនិងស្លាប់ ។ ចំពោះមនុស្សពេញវ័យ ជំងឺស្វាយនេះបង្កជាផលវិបាកចំពោះបេះដូង, សរសៃប្រសាទ និងផលវិបាកផ្សេងៗទៀត ដែលអាចអោយអ្នកជំងឺស្លាប់បាន ។









# ផលវិបាកនៃជំងឺកាមរោគ

| ***Causes*** | ***Complications*** |
|---|---|
| Gonococcal and Chlamydial infection | Infertility in men and women, Epididymitis, Ectopic pregnancy due to tubal damage |
| Gonorrhoea | Blindness in infants |
| Gonococcal, chlamydial and anaerobic bacterial infections | Pelvic and generalized peritonitis |
| Acquired syphilis | Permanent brain and heart disease |
| Congenital syphilis | Extensive organ and tissue destruction in children |
| Human papilloma virus | Genital cancer |



# ទំនាក់ទំនងរវាងមេរោគអេដស៍និងជំងឺកាមរោគ



## ការប៉ាន់ប្រមាណចំនួនអ្នកផ្ទុកមេរោគអេដស៍
## នៅលើពិភពលោកនៅឆ្នាំ ២០០៥




**Total: 40.3 (36.7 – 45.3) million**



## ប្រេវ៉ាឡង់នៃមេរោគអេដស៍ តាមឆ្នាំនីមួយៗ
## ក្នុងចំណោមស្ត្រីបំរើសេវាផ្លូវភេទតាមផ្ទះបន




*Adjusted for results of quality assurance testing



## ប្រេវ៉ាឡង់នៃមេរោគអេដស៍ តាមឆ្នាំនីមួយៗ
## ចំពោះមនុស្សពេញវ័យនៅកម្ពុជា អាយុពី ១៥ ទៅ ៤៩ឆ្នាំ




* From the modeled numbers of PLHA



## ចំនួនប៉ាន់ប្រមាណអ្នកផ្ទុកមេរោគអេដស៍ តាមឆ្នាំនីមួយៗ
## ចំពោះមនុស្សពេញវ័យនៅកម្ពុជា អាយុពី ១៥ ទៅ ៤៩ឆ្នាំ



# EM projected HIV prevalence among adults aged 15+ (with and without ART)




*Report of a Consensus Workshop HIV Estimates and Projections for Cambodia 2006 - 2012*



# តើត្រូវធ្វើអ្វីខ្លះដើម្បីទប់ស្កាត់ជំងឺកាមរោគ?

- <u>ការបង្កាជាបថម</u> (Primary prevention) មានគោលបំណងបង្ការទុកជាមុនមិនអោយប្រជាជនឆ្លងជំងឺកាមរោគ និងមេរោគអេដស៍ ។
- <u>ការបង្ការក្រោយពីមានការបង្ករោគ</u> (Secondary prevention) គឺជាការផ្តល់នូវការថែទាំព្យាបាលចំពោះអ្នកជំងឺកាមរោគ ក្នុងគោលបំណងជៀសវាងមិនអោយជំងឺនោះឆ្លងទៅអ្នកដទៃផ្សេងទៀត ។



# តើត្រូវបង្ការការបង្ករោគតាមការរួមភេទ (ជំងឺកាមរោគ) យ៉ាងដូចម្តេច?

- **A** ការតមការរួមភេទ (Abstinence) : ពន្យាពេលចាប់ផ្តើមមានសកម្មភាពរួមភេទ (ជាពិសេសចំពោះយុវវ័យ)
- **B** ការស្មោះស្ម័គ្រនឹងដៃគូរួមភេទមួយទល់នឹងមួយ (Be faithful) : កាត់បន្ថយចំនួនដៃគូរួមភេទ
- **C** **ការប្រើប្រាស់ស្រោមអនាម័យ (Condom use)** : អោយបានត្រឹមត្រូវនិងជាប់លាប់
- **D** កុំប្រើប្រាស់សឺរ៉ាំង ឬ ម្ជុលរួមគ្នា (Do not inject)
- **E** មិត្តជួយអប់រំមិត្ត (Educate each other)



# តើត្រូវបង្ការ Iatrogenic infections យ៉ាងដូចម្តេច?

<u>បង្ការការបង្ករោគនៅប្រដាប់បន្តពូជផ្នែកខាងលើ</u> (upper genital tract infection) :

— បង្ការនិងគ្រប់គ្រងព្យាបាលការបង្ករោគតាមការរួមភេទ

—ផ្តល់សេវាថែទាំផ្ទៃពោះដែលមានគុណភាព និងការសំរាលដែលមានសុវត្ថិភាព

—អនុវត្តវិធីសាស្រ្តបែបវេជ្ជសាស្រ្តឆ្លងកាត់មាត់ស្បូនប្រកបដោយសុវត្ថិភាព

—ថែទាំតាមដានក្រោយពីការរំលូតកូន និងព្យាបាលផលវិបាកអោយបានត្រឹមត្រូវ ។

# តើត្រូវបង្ការ Endogenous infections យ៉ាងដូចម្តេច?

ការបង្ករោគផ្សិត និងបាក់តេរីនៅទ្វារមាស (Yeast infection and bacterial vaginosis) គឺជាការបង្ករោគដែលកើតមានជាញឹកញាប់ពីក្នុងខ្លួនមនុស្ស ក៏ប៉ុន្តែការបង្ករោគនេះអាចព្យាបាលដោយងាយស្រួល បើទោះបីជាវាកើតមានឡើងវិញជាញឹកញាប់ក៏ដោយ ។ អ្នកផ្តល់សេវាថែទាំព្យាបាលត្រូវដឹងថា :

- ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលប្រើឱសថពន្យាកំណើតអាចនឹងបង្កអោយមានរោគផ្សិតដោយសារការផ្លាស់ប្តូរ pH acide នៅក្នុងទ្វារមាស
- ស្ថានភាពសុខភាពមួយចំនួន ដូចជា ជំងឺទឹកនោមផ្អែម អាចបង្កើនការប្រឈមមុខនឹងការបង្ករោគផ្សិតដោយសារការប្រើប្រាស់ឱសថ Steroids រយៈពេលយូរ ។



# តើត្រូវបង្ការ Endogenous infections យ៉ាងដូចម្តេច?

អ្នកផ្តល់សេវាថែទាំព្យាបាលត្រូវផ្តល់ប្រឹក្សាដល់អ្នកជំងឺអំពីវិធីងាយៗ សំរាប់បង្ការ Endogenous infections ដូចជា :

- ការលូកលាងសំអាតក្នុងទ្វារមាសអាចបង្កអោយមានការប៉ះពាល់ដល់ការដុះលូតលាស់ធម្មតានៃ flora នៅក្នុង ទ្វារមាស ហើយធ្វើអោយ Microorganisms ដទៃទៀតដូចជា bacterial vaginosis រីកលូតលាស់ច្រើនហួស ។ ដូច្នេះត្រូវជៀសវាងការប្រើប្រាស់សាប៊ូ, ទឹកសំឡាប់មេរោគ និងសារធាតុលាងសំអាតទ្វារមាសឬសារធាតុធ្វើអោយទ្វារមាសស្ងួត ។ ការលាងសំអាតផ្នែកខាងក្រៅនៃទ្វារមាសដោយសាប៊ូនិងទឹកគឺជាការគ្រប់គ្រាន់សំរាប់អនាម័យប្រដាប់ភេទ ។



# តើត្រូវបង្ការ Endogenous infections យ៉ាងដូចម្តេច?

- ការប្រើប្រាស់ឱសថ Antibiotics ក៏អាចបង្កអោយមានការប៉ះពាល់ដល់ការដុះលូតលាស់ធម្មតានៃ flora នៅក្នុងទ្វារមាសដែរ ហើយធ្វើអោយផ្សិត (Yeast) ដុះលូតលាស់ច្រើនហួស ។ ដូច្នេះស្ត្រីដែលប្រើ ឱសថ Antibiotics ដែលអាចសំឡាប់មេរោគបានច្រើនមុខ (broad spectrum) ជាពិសេសការប្រើប្រាស់ឱសថនេះរយៈពេលយូរ ចាំបាច់ត្រូវពិនិត្យតាមដាននិងថែទាំព្យាបាលការបង្ករោគផ្សិតផងដែរ ។



# ហេតុអ្វីបានជាមានមានការលំបាកក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកាមរោគ?

- ៧0%នៃស្ត្រី និង ៣0%នៃបុរសដែលឆ្លងមេរោគ Chlamydia ពុំមានលេចចេញជារោគសញ្ញាទេ ។
- លើសពី ៨0%នៃស្ត្រី និង ១0%នៃបុរសដែលឆ្លងមេរោគ Gonococcus ពុំមានលេចចេញជារោគសញ្ញាទេ ។

ដូច្នេះមានន័យថា មានតែស្ត្រី តិចជាង ២0% ប៉ុណ្ណោះ ដែលឆ្លងជំងឺកាមរោគ ហើយស្វែងរកការថែទាំព្យាបាល ចំណែកឯស្ត្រីដែលឆ្លងជំងឺកាមរោគហើយ តែគ្មានរោគសញ្ញា ពុំមាននៅក្នុងរបាយការណ៏ទេ ។

## ភាគច្រើននៃជម្ងឺកាមរោគគឺ គ្មានរោគសញ្ញា



ឆ្លងរោគនិងមានរោគសញ្ញា

Symptomatic





ឆ្លងរោគតែគ្មានរោគសញ្ញា

Asymptomatic



## ការមិនដឹងអំពីស្ថានភាពឆ្លងជំងឺកាមរោគ អាចបង្កអោយមានការឆ្លងរាលដាលជំងឺនេះកាន់តែខ្លាំង

**មនុស្សដែលបានឆ្លងការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ (STI/RTI)**

| | |
|---|---|
| មានរោគសញ្ញា (Symptomatic) | *គ្មានរោគសញ្ញា (Asymptomatic)* |
| ស្វែងរកការថែទាំព្យាបាល | *មិនស្វែងរកការថែទាំព្យាបាល* |
| ធ្វើរោគវិនិច្ឆ័យត្រឹមត្រូវ | |
| ព្យាបាលត្រឹមត្រូវ | |
| ព្យាបាលចប់សព្វគ្រប់ | |
| ជាសះស្បើយ | |
| ព្យាបាលដៃគូ | ***បន្តការចំលងរោគទៅអ្នកដទៃទៀត*** |



## ហេតុអ្វីបានជាមានមានការលំបាកក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺកាមរោគ?

- អ្នកឆ្លងជំងឺកាមរោគតែគ្មានរោគសញ្ញា មិនបានទៅស្វែងរកសេវាថែទាំព្យាបាលទេ
- សេវាសុខាភិបាលដែលផ្តល់ការថែទាំព្យាបាលជំងឺកាមរោគ អាចស្ថិតនៅឆ្ងាយពេកពីប្រជាជនជាច្រើន
- អតិថិជនដែលទទួលសេវាដទៃទៀត ដូចជាសេវាពិនិត្យផ្ទៃពោះ អាចមិនបានធ្វើតេស្តស្រាវជ្រាវរកការឆ្លងជំងឺកាមរោគ
- អតិថិជនមួយចំនួនអាចមានអារម្មណ៏ថា មានការមាក់ងាយពីអតិថិជនដទៃទៀត នៅពេលរង់ចាំទទួលសេវានៅគ្លីនិកកាមរោគ ដែលពួកគាត់គិតថា ខ្លួនគាត់អាចមានការប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ
- អ្នកជំងឺខ្លះអាចជ្រើសរើសអ្នកផ្តល់សេវាទាំងពីរប្រភេទឆ្លាស់គ្នា ម្តងទៅសេវារដ្ឋឬអង្គការមិនមែនរដ្ឋាភិបាល ម្តងទៅសេវាឯកជន ដែលជាទូទៅសេវាឯកជនពុំមានរបាយការណ៏ទេ។ តំលៃសេវាក៏ជាកត្តាសំខាន់ដែរ ចំពោះការសំរេចចិត្តរបស់អ្នកជំងឺ។



## គោលការណ៍ ៦ យ៉ាង នៃការថែទាំព្យាបាលគ្រប់ជ្រុងជ្រោយ (Comprehensive care)

- ✓ ធ្វើរោគវិនិច្ឆ័យអោយបានត្រឹមត្រូវ
- ✓ ផ្តល់ការព្យាបាលដោយឱសថអង់ទីប៊ីយ៉ូទិកត្រឹមត្រូវទៅតាមគោលការណ៏ណែនាំជាតិ
- ✓ អប់រំអ្នកជំងឺអំពីបែបផែននៃការចំលងជំងឺកាមរោគ, ការបង្ការ, ការរួមភេទដែលមានសុវត្ថិភាព, ការកាត់បន្ថយការប្រឈមមុខនឹងការឆ្លងជំងឺនេះ ក្នុងគោលបំណងកុំអោយមានការឆ្លងរោគសារជាថ្មីនៅលើកក្រោយៗទៀត
- ✓ អប់រំអំពីការប្រើប្រាស់ឱសថព្យាបាលអោយបានត្រឹមត្រូវ ទៀងទាត់ និងជាប់លាប់តាមវេជ្ជបញ្ជា
- ✓ បង្ហាញអំពីការប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវ និងផ្តល់ស្រោមជូនអតិថិជន
- ✓ ផ្តល់ប្រឹក្សាជូនអ្នកជំងឺអំពីហេតុផល ដែលដៃគូរបស់គាត់ត្រូវមកទទួលការថែទាំព្យាបាល និងជូនប័ណ្ណអញ្ជើញដៃគូដល់គាត់។

# វិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យ ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

- **ការធ្វើរោគវិនិច្ឆ័យបែបគ្លីនិក :** ដោយប្រើប្រាស់បទពិសោធន៍គ្លីនិក ដើម្បីកំណត់រោគសញ្ញាដែលលេចចេញមកច្បាស់លាស់ក្នុងការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគណាមួយ ។
- **ការធ្វើរោគវិនិច្ឆ័យបែបចង្កោមរោគសញ្ញា :** ដោយសំដៅទៅលើបញ្ហាដែលឆ្លើយតបនឹង រោគសញ្ញាដែលអ្នកជំងឺបានរៀបរាប់ប្រាប់ (ចង្កោមរោគសញ្ញា គឺជាការប្រមូលផ្តុំរោគសញ្ញា ដែលអ្នកជំងឺបានរៀបរាប់ប្រាប់ និងរោគសញ្ញាដែលគ្រូពេទ្យរកឃើញពេលពិនិត្យអ្នកជំងឺនោះ)
- **ការធ្វើរោគវិនិច្ឆ័យបែបមូលហេតុនៃការបង្ករោគ :** ដោយពឹងផ្អែកលើតេស្តមន្ទីរពិសោធន៍ ដើម្បីកំណត់អំពីមេរោគដែលជាមូលហេតុបង្ករោគ ។



# ការធ្វើរោគវិនិច្ឆ័យបែបគ្លីនិក (Clinical diagnosis)

- គ្រូពេទ្យព្យាបាលជំងឺបង្កតាមការរួមភេទនិងប្រដាប់បន្តពូជ ជូនអ្នកជំងឺដោយពឹងផ្អែកលើរោគសញ្ញាគ្លីនិក និងបទពិសោធន៍នៃវិជ្ជាជីវៈរបស់ខ្លួន ។
- ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជមួយចំនួនអាចមានរោគសញ្ញាដូចគ្នា បើទោះបី ជាវាបង្កដោយមេរោគខុសៗគ្នាក៏ដោយ ដូច្នេះគ្រូពេទ្យអាចព្យាបាលជំងឺខុសជូនអ្នកជំងឺ ។
- ជំងឺដែលបង្កដោយមេរោគច្រើនក្នុងពេលដំណាលគ្នាតែមួយ ច្រើនកើតមានជាញឹកញាប់ ក៏ប៉ុន្តែគ្រូពេទ្យច្រើនតែធ្វើរោគវិនិច្ឆ័យជំងឺតែមួយមុខទៅវិញ ។
- អ្នកដែលមានជំងឺច្រើនប្រភេទក្នុងពេលតែមួយ ត្រូវតែទទួលបាននូវការព្យាបាលជំងឺនិមួយៗ ។ ការខកខានមិនបានព្យាបាលជំងឺណាមួយ អាចអោយជំងឺនោះវិវត្តទៅរកផលវិបាកផ្សេងៗ ហើយអ្នកជំងឺនោះបន្តការចំលងរោគទៅដល់អ្នកដទៃទៀត ។
- គ្រូពេទ្យងាយនឹងធ្វើរោគវិនិច្ឆ័យមិនត្រឹមត្រូវចំពោះការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ហើយក៏ងាយនឹងខកខានមិនបានព្យាបាលការបង្ករោគច្រើនមុខ ដែលកើតក្នុងពេលដំណាលគ្នាតែមួយដែរ ។



# ការធ្វើរោគវិនិច្ឆ័យបែបចង្កោមរោគសញ្ញា (Syndromic case management)

- គឺជាការធ្វើរោគវិនិច្ឆ័យដោយផ្តោតទៅលើបញ្ហាដែលកើតមាន (problem-oriented) ដោយការឆ្លើយតបទៅនឹងរោគសញ្ញាដែលអ្នកជំងឺមាន ។ ការធ្វើរោគវិនិច្ឆ័យបែបនេះអាចត្រូវនឹងជំងឺច្រើនមុខ ហើយការបង្ករោគដែលកើតមានច្រើនមុខក្នុងពេលដំណាលគ្នា មិនអាចគេចផុតពីការព្យាបាលបែបចង្កោមរោគសញ្ញានេះបានឡើយ នៅពេលដែលអ្នកជំងឺមកពិនិត្យជាលើកដំបូង ។
- ការធ្វើរោគវិនិច្ឆ័យបែបនេះ ធ្វើអោយការថែទាំព្យាបាលជំងឺកាមរោគ អាចអនុវត្តបាននៅសេវាថែទាំសុខភាពបឋម ដូចជាមណ្ឌលសុខភាពជាដើម ។
- ការប្រើប្រាស់គំនូសបំព្រួញ អាចណែនាំដល់អ្នកផ្តល់សេវាថែទាំព្យាបាល អោយអនុវត្តនូវជំហានជាបន្តបន្ទាប់ ព្រមទាំងការផ្តល់ឱកាសសំរាប់ការអប់រំ និងផ្តល់ប្រឹក្សាជូនអ្នកជំងឺផងដែរ ។



# ការធ្វើរោគវិនិច្ឆ័យបែបមូលហេតុនៃការបង្ករោគ (Etiological approach: lab-based)

- ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើតេស្តមន្ទីរពិសោធន៍ (laboratory testing) ត្រូវការបុគ្គលិកដែលមាន ជំនាញ និងការគាំទ្រ-ផ្គត់ផ្គង់គ្រប់គ្រាន់និងទៀងទាត់ ។
- ការធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើមន្ទីរពិសោធន៍អាចបញ្ជាក់រោគវិនិច្ឆ័យបន្ថែមអោយបានច្បាស់លាស់ ប្រសិនបើអ្នកជំងឺដែលមានជំងឺកាមរោគត្រូវបានបញ្ជូនមកពីមណ្ឌលសុខភាព ។
- ការធ្វើរោគវិនិច្ឆ័យបែបនេះមានសារៈសំខាន់ណាស់ចំពោះជំងឺកាមរោគដែលគ្មានរោគសញ្ញា ជាពិសេសការធ្វើតេស្តស្រាវជ្រាវរកករណីជំងឺស្វាយចំពោះស្ត្រីមានផ្ទៃពោះ ។
- ទោះបីយ៉ាងណាក៏ដោយ វិធីសាស្ត្រនេះមិនអាចអនុវត្តបាន ហើយលទ្ធផលក៏មិនអាចយកជាការបានដែរចំពោះការធ្វើរោគវិនិច្ឆ័យចំពោះជំងឺកាមរោគខ្លះ បើទោះបីជាមានធនធានគ្រប់គ្រាន់ក៏ដោយ ។ ឧ. Haemophilus ducreyi ដែលបង្កជំងឺ Chancroid គឺជាបាក់តេរី ដែលមិនអាចបណ្តុះដោយងាយស្រួលបានឡើយ ។

# ម៉ូឌុលទី ២

## ការពិនិត្យជំងឺនិងការធ្វើតេស្តមន្ទីរពិសោធន៍រក ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- ពន្យល់បានពីគោលបំណងនៃការស្រង់ប្រវត្តិជំងឺ
- ពិពណ៌នាបានពីភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទង
- កំណត់បានច្បាស់នូវការស្រង់ពត៌មានពីអ្នកជំងឺ
- ពិពណ៌នាបានពីអកប្បកិរិយាវិជ្ជាជីវៈក្នុងពេលពិនិត្យជំងឺ
- កំណត់បានពីរបៀបនៃការពិនិត្យជំងឺ បុរស-ស្ត្រី
- កំណត់បានពីរបៀបស្រង់សារធាតុសរីរៈពីជំងឺបុរស-ស្ត្រី
- ពិពណ៌នាអំពីរោគសញ្ញានៃជំងឺបង្កតាមការរួមភេទ និងប្រដាប់បន្តពូជដែលមានញឹកញាប់
- អនុវត្តប្រើប្រាស់បញ្ជីសំរង់ប្រវត្តិជំងឺ និងបណ្ណ័វិភាគតេស្តមន្ទីពិសោធន៍សំរាប់ជំងឺបង្កតាម ការរួមភេទ និងប្រដាប់បន្តពូជ



# សំណួរពិភាក្សា

- **តើការសាកសួរពីប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺ មានគោលបំណងយ៉ាងដូចម្តេច?**



# គោលបំណងនៃការស្រង់ប្រវត្តិជំងឺ និងការពិនិត្យអ្នកជំងឺ

ដើម្បីៈ

- ធ្វើរោគវិនិច្ឆ័យដោយពឹងផ្អែកលើចង្កោម រោគសញ្ញាជំងឺកាមរោគឱ្យបានត្រឹមត្រូវ និង មានប្រសិទ្ធិភាព
- កំណត់អំពីការប្រឈមមុខនឹងគ្រោះថ្នាក់នៃការ ចំលង ឬ ឆ្លងកាមរោគរបស់អ្នកជំងឺ
- រកឃើញដៃគូរួមភេទ ដែលអាចឆ្លងជំងឺកាមរោគ





# ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទង

- ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទងដើម្បីបង្កើតនូវភាពស្និតស្នាលជាមួយអ្នកជំងឺ គឺជាភាពស្ទាត់ជំនាញដំបូងបង្អស់ដែលអ្នកគួរប្រើប្រាស់នៅពេលដែលអ្នកជំងឺមកជួបអ្នក រួមទាំង:

  - ភាពស្ទាត់ជំនាញក្នុងការនិយាយស្តី និងសាកសួរទៅកាន់អ្នកជំងឺ និង

  - ភាពស្ទាត់ជំនាញក្នុងការមិនប្រើពាក្យសំដី និងអ្វីដែលអ្នកត្រូវធ្វើជាមួយអ្នកជំងឺ ។



# ភាពស្ទាត់ជំនាញក្នុងការនិយាយស្តី

- ទទួលអ្នកជំងឺដោយរួសរាយរាក់ទាក់
- ជៀសវាងបញ្ហានានាក្នុងការប្រាស្រ័យទាក់ទងដោយប្រើពាក្យសំដី
- សូមសួរសំណួរ " បើក " និង " បិទ " ឱ្យមានប្រសិទ្ធិភាពល្អ
- ត្រៀមខ្លួនឆ្លើយតបចំពោះការរំភើបចិត្តរបស់អ្នកជំងឺ ។





# វិធីទទួលរាក់ទាក់អ្នកជំងឺ

- ប្រើប្រាស់សំលេងដែលមានន័យស្វាគមន៍ ញញឹមរាក់ទាក់
- ណែនាំខ្លួនអ្នកឱ្យអ្នកជំងឺស្គាល់
- អញ្ជើញអ្នកជំងឺឱ្យអង្គុយ
- មើលទៅភ្នែកអ្នកជំងឺ ប្រសិនបើគិតថាសមរម្យ
- លើកទឹកចិត្តអ្នកជំងឺឱ្យនិយាយដោយការសាកសួរសំណួរនានា ។
- ងក់ក្បាលពេលអ្នកជំងឺប្រាប់ ឬ "សូមប្រាប់ខ្ញុំបន្ថែមទៀត"
- សំដែងនូវការគោរពរាប់អាន និង យោគយល់ ។





# វិធីចៀសវាងបញ្ហាដែលមានញឹកញាប់នៅក្នុងការប្រាស្រ័យទាក់ទងដោយប្រើការនិយាយស្តី

- ជានិច្ចកាលត្រូវតែចេះគួរសម
- ប្រើពាក្យពេចន៍ដែលអ្នកជំងឺអាចយល់បានងាយស្រួល
- សួរសំណួររបស់អ្នកឱ្យបានច្បាស់លាស់
- សួរសំណួរមួយម្តងៗ
- ជៀសវាងប្រើសំណួរ " ដឹកនាំ " (leading)
- ជៀសវាងការវិនិច្ឆ័យមិនសមហេតុផល
- សុំការអនុញ្ញាតិពីអ្នកជំងឺ ដើម្បីពិភាក្សាអំពីបញ្ហាដែលប៉ះពាល់ដល់ទឹកចិត្តអ្នកជំងឺ (sensitive topics)

## សំណួរបើក និង សំណួរបិទ (១)

- **សំណួរបើក** : អ្នកជំងឺអាចផ្តល់ នូវចំលើយច្រើនដោយរួមបញ្ចូលទាំងពតិមានដែលគាត់ចង់បន្ថែមទៀតផង

<u>ឧទាហរណ៏:</u>

- " តើអ្នកមានបញ្ហាអ្វីដែលមិនស្រួល ?"
- " តើនៅពេលនេះអ្នកកំពុងប្រើថ្នាំអ្វីខ្លះ ?"



## សំណួរបើក និង សំណួរបិទ (២)

- **សំណួរបិទ** : អ្នកជំងឺត្រូវបានឆ្លើយតបដោយប្រើពាក្យមួយម៉ាត់ ឬ ឃ្លាមួយយ៉ាងខ្លី ជារឿយៗ "បាទ/ចាស " ឬ "ទេ" ។

<u>ឧទាហរណ៏:</u>

- " តើការហើមនេះឈឺដែរឬទេ? "
- " តើអ្នកក្រមករដូវមែនដែរឬទេ ? "
- " តើអ្នកអាយុប៉ុន្មាន ? "



## ភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទង ដែលមិនប្រើពាក្យពេចន៍

- សូមរកទីកន្លែងស្ងាត់កំបាំងសំរាប់អ្នកជំងឺ
- សូមស្តាប់ដោយយកចិត្តទុកដាក់ នូវអ្វីដែលអ្នកជំងឺនិយាយ
- សូមអង្គុយប្រសិនបើអ្នកជំងឺអង្គុយ ហើយសូមចាប់អារម្មណ៏លើចំងាយ ដែលអ្នកស្ថិតនៅជិតអ្នកជំងឺ ។





## ភាពស្ទាត់ជំនាញទាំង ៦ សំរាប់ធ្វើការប្រាស្រ័យទាក់ទង ដោយប្រើពាក្យពេជន៍ប្រកបដោយប្រសិទ្ធិភាព

- ការជួយសំរួល (Facilitation)
- ដឹកនាំ (Direction)
- ការសង្ខេប និង ផ្ទៀងផ្ទាត់ (Summarizing and checking)
- ការសំដែងការយល់អារម្មណ៏ (Empathizing)
- ការធ្វើឱ្យមានទំនុកចិត្ត ( Reassuring)
- ការបង្ហាញភាពជាដៃគូ ( Expressing partnership)



# ការប្រមូលពត៌មានក្នុងពេលស្រង់យកប្រវត្តិអ្នកជំងឺ






# សំណួរពិភាក្សា

- តើអ្នកត្រូវការពតិមានអ្វីខ្លះ ក្នុងការស្រង់ប្រវត្តិ អ្នកជំងឺ ?



# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ

១- ពត៌មានលំអិតទូទៅស្តីអំពីអ្នកជំងឺ ( General details)

២- ការពិពណ៌នាអំពីជំងឺបច្ចុប្បន្ន ( Present illness)

៣- ផែនការគ្រួសារ (Family Planning)

៤- ប្រវត្តិជំងឺ  (Medical history)

៥- ប្រវត្តិនៃសកម្មភាពផ្លូវភេទ (Sexual history)







# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (១)

**១- ពត៌មានលំអិតទូទៅ (General details):**

- អាយុ
- អាស័យដ្ឋាន
- មុខរបរ
- ការិតវប្បធមិ

# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (២)

## ២ - ជំងឺបច្ចុប្បន្ន (Present illness) :

— ការត្អូញត្អែរអំពីបញ្ហាបច្ចុប្បន្ន និងរយៈពេលដែលមានបញ្ហា

— **ចំពោះអ្នកជំងឺបុរសៈ**

- ហូរខ្ទុះតាមបង្ហូរនោម
- ដំបៅលើប្រដាប់បន្តពូជ
- សិរមាន់លើប្រដាប់បន្តពូជ
- ហូរខ្ទុះតាមរន្ធគូថ
- ពិបាកនោម
- ហើមកូនកណ្តុរ
- ឈឺ/ហើមពងស្វាស
- រមាស់លើស្បែក







# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (៣)

## ២ - ជំងឺបច្ចុប្បន្ន (Present illness) : ( ត )

— **ចំពោះអ្នកជំងឺស្ត្រីៈ**

- ធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស
- ឈឺចាប់ពេលរួមភេទ
- នោមពិបាក
- សិរមាន់
- ហូរខ្ទុះតាមរន្ធគូថ
- ឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ
- ដំបៅ
- រមាស់
- ហើមកូនកណ្តុរ



# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (៣)

## ៣ - ផែនការគ្រួសារ (Family Planning) :

- ការបង្ការការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ និងការគិតគូរដល់ ផែនការគ្រួសារគួរលើកយកមកពិភាក្សារាល់ពេលដែលអ្នកជំងឺមកពិនិត្យៈ

– ការពន្យាកំណើតដូចជា ថ្នាំចាក់ ថ្នាំគ្រាប់ ស្រោមអនាម័យ កងដាក់ក្នុងដៃ និងកងដាក់ក្នុងស្បូន

- ចំនួននៃការមានផ្ទៃពោះ ចំនួនកូននៅរស់

- ចំនួននៃការពន្លូតកូន ការរលូតកូន

- រដូវចុងក្រោយ



# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (៤)

## ៤ - ប្រវត្តិជំងឺ (Medical history)

— តើធ្លាប់កើតកាមរោគដែរឬទេ? - ប្រភេទអ្វី ? នៅពេលណា ?

— តើមានបានទទួលការព្យាបាលដែរឬទេ ? ហើយការឆ្លើយតបនឹងការព្យាបាលយ៉ាងដូចម្តេច ?

— តើមានលទ្ធផលនៃការធ្វើតេស្តមុនៗដែរឬទេ ?

— ជំងឺផ្សេងៗទៀត - ប្រភេទអ្វី ? កាលបរិច្ឆេទ ? មានបានទទួលការព្យាបាលដែរឬទេ? ហើយការឆ្លើយតប នឹងការព្យាបាល យ៉ាងដូចម្តេចដែរ តើមានលទ្ធផលនៃការធ្វើតេស្តដែរឬទេ?

— ការប្រើប្រាស់ឱសថ

— ភាពមិនត្រូវនឹងថ្នាំ ( drug allergies)

# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (៥)

៥- **ប្រវត្តិផ្លូវភេទ** (Sexual history)

ការប្រព្រឹត្តិដែលប្រឈមមុខនឹងគ្រោះថ្នាក់ ដើម្បីស្វែងរកកត្តាដែលជះឥទ្ធិពលដល់សុខភាពបន្តពូជរបស់អ្នកជំងឺ រួមមានៈ

- **សំរាប់បុរស**
  - ♦ក្នុងឆ្នាំកន្លងទៅ តើអ្នកធ្លាប់មានដៃគូរួមភេទទៀងទាត់ប៉ុន្មាននាក់?
  - ♦តើអ្នកមានប្រើស្រោមអនាម័យនៅពេលរួមភេទលើកចុងក្រោយដែរឬទេ?
  - ♦តើមានរួមភេទជាមួយដៃគូរួមភេទផ្សេងទៀតដែរឬទេ ក្នុងខែកន្លងទៅ?
  - ♦តើកន្លងមកអ្នកជំងឺធ្លាប់មានកើតកាមរោគដែរឬទេ?
  - ♦តើបច្ចុប្បន្នអ្នកជំងឺមានប្រើប្រាស់គ្រឿងញៀនដែរឬទេ?



# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (៦)

៥- **ប្រវត្តិផ្លូវភេទ** (Sexual history)

- **សំរាប់បុរសរួមភេទជាមួយបុរស** (MSM)
  - ♦ តើអ្នករួមភេទជាមួយបុរស ស្រ្តី ឬទាំងពីរភេទ?
  - ♦ ជាញឹកញាប់ តើអ្នករួមភេទតាមគូថ ឬតាមមាត់?
  - ♦ តើអ្នករួមភេទដោយការបបោសអង្អែល ឬដោយស៊កបញ្ចូល?



# ពត៌មានដែលអ្នកផ្តល់សេវាត្រូវការ (៦)

៥- **ប្រវត្តិផ្លូវភេទ** (Sexual history)

- **សំរាប់ស្ត្រីៈ**
  - ♦ តើអ្នកជំងឺចេះប្រើស្រោមអនាម័យដែរឬទេ?
  - ♦ តើក្នុងរយៈពេល៣ខែកន្លងមក អ្នកមានភ្ញៀវទៀងទាត់/សង្សារប៉ុន្មាននាក់?
  - ♦ តើភាគច្រើន អ្នករួមភេទតាមរបៀបណាខ្លះ ជាមួយភ្ញៀវទៀងទាត់/សង្សារ (តាមទ្វារមាស មាត់ រន្ធគូថ)?
  - ♦ តើអ្នកមានប្រើស្រោមអនាម័យក្នុងការរួមភេទលើកចុងក្រោយជាមួយភ្ញៀវទៀងទាត់/សង្សារដែរឬទេ?
  - ♦ តើអ្នកជំងឺមានប្រើប្រាស់គ្រឿងញៀនដែរឬទេ?



# ការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់ជំងឺរលាកមាត់ស្បូន

- ចំពោះជំងឺរលាកមាត់ស្បូន ការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់ មានសារៈប្រយោជន៏ចំពោះស្ត្រីដែលមានធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស :

**ក) ការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់ជំងឺរលាកមាត់ស្បូនសំរាប់ស្ត្រីបំរើសេវាកំសាន្ត**

**( ដោយផ្ទាល់ ឬ ដោយប្រយោល)**

- តួញត្អែរមានធ្លាក់សពណ៌លឿងខាប់
- ឈឺចាប់ផ្នែកខាងក្រោមនៃពោះនៅពេលរួមភេទ
- ទទួលភ្ញៀវលើសពី៥នាក់ក្នុងមួយថ្ងៃជាមធ្យម
- មិនបានប្រើស្រោមអនាម័យពេលរួមភេទជាមួយភ្ញៀវថ្មី

បើចំលើយមានចាប់ពី ២ ឡើងទៅ ត្រូវព្យាបាលជំងឺរលាកមាត់ស្បូន

## ការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់ជំងឺរលាកមាត់ស្បូន (ត)

**៩) ការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់ជំងឺរលាកមាត់ស្បូនសំរាប់ស្ត្រីទូទៅផ្សេងៗ**

- **តើអ្នកជំងឺមានធ្លាក់ ស ពណ៌លឿងខាប់ដូចខ្ទុះដែរឬទេ? ឬ**
- **តើដៃគូមានរោគសញ្ញាជំងឺកាមរោគដែរឬទេ? ឬ**

* *បើចំលើយមានចាប់ពី ១ ឡើងទៅ ត្រូវព្យាបាលជំងឺរលាកមាត់ស្បូន ។*

* * កត្តាប្រឈមមុខនឹងគ្រោះថ្នាក់នៃការបង្ករោគតាមការរួមភេទនៅនឹងមាត់ស្បូននេះ ត្រូវបានកែសំរួលឡើងវិញនៅឆ្នាំ ២០០៧ ក្រោយពីមានការព្យាបាលច្រើនលើសលុបនៃជម្ងឺរលាកមាត់ស្បូនចំពោះស្ត្រីទូទៅ នៅតាមមណ្ឌលសុខភាព ។



# ការពិនិត្យអ្នកជំងឺ



## ការប្រកាន់ភ្ជាប់នូវមនសិការវិជ្ជាជីវៈនៅពេលពិនិត្យអ្នកជំងឺ

- ធានារក្សាអាថិកំបាំងឱយបាន
- ពន្យល់អំពីអ្វីដែលអ្នកនឹងធ្វើ និងអំពីសារៈសំខាន់របស់វា
- ធ្វើការពិនិត្យដោយលក្ខណៈទុកចិត្តលើខ្លួនឯង ដោយកុំបង្ហាញឱ្យឃើញអំពីភាព មិនច្បាស់លាស់ ឬ ការអៀនខ្មាស់
- សូមកុំគំរោះគំរើយ ឬធ្វើការពិនិត្យដោយប្រឆាំងនឹងបំណងរបស់អ្នកជំងឺ ។
- សូមប្រើប្រាស់នូវជំនាញក្នុងការប្រស្រយ័ទាក់ទងទាំងអស់ដែលមានក្នុងជំពូកនេះ ។



## ការអនុវត្តន៍ល្អក្នុងការពិនិត្យជំងឺ

| កត្តាសំខាន់ | ការណែនាំ |
|---|---|
| ១. ធ្វើឱ្យអ្នកជំងឺបាត់ការភ័យខ្លាច | ពន្យល់ពីអ្វីដែលអ្នកត្រូវធ្វើ និងលើកទឹកចិត្តឱ្យមានអារមណ៍ល្អពេលពិនិត្យ |
| ២. ភាពស្ងាត់កំបាំង | បិទវាំងននបង្អួច ឬបាំងជុំវិញគ្រែពិនិត្យជំងឺ និងបិទទ្វារ |
| ៣. គ្រែពិនិត្យជំងឺ | ពិនិត្យអ្នកជំងឺដែលគេងផ្ទៀង ឬ prayer position |
| ៤. ពន្លឺភ្លើងល្អ | ដំបៅ ស្នាមជាំ ពងបែកតូចៗមាននៅលើអ្នកជំងឺ អាចមើលឃើញបានច្បាស់ល្អ ដោយសារពន្លឺភ្លើងសំរាប់ពិនិត្យ |

## ការអនុវត្តន៍ល្អក្នុងការពិនិត្យជំងឺ (ត)

| កត្តាសំខាន់ | ការណែនាំ |
|---|---|
| ៥. ការបង្ការជាសកល | លាងដៃជាមួយសាប៊ូ និងទឹក មុននិងក្រោយពេលពិនិត្យជំងឺ ហើយពាក់ស្រោមដៃ |
| ៦. អ្នកផ្តល់សេវា | អ្នកផ្តល់សេវាជួយរៀបចំអ្នកជំងឺដើម្បីធ្វើការពិនិត្យ និងធានាបានល្អនូវការពិនិត្យ តាមក្បួនខ្នាតវេជ្ជសាស្ត្រគំរូ |
| ៧. ការរៀបចំល្អ | មានសំភារៈ(ឧៈកញ្ចក់ឡាម សំឡីមានដង និង spatulas), disposable plastic ឬsterilisable specula និង anoscopes ដាក់នៅក្បែរ |
| ៨. ការប្រាស្រ័យទាក់ទង | សួរអ្នកជំងឺពីភាពមិនស្រួល ផ្តល់ការធានារ៉ាប់រង ប្រាប់ពីពេលដែលភាព មិនស្រួលនេះនឹងត្រូវបញ្ចប់ និងពីរបៀបដើម្បីសំរាលនូវភាពមិនស្រួល |



## ការអនុវត្តន៍ល្អក្នុងការពិនិត្យជំងឺ (ត)

| កត្តាសំខាន់ | ការណែនាំ |
|---|---|
| ៩. ការពិនិត្យទូទៅ | ពិនិត្យស្បែក មាត់ កូនកណ្តុរ ដើមទ្រូង បេះដូង និងពោះ |
| ១០. ការពិនិត្យដោយស្ពេគូឡូម | អ្នកជំងឺរៀបរាប់ពីរោគសញ្ញាដែលមិនអាចយកជាការបាន ។ ការពិនិត្យដោយ ប្រើស្ពេគូឡូមគឺដើម្បីបង្ហាញនូវរោគសញ្ញាផ្សេងៗ ។ ផ្នែកមួយយ៉ាងសំខាន់នៃ ការពិនិត្យ គឺការមើលដោយភ្នែកនៅតំបន់មាត់ស្បូន និងក្នុងទ្វារមាស |
| ១១. ការពិនិត្យរន្ធគូថ | អ្នកជំងឺរៀបរាប់ពីរោគសញ្ញាដែលមិនអាចយកជាការបាន ។ ការពិនិត្យដោយ anoscopyគឺដើម្បីបង្ហាញរោគសញ្ញាផ្សេងៗ ។ ផ្នែកមួយយ៉ាងសំខាន់នៃការពិនិត្យ គឺការមើលដោយភ្នែកនៅតំបន់ anogenital ។ |



# សំណួរពិភាក្សាក្រុមធំ

- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីពិនិត្យអ្នកជំងឺបុរស?
- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីពិនិត្យអ្នកជំងឺស្ត្រី?



## ផ្នែកនៃរាងកាយដែលត្រូវពិនិត្យ

| ផ្នែកនៃរាងកាយ (region) | Exposure needed | Body Position |
|---|---|---|
| ■ដៃ/ ប្រអប់ដៃ<br>■ក្បាល និង ក<br>■មាត់ | ដោះសំលៀកបំពាក់ចេញ | អង្គុយ (setting) |
| ■ ពោះ | ដោះសំលៀកបំពាក់ចេញ<br>ទុកពោះឱ្យនៅភាពទនល | គេងផ្ងា (Supine) |
| ■ ប្រដាប់ភេទ<br>■ គូថ/rectum | សំលៀកបំពាក់ក្រៅ និងក្នុងដោះចេញ<br>ចាប់ពីពោះរហូតដល់ជង្គង់ឱ្យនៅភាពទនទល | គេងផ្ងា (Supine) |

# ផ្នែកនៃរាងកាយដែលត្រូវពិនិត្យ

- ឱ្យអ្នកជំងឺអង្គុយនៅគែមគ្រែ
- ពាក់សំលៀកបំពាក់
- ពិនិត្យដៃ ប្រអប់ដៃ រកមើល ស្នាមកន្ទួល ការហើមប៉ោងកូនកណ្តុរ
  - ពិនិត្យសន្លាក់ (joints) ដើម្បីរកមើលការហូរ(ខ្ទុះ) ស្នាមក្រហម
  - បាតដៃដើម្បីរកមើលស្នាមកន្ទួល លាយឡំជាមួយជំងឺស្វាយ
- ពិនិត្យ និងស្ទាប ក និងលលាដ៏ក្បាលៈ
  - ពិនិត្យមើលដុំពកនៅក និងលលាដ៏ក្បាលផ្នែកខាងក្រោយ
  - ពិនិត្យមើលការជ្រុះសក់



# ផ្នែកនៃរាងកាយដែលត្រូវពិនិត្យ

- ពិនិត្យស្បែកៈ
  - ពងផ្លួច (molluscum or penicillium)
- ពិនិត្យមាត់ និងធ្មេញដោយប្រើពន្លឺភ្លើង និងប្រដាប់សង្កត់អណ្តាត
  - រកមើលរោគសញ្ញានៃជំងឺស្វាយ និងផ្សិតក្នុងមាត់
  - បបូរមាត់ៈ ដំបៅពងបែក (cold sores)
- ពិនិត្យបំពង់ក
  - ទឹករងៃ ស្នាមកន្ទួលក្រហម
- ពិនិត្យស្បែកពោះ
  -ពិនិត្យមើលរោគសញ្ញានៃជំងឺថ្លើមរាំរៃ ស្នាមកន្ទួលនៃជំងឺស្វាយ
- ស្ទាបថ្លើម និង លំពែង



# ជម្ងឺស្វាយ ដំណាក់កាលទី ២






Pharyngeal gonorrhea



Chancre syphilis on tongue



# ការពិនិត្យអ្នកជំងឺបុរស



១ — ការពិនិត្យជាប្រចាំរួមមាន:

- ពិនិត្យមើល (inspection)៖
  - ស្បែកដៃ, ប្រអប់ដៃ កំភួនដៃ ភ្លៅ និងផ្នែកខាងក្រោមនៃពោះ
  - រោមpubic រកមើលចៃ និងពងចៃ
  - លិង្គ រួមទាំងរន្ធបង្ហូរនោម ដោយពន្លាត់ស្បែកគ្របក្បាលលិង្គ និងច្បូតបង្ហូរនោម
- ស្ទាប (palpation)៖
  - កន្សោមពងស្វាស (testes, បំពង់ទឹកកាម (spermatic cord), អេពីឌីឌីម (epididymis))
  - កូនកណ្តុរគ្រលៀន



# ការពិនិត្យអ្នកជំងឺបុរស (ត)

២- សំរាប់បុរសរួមភេទជាមួយបុរស (MSM):

- ពិនិត្យមើលមាត់ បំពង់ក perineum និងរន្ធគូថ
- ស្ទាបក លើឆ្អឹងដងកាំបិត(supraclavicular) និងក្លៀកដើម្បីរកកូនកណ្តុរ។
- ពិនិត្យដោយ anoscopic ចំពោះ MSM ដែលត្អូញត្អែរមានរោគសញ្ញានៅរន្ធគូថ
- ធ្វើការពិនិត្យមាត់ ចំពោះបុរសរួមភេទតាមមាត់

៣- កត់ត្រាទុកវត្តមាន ឬអវត្តមាននៃ

- ហើមពងស្វាស
- ដំបៅ
- ការហូរខ្ទុះតាមបង្ហូរនោម ដោយបញ្ជាក់ពីពណ៌ និង បរិមាណ





# ការពិនិត្យប្រដាប់ភេទ

១- ពាក់ស្រោមដៃ

២- ស្ទាបរកកូនកណ្តុរគ្រលៀន

៣-ពិនិត្យមើលផ្នែកខាងក្រោមនៃពោះ រោមpubic និងរោមជើង

- រកមើលចៃ (lice) រមាស់ (scarbies), molluscum, សិរមាន់ ស្នាមសំលាកចាស់ (old scars) ឬរបួស (trauma).

៤- ពិនិត្យមើលស្បែក:

- កន្លែងផ្នត់ៗនៃស្បែក, ក្រោមពងស្វាស (under scrotum)
- រកមើលស្នាមកន្ទួល (rashes) ដុំពក (lumps)

៥- ស្ទាបកន្សោមពងស្វាស



# ការពិនិត្យប្រដាប់ភេទ (ត)

៦- ពិនិត្យមើលគល់លិង្គ (ជិតរោម pubic) និងតាមបណ្តោយតួលិង្គ

- រកមើលសិរមាន់ ដំបៅ (ulcers) និងស្នាមកន្ទួល (rashes)

៧- ពន្លាត់ និងពិនិត្យមើលក្រោមស្បែកក្បាលលិង្គ

- រកមើលសិរមាន់, ដំបៅ (ulcers) ស្នាមកន្ទួល(rashes)

៨- ផ្នែកនៃរន្ធបង្ហូរនោម

- រកមើល សិរមាន់ ដំបៅ (ulcers)
- ច្បូតបង្ហូរនោម

# ការពិនិត្យពងស្វាស

- ពិនិត្យដោយដៃម្ខាងទ្រពងស្វាស ហើយកត់សំគាល់នូវអ្វីដែលមិនធម្មតា
- ពិនិត្យ ពងស្វាស ម្តងមួយៗក្នុងពេលតែមួយ

  - ប្រមៀល ពងស្វាស ថ្នមៗដោយប្រើម្រាមដៃ និងមេដៃ

  - **<u>ពងស្វាស ធម្មតាឃើញៈ</u>**

    - ពងស្វាសម្ខាងអាចធំជាងម្ខាងទៀត និង ពងស្វាស ខាងឆ្វេងអាចធ្លាក់បន្តិចជាងខាងស្តាំ
    - ជាធម្មតាមានរាងពងក្រពើ
    - ហាប់ (firm) រលោង (smooth) និងយឺត (rubbery)

  - **<u>ពងស្វាសមិនធម្មតាឃើញៈ</u>**

    .- កំណត់ដោយដុំ ឬការបុកទង្គិចលើ ពងស្វាស



# ការពិនិត្យពងស្វាស (ត)

- ពិនិត្យអេពីឌីឌីម ( នៅជាប់ testicle )

  - ទន់ និងចល័ត (Soft and mobile)

- ពិនិត្យបំពង់ទឹកកាម (Spermatic cord)

  - បន្តពីអេពីឌីឌីម (Contiguous with epididymis)

  - រលោង និងចល័ត ( Smooth and mobile)






# ការពិនិត្យតំបន់ចន្លោះរន្ធគូទ (Perineum/Anorectum)

- ឱ្យអ្នកជំងឺដោះខោចេញ
- អោយអ្នកជំងឺគេងផ្អៀងទៅឆ្វេង បែរខ្នងរកអ្នក
- អង្គុញជើង
- ប្រាប់អោយអ្នកជំងឺយកដៃស្តាំទាញកំប៉េះគូទខាងស្តាំ
- ពិនិត្យមើលតំបន់ជុំវិញគូទ និង រន្ធគូទ :

  - រកមើលសិរមាន់ ដំបៅ ស្នាមកន្ទួល ឬសដូងបាត ហូរឈាម ហូរខ្ទុះ



# Left lateral Position





# ការពិនិត្យរន្ធគូថដោយប្រើ Anoscope

❒ បង្ហាញ Anoscopeទៅអ្នកជំងឺ

❒Anoscope ត្រូវឱ្យប្រើបានតែនៅពេលដែលអ្នកជំងឺពិពណ៌នាថា មានរោគសញ្ញារលាកក្រសាលគូទ (proctitis) ឬមានហូរឈាមតាមរន្ធគូទ។

❒ ជាទូទៅមិនគួរប្រើវាប្រសិនបើនៅផ្នែកខាងក្រៅមានវត្ថុមាននៃដំបៅពងបែក សិរមាន់ ឬស្នាមដាច់រលាត់ (fissures)



Disposable Anoscope



# ការពិនិត្យរន្ធគូថដោយប្រើ Anoscope (ត)

- Anoscope មានលក្ខណៈដូចខាងក្រោមៈ
  - រាងជាបំពង់, រឹង និងប្រហោង
  - បណ្តោយ១០ស.ម, ទំហំ២-៤ស.ម
  - ស្នូលកណ្តាលដែលអាចដោះចេញបាន
  - ខ្លី ជាជ័រ (plastic) ប្រើរួចបោះចោល
  - ជាដែកត្រូវតែរំងាប់ និងសំលាប់មេរោគ (disin

ក្រោយពេលប្រើពីអ្នកជំងឺម្នាក់ទៅអ្នកជំងឺម្នាក់ទៀត( មុនប្រើត្រូវក័ដៅដោយទឹកក្តៅឧណ្ហៗ) ។






# ការពិនិត្យរន្ធគូថដោយប្រើ Anoscope (ត)

- ដំបូងពិនិត្យដោយប្រើចង្អុលដៃលូកចូលក្នុងបំពង់លាមក
- ដាក់ Anoscop ចូលឱ្យអិបនឹងគូទ
- ដាក់ដោយសង្កត់ថ្នមៗដើម្បីជួយបន្ធូរ សាច់ដុំរន្ធគូទ (sphincter)ហើយស៊កបញ្ចូលយឺតៗ
- ប្រាប់អ្នកជំងឺឱ្យបន្ធូរ (relax) ដកដង្ហើមវែងៗ ហើយដាក់គូទចុះ (bear down)

ធ្វើដូចការពិនិត្យដោយប្រើចង្អុលដៃខាងលើ។





# ការពិនិត្យរន្ធគូថដោយប្រើ Anoscope (ត)

- ដកស្នូល (trocar) ចេញ

ពិនិត្យមើលទឹករំអិលរន្ធគូទដោយពន្លឺភ្លើងភ្លឺខ្លាំង

- រកមើល ដំបៅ ហូរខ្ទុះ ហូរឈាម

សិរមាន់ ស្នាមកន្ទួល អនាម័យ



# ការពិនិត្យអ្នកជំងឺស្ត្រី

- ការពិនិត្យរាងកាយជាប្រចាំចំពោះស្ត្រីដែលបានសង្ស័យថាមានការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ រួមមាន:

១- ពិនិត្យមើល

- ស្បែក ផ្នែកខាងក្រោមនៃពោះ តំបន់ក្រលៀន ភ្លៅ ដៃ បាតដៃ និងកំភួនដៃ
- រោម pubic រកមើលចៃ និងពងចៃ

២- ពិនិត្យមើល និងស្ទាបផ្នែកខាងក្រៅនៃប្រដាប់ភេទ និងពិនិត្យមើល perineum និងរន្ធគូទ (anus)

៣- ស្ទាបរកកូនកណ្តុរក្រលៀន







# ការពិនិត្យអ្នកជំងឺស្ត្រី (២)

៤- ស្ទាបពោះដើម្បីរកមើល ដុំនៅអាងត្រគាក និងការឈឺចាប់ពោះ ។

៥- ការពិនិត្យទ្វារមាស និងមាត់ស្បូនដោយស្ពេគុឡូម

- សើកចង្អុលដៃទៅក្នុងមាត់រន្ធទ្វារមាស ហើយសង្កត់បើរំលោចុះថ្នមៗ
- ដាក់ស្ពេគុឡូមឱ្យជាប់កៀក ក្នុងមុំ៤៥ដឺក្រេ ហើយដកម្រាមដៃចេញ រួចបង្វិលស្ពេគុឡូមឱ្យ ទៅស្ថានភាពផ្តេក
- បើកស្ពេគុឡូមហើយបង្វិលរហូតដល់លែឃើញមាត់ស្បូន
- ពិនិត្យមើលភ្នាសទ្វារមាស ដោយកត់សំគាល់ដំបៅ ហូរខ្ទុះ
- ពិនិត្យមើលមាត់ស្បូន និងរន្ធមាត់ស្បូនរកមើលការហូរខ្ទុះ ហូរឈាម ដំបៅ និងភាពងាយដាច់ដោច







# Speculum examination of the vagina and cervix.







# ការពិនិត្យអ្នកជំងឺស្ត្រី (៣)

៦- ការពិនិត្យអាងត្រគៀកដោយដៃទាំងពីរ

គេត្រូវធ្វើដោយ ប្រុងប្រយ័ត្ន កុំឱ្យមានការឈឺចាប់ដល់អ្នកជំងឺ ។



គេត្រូវតាមរកមើល ហើយកត់ត្រា ទុកវត្តមាន ឬអវត្តមាននៃ :

- ហើមក្រលៀន
- ដំបៅ
- ធ្លាក់ ស ដោយកត់សំគាល់ ពណ៌ និងបរិមាណ

# ការប្រមូលយកសារធាតុសរីរៈពីបុរស (១)

## ក -សំរាប់បុរស:

១- ការបំពាក់ពណិក្រោមសារធាតុសរីរៈយកពីបង្ហូរនោមត្រូវតែអនុវត្ត ទោះជាអ្នកជំងឺមាន ឬគ្មានរោគសញ្ញារលាកបង្ហូរនោមក៏ដោយ ។

២- ការបណ្ដុះសារធាតុសរីរៈពីបង្ហូរនោមដើម្បីរកមេរោគហ្គោណូកូក

៣- តេស្ដរកមេរោគស្វាយ (Syphilis serology)

៤- បញ្ជូនអតិថិជនរបស់គ្លីនិកកាមរោគទៅ VCCT (រួមទាំងអ្នកប្រើគ្រឿងញៀន និងអ្នកមានទំនាក់ទំនងផ្លូវភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ)




FIGURE 2




**To collect a specimen for culture,** insert the swab at least 2 cm past the meatus.



# ការប្រមូលយកសារធាតុសរីរៈ(២)

## ខ -សំរាប់បុរសរួមភេទជាមួយបុរស(MSM):

១- ការបំពាក់ពណិក្រោមសារធាតុសរីរៈយកពីភ្នាសបំពង់លាមក

២- ការបណ្ដុះសារធាតុសរីរៈរកមេរោគហ្គូណូកូក (GC), Chlamydia trachomatis

៣- វីរុស herpes simplexដោយធ្វើតេស្ដ Nucleiic acid amplification

៤- បើឃើញមានដំបៅនៅជុំវិញរន្ធគូទ ឬប្រហោងលាមក ធ្វើតេស្ដរកមេរោគស្វាយ (RPR ឬ VDRL, TPPA)

៥- បើរលាកពោះវៀនតូច ឬរលាកពោះវៀនធំ:

- បណ្ដុះលាមករកមេរោគ Salmonella, Shigella និង Campilobacter និង
- ពិនិត្យលាមករកមើលពងព្រូន និងព្រូន



# ការប្រមូលសារធាតុសរីរៈយកទៅពិនិត្យនៅមន្ទីរពិសោធន៍

- **របៀបយកសចេញពីទ្វារមាស និងមាត់ស្បូនៈ**

១- ទ្វារមាស :

យកសចេញពីទ្វារមាសដោយប្រើសំឡីមានដង (Vaginal swabs ) សំរាប់រក :

– Trichomonas, Candida, Gardnerella Vaginalis

២- មាត់ស្បូន :

ក្រោយពីដាក់ Speculum ត្រូវលាងសំអាតមាត់ស្បូនដោយប្រើសៀ៉មប្រៃ អោយអស់ខ្ទុះនៅលើមាត់

ស្បូន ហើយបញ្ចូលសំឡីមានដង (cervicall swabs) ជំរៅប្រហែល ១-១,៥ ស.ម

រួចត្បាល់ថ្នមៗប្រហែល១៥-៣0វិនាទី សំរាប់រក

– Gonorrhoea: Gram Stain, Culture

- Chlamydia : Culture



# ការប្រមូលសារធាតុសរីរៈយកទៅពិនិត្យនៅមន្ទីរពិសោធន៍

- **របៀបយកសចេញពីទ្វារមាសនិងមាត់ស្បូន**

~ វត្ថុបំណងៈ

វិធីផ្សេងៗក្នុងការពិនិត្យសៈ

–ពិនិត្យ pHរបស់ទ្វារមាស

–Wet mount (KOH) ពិនិត្យរកមេរោគផ្សិត

– Wet mount រក Trichomonas Trachomatis, Gardnerella vaginalis

-Test Amine : Gardnerella vaginalis

-Gram Stain: Gonorrhea

-បណ្ដុះសពីមាត់ស្បូន រកៈ Gonorrhea ,Chlamydia

# ការប្រមូលសារធាតុសរីរៈយកទៅពិនិត្យនៅមន្ទីរពិសោធន៍

**សំភារៈ :**

- សំឡីមានដង សំរាប់យកសចេញពីទ្វារមាសនិងមាត់ស្បូន( Vaginal swabs )
- សូលុយស្យុង ប៉ូតាស្យូម អ៊ីដ្រុកស៊ីត( KOH )
- សេរ៉ូមប្រៃ ( Normal saline )
- ឡាមកញ្ចក់ ( Glass slide )
- ប្រតិករ សំរាប់ការពិនិត្យដោយបំពាក់ពណ៌ ( Gram Stain Reaction )



# តើត្រូវប្រើប្រាស់ standard medical history form សំរាប់ស្ត្រី និង Buletin analysis យ៉ាងដូចម្តេច?



# ការប្រើប្រាស់ SMH សំរាប់ស្ត្រី

- General Information
- History & Reason for consultation
- Risk Behaviour
- Risk assessments for cervicitis
- Clinical Examination
- Laboratory examination
- Diagnosis
- Treatment
- Counseling & Advice



មន្ទីរសុខាភិបាលខេត្ត (Provincial Health Department)............ ព្រះរាជាណាចក្រកម្ពុជា (Kingdom of Cambodia)

គ្លីនិកសុខភាពគ្រួសារ (Family health clinic)………………… ជាតិ (Nation) សាសនា (Religion) ព្រះមហាក្សត្រ (King)

## ប័ណ្ណវិភាគតេស្តមន្ទីរពិសោធន៍

ឈ្មោះអ្នកជម្ងឺ (Name)..........................................អាយុ (Age)..............................................ភេទ (sex)...................................

លេខកូដគ្លីនិក (Clinic code number)..........................................លេខកូដមន្ទីរពិសោធន៍ (Lab code number)..............................

**MICROSCOPIC EXAMINATION**

| **Wet preparation**<br>**(ស ក្នុងសភាពស្រស់ )**<br>☐ **Vaginal (ទ្វារមាស)** | | **Gram stain**<br>**(តេស្តបំពាក់ពណ៌ក្រាម)**<br>☐ **Vaginal (ទ្វារមាស)** | | | **Gram stain/ Methylene blue**<br>**(ក្រាម/មេទីឡែនប៊្លូ)**<br>☐ **Endocervical**<br>**(មាត់ស្បូនខាងក្នុង)** | | **Gram stain**<br>**(តេស្តបំពាក់ពណ៌ក្រាម)** | | **Syphilis test** |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | ***RPR test*** |
| pH | | Nugent Score<br>(ពិន្ទុនូសែន ) | 1-3 | | <10WBCs/HPF | | ☐ ***Urethral smear***<br>***(វត្ថុវិភាគស្រង់ពីបង្ហូរនោម)*** | | |
| Whiff test/Amine test<br>(KOH): តេស្តក្លិន | | | 4-6 | | 10-20WBCs/HPF | | WBC | | ***TPPA/ TPHA test*** |
| Clue Cells<br>( ឃ្លូសែល ) | | | >7 | | >20WBCs/HPF | | GNID<br>ហ្គោណូកូក | | |
| Trichomonas<br>(ទ្រីកូម៉ូណាស់ ) | | Budding yeasts/<br>Hyphae (ផ្សិត ) | | | GNID<br>ហ្គោណូកូក | | ☐ ***Anal smear***<br>***(វត្ថុវិភាគស្រង់ពីគូថ)*** | | ***Rapid test*** |
| Budding yeasts/<br>Hyphae (ផ្សិត ) | | | | | | | WBC | | |

ថ្ងៃទី...............ខែ...............ឆ្នាំ............... ថ្ងៃទី........................ខែ....................ឆ្នាំ................

ហត្ថលេខាគ្រូពេទ្យ (signature physician) ហត្ថលេខាអ្នកបច្ចេកទេសមន្ទីរពិសោធន៍ (signature technician)

# ចង្កោមរោគសញ្ញា STI/RTI ដែលកើតមានញឹកញាប់

| Syndrome | STI/RTI | Organism | Type | Sexually transmitted | Curable |
|---|---|---|---|---|---|
| Genital ulcer | Syphilis | *Treponema pallidum* | bacterial | yes | yes |
| | Chancroid | *Haemophilus ducreyi* | bacterial | yes | yes |
| | Herpes | Herpes simplex | viral | yes | no |
| | Granuloma inguinale | *Klebsiella granulomatis* | bacterial | yes | yes |
| | Lymphogranuloma venereum | *Chlamydia trachomatis* | bacterial | yes | yes |



# ចង្កោមរោគសញ្ញា STI/RTI ដែលកើតមានញឹកញាប់

| Syndrome | STI/RTI | Organism | Type | Sexually transmitted | Curable |
|---|---|---|---|---|---|
| Vaginal discharge | Bacterial vaginosis | multiple | bacterial | No | yes |
| | Yeast infection | *Candida albicans* | fungal | No | yes |
| | Trichomoniasis | *Trichomonas vaginalis* | protozoal | yes | yes |
| | Gonorrhoea | *Neisseria* | bacterial | yes | yes |
| | Chlamydia | *Chlamydia trachomatis* | bacterial | yes | yes |



# ចង្កោមរោគសញ្ញា STI/RTI ដែលកើតមានញឹកញាប់

| Syndrome | STI/RTI | Organism | Type | Sexually transmitted | Curable |
|---|---|---|---|---|---|
| P I D | Bacterial anaerobia<br>Gonorrhoea<br>Chlamydia | multiple<br>*Neisseria*<br>*Chlamydia trachomatis* | bacterial | Yes | yes |
| Genital warts | Human papilloma virus (HPV) | Human papilloma virus (HPV) | virus | Yes | No |
| Urethral discharge | Gonorrhoea<br>Chlamydia | *Neisseria*<br>*Chlamydia trachomatis* | bacterial | yes | yes |

# ម៉ូឌុលទី ៣.១

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបន្តរោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ការហូរខ្ទុះតាមបង្ហួរនោម

**(URETHRAL DISCHARGE SYNDROME)**



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្រ្តនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ការហូរខ្ទុះតាមបង្ហួរនោម



## របៀបប្រើប្រាស់គំនូសបំព្រួញ (How to use the flow-charts)

- សូមចាប់ផ្តើមពីប្រអប់លើបង្អស់នៃគំនូសបំព្រួញនៅត្រង់ប្រអប់ចាប់ផ្តើម (entry-point box) ដែលពិពណ៌នាអំពីការត្អូញត្អែររបស់អ្នកជំងឺ ។
- ប្រមូលយកពត៌មាន ដែលត្រូវការសំរាប់ធ្វើការសំរេចចិត្តដើម្បីកំណត់យកចង្កោមរោគសញ្ញា ណាមួយ
- ធ្វើការសំរេចចិត្តដោយពឹងផ្អែកលើពត៌មាន ដែលប្រមូលបានហើយប្រមូលយកពត៌មាន បន្ថែម ប្រសិនបើត្រូវការ
- ធ្វើរោគវិនិច្ឆ័យ
- ជ្រើសរើសយកការព្យាបាលដែលត្រូវនឹងរោគវិនិច្ឆ័យ
- ផ្តល់ការអប់រំ និងជំរុញការប្រើប្រាស់ស្រោមអនាម័យ
- ពិនិត្យមើលលទ្ធភាពក្នុងការបញ្ជូនដៃគូរួមភេទ



# គំនូសបំព្រួញស្តីពីការហូរខ្ទុះពីបង្ហួរនោម



# គំនូសបំព្រួញសំរាប់ការហូរខ្ទុះពីបង្ហូរនោម (តាមរោគសញ្ញា)






# ការបំពាក់ពណ៌ក្រាម (Gram-stained smear)



PMNs with Gonococcal



PMNs, no Gonococcal



# គំនូសបំព្រួញការហូរខ្ទុះពីបង្ហូរនោម ករណីមិនធូរស្រាល/រើឡើងវិញ






# ការរលាកបង្ហូរនោម (Urethritis)

- ជម្ងឺនេះបង្កឡើងដោយ gonococcal និង non gonococcal
- បែបផែននៃការចំលង: តាមទ្វារមាស, រន្ធគូទ និង មាត់-ប្រដាប់បន្តពូជ (oral-sex)
- រោគសញ្ញានៃការរលាកបង្ហូរនោមរួមមាន:

  -ហូរខ្ទុះចេញពីបង្ហូរនោម (urethral discharge)

  -នោមឈឺផ្សា-ក្រហាយ (dysuria)

  -រមាស់តាមបង្ហូរនោម (meatal pruritus)

## ការរលាកបង្ហួរនោមដែលមិនមែនមេរោគហ្គូណូកុក (non gonococcal urethritis)

### មូលហេតុដែលមានទូទៅនៃការចម្លងរោគ (common infectious etiologies):

- ជម្ងឺបង្កឡើងដោយមេរោគក្លាមីឌីយ៉ា មាន ២០-៤០ ភាគរយ (C.trachomatis causes 20-40 % )
- ជម្ងឺបង្កឡើងដោយមេរោគមីកូប្លាស្មា និងយូរៀលប្លាស្មាមាន ១០-២០ភាគរយ (mycoplasma genitalium and ureaplasma urealyticum causes 10-20%)
- ជម្ងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ មានតិចជាង ០៥ ភាគរយ (trachomonas vaginalis causes <5% )
- ជម្ងឺបង្កឡើងដោយអែរប៉េស មានតិចជាង ០៥ ភាគរយ (HSV causes <5% )
- ផ្សេងៗ/មិនដឹងច្បាស់ មាន ២០-៣០ ភាគរយ (other/unknown causes 20-30% )



## រោគសញ្ញាគ្លីនិកនៃការរលាកបង្ហួរនោម (Urethritis clinical feature NGU vs GU)

| លក្ខណៈ (characteristic) | NGU | GU |
|---|---|---|
| រយៈពេលបង្ករោគ (incubation) | ៥-១៤ថ្ងៃ | ២-៦ថ្ងៃ |
| ចាប់ផ្តើម (onset) | បន្តិចម្តងៗ (gradual) | ភ្លាមៗ (abrupt) |
| នោមឈឺផ្សាក្រហាយ | មិនសូវធ្ងន់ធ្ងរ (mild) | ធ្ងន់ធ្ងរ (severe) |
| ការហូរខ្ទុះ (discharge) | រំអិលថ្លា (mucoid) | ខ្ទុះ (purulent) |





Non gonococcal Urethritis



Gonococcal Urethritis



## ការធ្វើរោគវិនិច្ឆ័យជម្ងឺរលាកបង្ហួរនោម

**ដើម្បីបញ្ជាក់ថាអ្នកជម្ងឺមានការរលាកបង្ហួរនោមយ៉ាងហោចណាស់ត្រូវមាន ០២ លក្ខណៈ ក្នុងចំណោមលក្ខណៈ ពិសេស ០៣ ខាងក្រោម:**

១- រោគសញ្ញាៈ មានប្រវត្តិហូរខ្ទុះចេញពីបង្ហួរនោម និង /ឬ នោមឈឺផ្សារក្រហាយ (history of urethral discharge or dysuria )

២- ការពិនិត្យៈ មានខ្ទុះ ឬ រំអិលលាយខ្ទុះ ឬ រំអិល ហូរចេញពីបង្ហួរនោម (presence purulent, muco-purulent, or mucoid discharge )

**តេស្តមន្ទីរពិសោធន៍ តែមួយគឺគ្រប់គ្រាន់**

១- ការបំពាក់ពិណក្រាមលើសារធាតុសរីរៈចេញពីបង្ហួរនោម លទ្ធផលបង្ហាញ គោលិកា ស លើស ០៥ ក្នុងមួយរង្វង់មីក្រូទស្សន៍ (>5WBCs per oil immersion field) ឬ

២- ការពិនិត្យទឹកនោម លទ្ធផលបង្ហាញ គោលិកា ស លើស/ឬស្មើ ១០ក្នុងមួយ រង្វង់មីក្រូទស្សន៍ (≥10WBCs per oil immersion field, test on first void urine )

# ការធ្វើរោគវិនិច្ឆ័យជម្ងឺរលាកបង្ហូរនោម

រោគវិនិច្ឆ័យមូលហេតុគឺត្រូវផ្អែកទៅលើការធ្វើតេស្តរកមេរោគហ្គោណូកូក និង ក្លាមីឌីយ៉ា (GC & CT tests)



Intacellular Gram-negative diplococci (GNDC) in urethral Gram stain



Non gonococcal Urethral Gram stain with >5 WBCs per high power



# ការពិនិត្យប្រដាប់បន្តពូជចំពោះជម្ងឺរលាកបង្ហូរនោមដែលបណ្តាលមកពីមេរោគហ្គូណូកូក

- បង្ហូរនោមឡើងក្រហម និង មានការឈឺចាប់ (Erythematous and tender)
- បន្ទាប់ពីច្បូតបង្ហូរនោម ឃើញមានហូរខ្ទុះច្រើនចេញពីបង្ហូរនោម (corpious purulent discharge is evident after stripping the urethra)







# រោគវិនិច្ឆ័យ និងសញ្ញាគ្លីនិក ជម្ងឺប្រមេះទឹកបាយនៅលើបុរស

- រយៈពេលបង្ករោគ: ២-៦ថ្ងៃ
- ហូរខ្ទុះពីបង្ហូរនោម (urethral discharge)
- នោមឈឺផ្សារ-ក្រហាយ (dysuria)
- សញ្ញាគ្លីនិកផ្សេងៗទៀតដូចជា: រលាកភ្នែកមានខ្ទុះ, រលាកចុងពោះវៀនធំ, រលាកបំពង់ក (purulent conjunctivitis, proctitis, pharyngitis)
- លទ្ធផលនៃការធ្វើរោគវិនិច្ឆ័យនៅលើបុរស:

  - Sensitive ៩៥ភាគរយ ចំពោះអ្នកជម្ងឺដែលមានរោគសញ្ញា (symptomatic males)

  - Sensitive ៥០-៧០ ភាគរយ ចំពោះអ្នកជម្ងឺដែលមិនមានរោគសញ្ញា (asymptomatic males)

  - ការបណ្តុះមេរោគ Sensitive ៨០-៩៥ភាគរយ

  - ការធ្វើតេស្ត Gen-probe sensitive ៩០-៩៥ភាគរយ



# ជម្ងឺប្រមេះទឹកបាយនៅលើបុរស

- រលាកបង្ហូរនោម (urethritis)
- រលាកអេពីឌីឌីម (epididymitis)
- រលាកចុងពោះវៀនធំ (Proctitis)
- រលាកភ្នែក (conjunctivitis)
- កើតបូសនៅលើក្រពេញ Tyson (abscess of Tyson's gland)
- រលាកបំពង់ក (pharyngitis)
- តៀ្បតបង្ហូរនោម (urethral stricture)
- ហើមលឹង្គ (penile edema)
- ការសាយភាយមេរោគហ្គោណូកូក (DGI 90% arthritis+/- dermatitis)
- ជួនកាលមិនស្តែងចេញជារោគសញ្ញា (infection may be asymptomatic)



DGI Skin Lesion



# ជម្ងឺប្រមេះទឹកថ្លានៅលើបុរស

- រយៈពេលបង្ករោគៈ ១- ៥សប្តាហ៏ (ជាមធ្យម ២សប្តាហ៏)
- រលាកបង្ហួរនោម (urethritis)
- រលាកអេពីឌីឌីម (epididymitis)
- រលាកចុងពោះវៀនធំ (Proctitis)
- រលាកភ្នែក (conjunctivitis)
- ជម្ងឺ Reiter's syndrome
- ជាង ៥០ភាគរយ មិនស្តែងចេញជារោគសញ្ញា (>50% asymptomatic)



ជម្ងឺ Reter's syndrome circinate Balanitis



# រោគសញ្ញាគ្លីនិកនៃជម្ងឺប្រមេះទឹកថ្លានៅលើបុរស

- រលាកបង្ហួរនោម (urethritis)
- ហូរទឹករំអិលខាប់ឬថ្លា (clear or mucoid discharge) ចេញពីបង្ហួរនោម
- នោមឈឺផ្សារ-ក្រហាយ (dysuria)
- រមាស់/ក្រហាយនៅតាមបង្ហួរនោម (itching/irritation at the meatus)
- អាចមិនស្តែងចេញជារោគសញ្ញា (May be asymptomatic)





# ការព្យាបាលការហូរខ្ទុះតាមបង្ហួរនោម

*១-ការព្យាបាលជំងឺរលាកបង្ហួរនោមបង្កដោយ Gonorrhoea*

ជំរើសទី១: Cefixime 400 mg លេបតែមួយដង **ឬ**

ជំរើសទី២: Spectinomycin 2g ឬ Ceftriaxone 250mg ចាក់សាច់ដុំតែម្តង

**រួមជាមួយនឹងៈ**

*២-ការព្យាបាលជំងឺរលាកបង្ហួរនោមបង្កដោយមេរោគ Chlamydia*

ជំរើសទី១: **-Azythromycine 1 g** លេបតែម្តង គត់ **ឬ**

-Doxycycline 100mg លេប២ ដង ក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ទៅ ១៤ថ្ងៃ

ជំរើសទី២: Erythromycin 500mg លេប៤ ដង ក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ។

**កំណត់សំគាល់:** ក្នុងករណីភាគច្រើនការផ្តល់ឱសថ Doxycycline រយៈពេល ៧ថ្ងៃ ជាការគ្រប់គ្រាន់ សំរាប់ព្យាបាលជំងឺរលាកបង្ហួរនោមដែលបង្កដោយមេរោគ Chlamydia ។



# ការព្យាបាលជម្ងឺបង្កឡើងដោយមេរោគហ្គោណូកុក និងក្លាមីឌីយ៉ា

*១-ការព្យាបាលដៃគូរួមភេទ*

គ្រប់ដៃគូរួមភេទ (៣ខែកន្លងទៅ) របស់អ្នកជម្ងឺហូរខ្ទុះតាមបង្ហួរនោមត្រូវទទួលការ ព្យាបាលជម្ងឺបង្កឡើងដោយ **មេរោគហ្គោណូកូក និងក្លាមីឌីយ៉ា** ។

***២-ការពិនិត្យវិនិច្ឆ័យពិសេសចំពោះអ្នកជម្ងឺមានមេរោគអេដស៍***

ការរលាកបង្ហួរនោមដោយមេរោគហ្គោណូកូក,ក្លាមីឌីយ៉ា និង non gonococcal ងាយសំរួលក្នុងការចំលងមេរោគអេដស៍ ។ អ្នកជម្ងឺដែលមានជម្ងឺ gonococcal, non gonococcal ហើយមាន មេរោគអេដស៍ ត្រូវទទួលការព្យាបាលដូចគ្នានឹងអ្នកដែលគ្មានមេរោគអេដស៍ដែរ ។

# ការព្យាបាលការហូរខ្ទុះតាមបង្ហូរនោមក្នុងករណីមិនធូរស្រាល/សើរើឡើងវិញ

*១-ការព្យាបាលជំងឺរលាកបង្ហូរនោមបង្កដោយ Trichomonas*

ជំរើសទី១: Metronidazole 2g លេបតែមួយដង **ឬ**

ជំរើសទី២: Tinidazole 2g លេបតែមួយដង

**រួមជាមួយនឹង:**

*២-ការព្យាបាលជំងឺរលាកបង្ហូរនោមបង្កដោយមេរោគ non gonococcal*

Erythromycin 500mg លេប៤ ដង ក្នុងមួយថ្ងៃ រយះពេល ៧ថ្ងៃ។

# ម៉ូឌុលទី ៣.២

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ដំបៅលើប្រដាប់បន្តពូជ

**(GENITAL ULCER)**



## វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ដំបៅ/ពងបែកលើប្រដាប់បន្តពូជ



## ដំបៅលើប្រដាប់បន្តពូជ

- ជម្ងឺស្វាយ (syphilis)
- ជម្ងឺឆ័នក្រយ (chancroid)
- ជម្ងឺអ៊ែកប៉ែស (Herpes simplex)
- ជម្ងឺ ហើមគ្រលៀន (Lymphogranuloma venereum)
- ការឆ្លងមេរោគអេដស៍ដំណាក់កាលដំបូង (Primary HIV infection)
- មូលហេតុផ្សេងៗទៀតដែលមិនមែនជម្ងឺកាមរោគ (many non STD etiologies)





## ជម្ងឺដំបៅលើប្រដាប់បន្តពូជ

**រូបសាស្ត្រនៃដំបៅ** (ulcer morphology)

- ចំនួន : តែមួយ ឬច្រើន (single or multiple)
- ជំរៅ: រាក់ ឬ ជ្រៅ (shallow or deep)
- គែម: ស្មើ ឬរនេងរនួញ (smooth or ragged)
- ភាពក្រិន: ណែន ឬទន់ (firm or soft)




- សារធាតុដែលជ្រាប : បាតស្អាត ឬមានខ្ទុះ (clean based or purulent )
- ការឈឺចាប់: ឈឺចាប់ខ្លាំង ឬ មិនឈឺចាប់ (painful or painless)
- កូនកណ្តុរគ្រលៀន: នៅតែមួយកន្លែង ឬ ពាសពេញខ្លួន (regional or generalized)

# គំនូសបំព្រួញសំរាប់ដំបៅលើប្រដាប់បន្តពូជ

## (គ្មានតេស្តមន្ទីរពិសោធន៍)






# គំនូសបំព្រួញសំរាប់ដំបៅលើប្រដាប់បន្តពូជ

## (មានតេស្តមន្ទីរពិសោធន៍)






# ការព្យាបាលដំបៅលើប្រដាប់បន្តពូជ (១)

## ១- <u>ការព្យាបាលជំងឺស្វាយ</u> <u>(syphilis) :</u>

– Banzathine Penicillin G 2,4 លាន IU ចាក់សាច់ដុំតែម្តង **ឬ**

***<u>ចំពោះអ្នកជំងឺដែលពុំអាចប្រើថ្នាំ Penicillin បានសូមប្រើ:</u>***

– Doxycycline 100mg លេបពីរដងក្នុងមួយថ្ងៃ រយៈពេល ១៤ ថ្ងៃ **ឬ**

– Tetracycline 500mg លេប៤ ដងក្នុងមួយថ្ងៃ រយៈពេល ១៤ ថ្ងៃ **ឬ**

– Erythromycin 500mg លេប៤ ដងក្នុងមួយថ្ងៃ រយៈពេល ១៤ ថ្ងៃ ។

**រួមជាមួយនឹង**



# ការព្យាបាលដំបៅលើប្រដាប់បន្តពូជ (២)

**រួមជាមួយនឹង** ☟

## ២- <u>ការព្យាបាលជំងឺ Chancroid:</u>

– Azithromycin 1g លេបតែ ១ ដងគត់ **ឬ**

– Ciprofloxacin 500mg លេប ១គ្រាប់ម្តង១ថ្ងៃ២ ដង រយៈពេល ៣ថ្ងៃ **ឬ**

– Erythromycin 500mg លេប៤ ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ **ឬ**

– Ceftriaxone 250mg ចាក់សាច់ដុំតែម្តងគត់ ។

**<u>ចំណាំ :</u>** ហាមប្រើ **Ciprofloxacin, Doxycycline** នៅពេលមានផ្ទៃពោះ ឬ បំបៅដោះ ។

# ការព្យាបាលជំងឺដំបៅពងបែកនៅលើប្រដាប់បន្តពូជ (៣)

**ការព្យាបាលជំងឺដំបៅពងបែកលើប្រដាប់បន្តពូជដំណាក់កាលដំបូង (Herpes primary episode)**

- លាងសំអាតដំបៅជាមួយទឹកសាប៊ូ ដើម្បីរក្សាឱ្យកន្លែងនោះស្អាត ហើយស្ងួត ឬ
- លាប Gentian violet 0.5% ២ ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ
- Acyclovir 200mg លេប៥ ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ
- Acyclovir 400mg លេប៣ ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ
- Famciclovir 250mg លេប៣ ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ
- Valaciclovir 1000mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ





# ការព្យាបាលជំងឺដំបៅពងបែកនៅលើប្រដាប់បន្តពូជ (៣)

**ការព្យាបាលជំងឺដំបៅពងបែកលើប្រដាប់បន្តពូជដំណាក់កាលសើរើឡើងវិញ (Herpes recurrent episode)**

- Acyclovir 200mg លេប៥ ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ ឬ
- Acyclovir 400mg លេប៣ ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ ឬ
- Acyclovir 800mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ ឬ
- Famciclovir 125mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ ឬ
- Valaciclovir 500mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ ឬ
- Valaciclovir 1000mg លេប១ ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ ឬ





# ការព្យាបាលជំងឺដំបៅពងបែកលើប្រដាប់បន្តពូជ ប្រចាំថ្ងៃដើម្បីកាត់បន្ថយសកម្មភាពមេរោគ ចំពោះអ្នកជំងឺ HIV

- Acyclovir 400mg-800mg លេប២-៣ ដងក្នុងមួយថ្ងៃ

ឬ

- Famciclovir 500mg លេប២ ដងក្នុងមួយថ្ងៃ

ឬ

- Valaciclovir 500mg លេប២ ដងក្នុងមួយថ្ងៃ



# ការព្យាបាលជំងឺដំបៅពងបែកលើប្រដាប់បន្តពូជ ក្នុងដំណាក់កាលលេចចេញរោគសញ្ញា ចំពោះអ្នកជំងឺ HIV

- Acyclovir 400mg-800mg លេប០៣ ដងក្នុងមួយថ្ងៃ រយៈពេល៥-១០ថ្ងៃ

ឬ

- Famciclovir 500mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល៥-១០ថ្ងៃ

ឬ

- Valaciclovir 1000mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល៥-១០ថ្ងៃ

## ការគ្រប់គ្រងថែទាំដៃគូរួមភេទចំពោះដំបៅលើប្រដាប់បន្តពូជ

- គ្រប់ដៃគូរួមភេទរបស់អ្នកជម្ងឺ (៣ខែកន្លងទៅ) ត្រូវផ្តល់ការព្យាបាល ជម្ងឺស្វាយ និង chancroid (ឬ ព្យាបាលជម្ងឺហើមក្រលៀន បើសិនជាកន្លែងនោះមានអេពីឌីមីសាស្ត្រ) ។



## ជម្ងឺស្វាយ (Syphilis)

- បង្កឡើងដោយ treponema pallidum
- ពពួក Spirochete ឆ្លងតាមរយៈការដាច់រលាត់ penetrates through abrasions.
- ការចំលងគឺតាមរយៈការរួមភេទ និងពីម្តាយទៅកូន (កូននៅក្នុងស្បូន ឆ្លងមេរោគពីម្តាយ តាមរយៈឈាមរបស់ម្តាយបញ្ជូនទៅកូន)
- ដែលចំលងជាងគេស្វាយតំណាក់កាលទី១ និងដំណាក់កាលទី២
- មិនមានការចំលងក្រោយពីកើតបានរយៈពេល៤ឆ្នាំ



*មេរោគ Treponema pallidum*





Early lesion-4wks



Healing 4-5 wks




> 5 wks







Photos courtesy Region III PTC

> 6 weeks

## ជម្ងឺស្វាយដំណាក់កាលទី១ (Primary syphilis)

- **ដំបៅ** (chancre)

  - ៩-៩០ថ្ងៃ បន្ទាប់ពីឆ្លងរោគ ជាមធ្យម០៣សប្តាហ៍

  -ជាទូទៅ dark field វិជ្ជមាន.

  -៧៤-៨៧ ភាគរយ VDRL/RPR sensitive បើសិន មានសញ្ញាគ្លីនិកបង្ហាញត្រូវធ្វើតេស្ត FTA-ABS ឬ TP-PA ។

  -ដំបៅអាចស្ថិតនៅរយៈពេល ២-៣សប្តាហ៍

- **តំបន់កណ្តុរក្រលៀនៈ** ទន់, មិនឈឺ, លេចចេញទាំងសង



ដំបៅជម្ងឺស្វាយដំណាក់កាលទី១ លេចចេញនៅលើគនាក់ក្បាលលឹង្គ (corona)

## ជម្ងឺស្វាយដំណាក់កាលទី១ (Primary syphilis)



Primary Syphilis Clearly Indurate Ulcer



Penile Lesions Resembling Herpes



Multiple Vulvar Chancres



Crusting Ulcer on Penile Glans



## ជម្ងឺស្វាយដំណាក់កាលទី១ (Primary syphilis)



Chancre on Chin



Chancre on Tongue



Digital Chancre



## ជម្ងឺស្វាយដំណាក់កាលទី២ (Secondary syphilis)

- លេចចេញរយៈ ៣-៦ បន្ទាប់ពីស្វាយដំណាក់កាលទី១, ជម្ងឺមានការបាចសាច (disseminated disease) និងមាន រោគសញ្ញាជាច្រើន ស្នាមកន្ទួល (៧៥-៩០ភាគរយ): macular, papular, squarmous (multiple signs)
- ជាទូទៅអត់រមាស់ (៦០ភាគរយ នៅបាតដៃ និងបាតជើង)
- កូនកណ្ដុរកើតពាសពេញ ៧០-៩០ភាគរយ (generalized adenopathy)
- រោគសញ្ញា: ល្វិតល្វៃដៃជើង, ក្ដៅខ្លួន, ឈឺចាប់តាមសាច់ដុំ ។

  Mucous patches (៥-៣០ ភាគរយ) ជាស្នាមបន្ទះ សំប៉ែតមាននៅក្នុងប្រហោងមាត់ (oral cavity) បំពង់ក ១ផហារយនខច ដើមបំពង់ខ្យល់ (larynx) និងប្រដាប់បន្តពូជ (genital)



## ជម្ងឺស្វាយដំណាក់កាលទី២ (Secondary syphilis)

- Condylomata lata (៥ - ២៥ភាគរយ) មានលក្ខណៈ សើម. គរលើគ្នា ដូច warts ដែលកើតមាន នៅលើតំបន់ warm intertriginous (ផ្នត់កំប៉េះគូទ) perineum, perianal ដែលជា កន្លែងត្រប៉ូណែម បង្ករោគ ។
- ទំពែកក្បាល (alopecia) (១០-១៥ ភាគរយ) នៅកន្លែងកណ្ដាលក្បាល និងលើស្បៀតផ្កា ទាំងសងខាង ជ្រុះរោមចិញ្ចើមខាងៗ ។
- សេរ៉ូឡូស៊ីតេស្ដ វិជ្ជមាន





## Condyloma Lata នៃជំងឺស្វាយដំណាក់កាលទី២








## ស្នាមកន្ទួលជំងឺស្វាយដំណាក់កាលទី២ (Rash of Secondary Syphilis)



Macular &Papulosquamous Rash



Hyperpigmented macules






## Mucous Patches នៃជំងឺស្វាយដំណាក់កាលទី២

- មិនឈឺ (painless), បន្ទះសំប៉ែត ពណ៌ ស ឬ ក្រហម (flat, white or red patches)
- លេចចេញស្រទាប់ភ្នាសមុយកឺនៅលើមាត់ pharynx,larynx, និងប្រដាប់បន្តពូជ ។
- សំបូរទៅដោយពពួក spirochetes;ដែលមានការចំលងខ្លាំង ។






## ជំងឺស្វាយដំណាក់កាលសំងំ (Latent Syphilis)

**បែងចែកជាពីរដំណាក់កាល**

- .ដំណាក់កាលសំងំថ្មី (early latent) មានរយៈពេលតិចជាងមួយឆ្នាំ
- .ដំណាក់កាលសំងំយូរ (late latent) មានរយៈពេលលើសពី១ឆ្នាំ ឬមិនដឹងរយៈពេល
- គ្មានរោគសញ្ញាគ្លីនិក : សេរ៉ូឡូស៊ីតេស្តវិជ្ជមាន តែមួយគត់
- ការលាប់ឡើងវិញ នៃដំបៅដំណាក់កាលទី២មានរហូតទៅដល់២៥ភាគរយនៃករណី ដែលជាធម្មតាមាន នៅឆ្នាំដំបូង ។

# ជម្ងឺស្វាយដំណាក់កាលទី៣ (Tertiary Syphilis)

.អ្នកជម្ងឺដែលមិនបានព្យាបាល ៣០ភាគរយ នឹងវិវត្តទៅរកជម្ងឺ:

- .ប្រព័ន្ធសរសៃប្រសាទកណ្តាល ( ច្រើនខែ-ច្រើនឆ្នាំ)
- បេះដូង : ការប៉ោងសរសៃ aort ( aortic aneverysm) ជាមធ្យមរយ:ពេល ១៥-៣០ឆ្នាំ បន្ទាប់ពីឆ្លង ។
- ឆ្អឹង និងជាលិកា: ដំបៅរលួយ (gummatous lesion) ជាមធ្យមរយ:ពេល១០-៤០ឆ្នាំបន្ទាប់ពីឆ្លង



# គំនូសបំព្រួញស្តីពីដំណាក់កាលនៃស្វាយ






# ការធ្វើរោគវិនិច្ឆ័យនៃជម្ងឺស្វាយ (Diagnosis of Syphilis)

**ប្រវត្តិជម្ងឺ** (History)

- ប្រវត្តិនៃជម្ងឺស្វាយ (history of syphilis)
- ដឹងថាមានការប៉ះពាល់ជម្ងឺស្វាយថ្មីៗ (known contact to an early case of syphilis)
- លេចចេញសញ្ញា ឬ មានរោគសញ្ញានៃជម្ងឺស្វាយក្នុងរយ:ពេល១២ខែកន្លងមក
- តេស្តសេរ៉ូមស្វាយ (serologic test syphilis)

**ការពិនិត្យរាងកាយ:** (Physical examination)

- មាត់ (oral cavity)
- កូនកណ្តុរ (lymph nodes)
- ស្បែកដងខ្លួន (skin of torso)
- បាតដៃ និងបាតជើង (palms and soles)



# ការធ្វើរោគវិនិច្ឆ័យនៃជម្ងឺស្វាយ (Diagnosis of Syphilis)

**មន្ទីរពិសោធន៍** (Laboratory)

- កំណត់រកមេរោគ treponema នៅនឹងដំបៅដោយផ្អែកលើការធ្វើតេស្ត darkfield
- តេស្តសេរ៉ូម (serological test)

**តេស្ត** Darkfield

- ត្រូវការបណ្តុះបណ្តាលបុគលិក និងមីក្រូទស្សន៍ពិសេស
- ការធ្វើរោគវិនិច្ឆ័យរហ័សសំរាប់ស្វាយដំណាក់កាលទី១

**តេស្តសេរ៉ូម**

- តេស្ត nontreponema (RPR, VDRL)
- តេស្ត treponema (TP-PA, FTA-ABS)

## តេស្ត nontreponema (VDRL, RPR) សំរាប់ជម្ងឺស្វាយ

- .រក anticardiolipin Abs មិនមែន specific សំរាប់ ត្រេប៉ូណេម៉ាប៉ាលីដូម
- .លឿន, តំលៃថោក និងសិក្សា quantitative （អាចប្រើសំរាប់តាមដានការព្យាបាល）
- មានលក្ខណៈ biological false positive ឃើញក្នុងករណី viral illnesses, vaccinations, autoimmune disease, chronic diseases.
- អាចអវិជ្ជមាននៅក្នុងដំណាក់កាលដំបូង (primary). ដំណាក់កាលសំងំយូរ (late latent) និង .ដំណាក់កាលទី៣ (tertiary dusease) ។



## តេស្ត treponema សំរាប់ជម្ងឺស្វាយ

- .មានលក្ខណៈ specific សំរាប់ ត្រេប៉ូណេម៉ាប៉ាលីដូម
- .សំរាប់វាស់អង្គបដិបក្ខប្រាណ (IgM & IgG) ផ្ទាល់ទៅនឹងអតិសុខុមប្រាណ (antigens) របស់មេរោគត្រេប៉ូណេម៉ាប៉ាលីដូម តាមរយៈ hemaglutination (TP-PA) ឬ immunofluorescence (FTA-ABS)
- តេស្តជាក់លាក់ (specificity test) ផ្អែកទៅលើការលាយសេរ៉ូម (serum dilution) និងការបឺត (absorption)
- មានសារៈសំខាន់ក្នុងការបញ្ជាក់តេស្ត non treponemaវិជ្ជមាន



## តេស្តសេរ៉ូមណាមួយដែលល្អសំរាប់ជម្ងឺស្វាយ

### (sensitivity ផ្អែកទៅលើដំណាក់កាលនិមួយៗ)

| ភាគរយវិជ្ជមាននៃដំណាក់កាលជំងឺ (stage of disease of percentage positive) | | | | |
|---|---|---|---|---|
| តេស្ត (test) | ដំណាក់កាលដំបូង (Primary) | ដំណាក់កាលទី២ (Secondary) | ដំណាក់កាលសំងំ (Late) | ដំណាក់កាលទី៣ (Tertiary) |
| RPR/VDRL | 78% (74-87) | 100% | 95% (88-100) | 71% (37-94) |
| FTA-Abs | 84% (70-100) | 100% | 100% | 96% |
| TP-PA | 84% (84-100) | 100% | 100% | ប្រហាក់ប្រហែល FTA-Abs |



## ការតាមដាន និងការឆ្លើយតបសេរ៉ូមតេស្តនៃជម្ងឺស្វាយ

- .ស្វាយតំណាក់កាលទី១ និងទី២ ត្រូវពិនិត្យឡើងវិញ នៅ ៦ខែ និង១២ខែ, សេរ៉ូមធ្លាក់ចុះ៤ដងក្នុងកំឡុង ៦ខែ ។
- ស្វាយតំណាក់កាលសំងំ ត្រូវពិនិត្យឡើងវិញ នៅ ៦ខែ និង១២ខែ និង២៤ខែ, សេរ៉ូមធ្លាក់ចុះ៤ដងក្នុងកំឡុង ១២ខែ និង ២៤ខែ ។
- អនុសាសន៍នៅលើអ្នកមានផ្ទុកមេរោគអេដស៍ត្រូវតាមដានឱយបានទៀងទាត់.

  -ស្វាយតំណាក់កាលទី១ និងទី២ ត្រូវពិនិត្យឡើងវិញ នៅ ៣ខែ, ៦ខែ, ៩ខែ, ១២ខែ និង២៤ខែ, សេរ៉ូមធ្លាក់ចុះ៤ដងក្នុងកំឡុង ៦ខែ និង១២ខែ។

  -ស្វាយតំណាក់កាលសំងំ ត្រូវពិនិត្យឡើងវិញ នៅ ៦ខែ និង១២ខែ និង២៤ខែ, សេរ៉ូមធ្លាក់ចុះ៤ដងក្នុងកំឡុង ១២ខែ និង ២៤ខែ ។

# ជម្ងឺស្វាយនៅលើស្ត្រីមានផ្ទៃពោះ

- អត្រានៃការចំលងទោតាមដំណាក់កាលជម្ងឺរបស់ម្តាយ:

  - តំណាក់កាលទី១: ៧០-១០០ភាគរយ

  -តំណាក់កាលទី២: ៩០ភាគរយ

  -តំណាក់កាលសំងំ: ១០-៣០ភាគរយ

- លទ្ធផលនៃជម្ងឺស្វាយតំណាក់កាលថ្មីៗដែលមិនបានព្យាបាល:

  -២៥ភាគរយស្លាប់នៅក្នុងស្បូន

  -២៥ភាគរយស្លាប់ មុន និងក្រោយសំរាល

  -៥០ភាគរយស្វាយពីកំណើត (៥០ភាគរយគ្មានរោគសញ្ញា)



# ផលវិបាកជម្ងឺស្វាយ

- រលូតកូន ឬទារកក្រោយពេលសំរាល
- ជម្ងឺស្វាយពីកំណើតនៅលើទារក:

  - ឆ្អឹង: រលាកឆ្អឹងខ្ចី, រលាកស្រទាបឆ្អឹង, ប៉ះពាល់ទៅលើធ្មេញ

  -ភ្នែក: ប៉ះពាល់ទៅលើ retina និង cornea

  -អាការ:ខាងក្នុង: ថ្លើម, កណ្តើក

  -ស្បែក: ស្នាមកន្ទួល

  -ប្រព័ន្ធសសៃប្រសាទកណ្តាល: ស្ពឹកទូទៅ, ថ្លង់, ការដើរដំណើរ មិនត្រូវចង្វាក់ ហើយមានការឈឺចាប់-នោមអត់ដឹង ( tabes) .



# ការគ្រប់គ្រងបុគ្គលដែលប៉ះពាល់ជាមួយជម្ងឺស្វាយ

- គ្រប់ដៃគូរួមភេទដែលត្រូវស្ថិតនៅក្នុងដំណាក់កាលតាមដាន:

  -ស្វាយតំណាក់កាលទី១: ៩០ថ្ងៃ រួមជាមួយរយ:ពេលនៃការលេចចេញរោគសញ្ញា

  -ស្វាយតំណាក់កាលទី២: ខែ រួមជាមួយរយ:ពេលនៃការលេចចេញរោគសញ្ញា

  -ស្វាយតំណាក់កាលសំងំថ្មី: ១ឆ្នាំ
- ដៃគូរួមភេទរបស់អ្នកជម្ងឺដែលមិនដឹងរយះពេល និងមានលទ្ធផល titers $\geq 32$
- បុគ្គលដែលមានការប៉ះពាល់ ក្នុងរយ:ពេល៩០ថ្ងៃ មុនការធ្វើរោគវិនិច្ឆ័យជម្ងឺស្វាយតំណាក់កាលសំងំថ្មី ត្រូវទទួលការព្យាបាលដោយសន្ទត់
- បុគ្គលដែលមានការប៉ះពាល់ លើសពីរយ:ពេល៩០ថ្ងៃ មុនការធ្វើរោគវិនិច្ឆ័យ ជាជម្ងឺស្វាយ ដំណាក់កាលសំងំថ្មី ដៃគូរបស់អ្នកជម្ងឺត្រូវទទួលការព្យាបាលដោយ សន្ទត់  បើសិនជាតេស្តសេរ៉ូមមិនអាចធ្វើបានភ្លាមៗ និងមិនមានឱកាសមកតាមដាន ។
- បុគ្គលដែលមានដៃគូរួមភេទកើតស្វាយយូរអង្វែងត្រូវធ្វើការតាមដាន



# រោគសញ្ញាគ្លីនិកនៃជម្ងឺ Chancroid

- បង្កឡើងដោយបាក់តេរី Haemophilus ducreyi
- រយ:ពេលបង្ករោគ ពី ០៣ ទៅ១០ថ្ងៃ
- ចាប់ផ្តើមឡើងដោយដំបៅដែលមានលក្ខណ: ទន់ (soft), ឈឺ (painful) និងមានបាត រលួយ (necrotic base)
- អម ទៅដោយកូនកណ្តុរក្រលៀនដែលឈឺ និងអាចករខ្ទុះជាទំរង់ bubo



Multiple penile ulcer





## លក្ខណៈ bubo នៃជំងឺ Chancroid

- ជួបប្រទះ ៤០-៥០ភាគរយ ករណី (40-50% of cases)
- កូនកណ្ដុរ bubo បង្កឡើងជាទំរង់ pyogenic inflammatory
- ករខ្ទុះ និង ពេលប៉ះមានលក្ខណៈទន់ហើយឈឺ (suppurative and tender)
- ញឹកញាប់ជា sterile abscess



## រោគវិនិច្ឆ័យនៃជំងឺ Chancroid

- ការបំពាក់ពិណក្រាមមាន sensitivity មានកំរិតទាប
- ក្រាមអវិជ្ជមានដែលមានរូបរាងជា railroad tie
- ការបណ្ដុះមេរោគ: sensitivity មានកំរិត៤០-៨០ភាគរយ
- រោគវិនិច្ឆ័យគ្លីនិក: វត្តមាន bubo រួមជាមួយដំបៅលើប្រដាប់បន្តពូជដែលមានលក្ខណៈឈឺចាប់



## ការតាមដានសញ្ញាគ្លីនិកនៃជំងឺ Chancroid

- ពិនិត្យឡើងវិញក្នុងរយៈពេល ៣-៥ថ្ងៃ បន្ទាប់មកពិនិត្យរៀងរាល់សប្ដាហ៍រហូតដល់ដំបៅ និង bubo បាត់ទៅវិញ ។

  -ជាធម្មតាដំបៅបានធូរស្រាលក្នុងរយៈពេល៣-៧ថ្ងៃ បន្ទាប់ពីព្យាបាល
- ពេលព្យាបាលបាន១-២ថ្ងៃ បើកូនកណ្ដុរ buboវិវត្តទៅជាធ្ងន់ធ្ងរ នោះចាំបាច់ត្រូវធ្វើការបូមចេញ (need to aspirate) ។
- រយៈពេល៣ខែ ត្រូវធ្វើតេស្តស្វាយ និងតេស្តរកមេរោគអេដស៍ឡើងវិញ។
- អ្នកជម្ងឺអេដស៍ត្រូវការព្យាបាលរយៈពេលយូរ
- គ្រប់គ្រងដៃគូរួមភេទ: ព្យាបាលគ្រប់ដៃគូរួមភេទដែលបានប៉ះពាល់ក្នុងរយៈពេល១០ថ្ងៃកន្លងទៅរួមជាមួយរយៈពេលមានរោគសញ្ញា ។



## ដំបៅពងបែកលើប្រដាប់បន្តពូជ










## ជម្ងឺពងបែកលើប្រដាប់បន្តពូជ

- ពងបែកនៅលើប្រដាប់បន្តពូជ គឺជាជម្ងឺរ៉ាំរ៉ៃ ហើយ វីរុសបង្ករោគនៅក្នុងខ្លួនរហូតមួយជីវិត ។
- វីរុសចែកចេញជាពីប្រភេទ: ប្រភេទ ១ និងប្រភេទទី ២
- ការបង្ករោគបណ្តាលមកពី: primary, recurrent, subclinical ឬមិនមានរោគសញ្ញា
- ភាគច្រើនឆ្លងតាមការរួមភេទ ដែលជួបប្រទះក្នុងរយៈពេលសាយភាយវីរុសដោយគ្មានរោគសញ្ញា (asymptoms viral shedding)
- ការប្រើស្រោមអនាម័យអាចជួយកាត់បន្ថយការចំលងទៅដៃគូរួមភេទ ។



## ជម្ងឺពងបែកដំណាក់កាលដំបូងលើប្រដាប់បន្តពូជ (Primary Herpes)

- រយៈពេលបង្ករោគ: ៣-៤ថ្ងៃ
- រហូតទៅដល់ ៨០ភាគរយ ជាញឹកញាប់អ្នកជម្ងឺមាន: ក្តៅខ្លួន (fever) , ឈឺក្បាល (headache) , ល្ហិតល្ហៃដៃជើង (malaise) , ឈឺសាច់ដុំ (myalgia)
- រោគសញ្ញានៅនឹងកន្លែង (local symptoms) 95%មានការឈឺចាប់ (pain) រមាស់ (itching), 60% នោមឈឺផ្សារ-ក្រហាយ (dysuria), 85% ធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស (vaginal discharge), និង 80%ឈឺចាប់កូនកណ្តុរក្រលៀន
- ដំបៅនៅលើប្រដាប់បន្តពូជមានការឈឺចាប់ខ្លាំង និងឈឺទាំងសងខាង ( painful genital lesions bilaterial) គឺមានលក្ខណៈជាស្នាមកន្ទួលពងទឹក បន្ទាប់មក ដំបៅរលួយ (ulcer) និងឡើងក្រម៉ (crust)



Early Lesions



Crusted Lesions



## ការបង្ករោគសារចុះសារឡើងដោយគ្មានការព្យាបាល (recurrent infection without treatment)

- សញ្ញាដំបូង (prodromal symptoms) អ្នកជម្ងឺមានអារម្មណ៍ក្តៅក្រហាយឈឺឆៀបៗ នៅនឹងកន្លែង (localized tingling, irritation) ប្រហែលជា៥០ភាគរយ ចាប់ផ្តើមពី ១២-២៤ម៉ោងមុន ពេលមានដំបៅ (lesion) និងជួលកាលគ្មានដំបៅ (false prodrome) .
- រយៈពេលខ្លីជាងការបង្ករោគដំបូង (duration is shorter than primary infection)
- ជាមធ្យមរយៈពេលនៃការ សាយភាយវីរុស ៤ថ្ងៃ
- ជាទូទៅរោគសញ្ញាមិនច្បាស់លាស់
- ការកើតសារចុះសារឡើង ជាមធ្យម ២-៦ដងក្នុងមួយឆ្នាំ
- ពពួក HSV 2 primary infection គឺឆាប់កើតសារចុះសារឡើងជាង HSV 1 primary infection



## រោគវិនិច្ឆ័យជម្ងឺពងបែកលើប្រដាប់បន្តពូជ

- Sensitivity Viral culture សរុបគឺមានតែ៥០ភាគរយ
  - លទ្ធផលល្អប្រសើរ គឺ (primary, fresh lesions)
  - លទ្ធផលមិនល្អ គឺ (recurrence, old lesions)
- Antigen detection (DFA or EIA): 70-85% sensitive active lesions
- Cytology (Tzank or pap) nnsensitive (50%)
- Serologic test

# ជម្ងឺពងបែកលើប្រដាប់បន្តពូជនៅលើស្រ្តីមានផ្ទៃពោះ

- អត្រានៃតំណាក់កាលចំលងពីម្តាយទៅកូន
- ដំបូង (primary) នៅត្រីមាសទី៣ : ៥០ភាគរយ
- កើតសារចុះសារឡើង (recurrent) នៅពេលសំរាល: ០៤ ភាគរយ
- សាយភាយវីរុសដោយគ្មានរោគសញ្ញា (asymptoms viral shedding)  នៅពេលសំរាលតិចជាង ០១ភាគរយ
- ការគ្រប់គ្រងផ្ទៃទាំម្តាយដែលមានជម្ងឺពងបែកលើប្រដាប់បន្តពូជ

  -active lesions /prodrome noted prior to delivery: C- section

# ម៉ូឌុលទី ៣.៣

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ការធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស

## (VAGINAL DISCHARGE)



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ការធ្លាក់ ស ឬ ហូរខ្ទុះតាមទ្វារមាស



# ការធ្លាក់សធម្មតា

- សដែលធ្លាក់មក មាន សភាព ថ្លា (clear) ឬ ពិណ ស (white) និងគ្មានក្លិន (no bad odor)
- បរិមាណតិចតួចដែលហូរចេញមកមានប្រឡាក់ជាប់នឹងខោទ្រនាប់
- pH អាស៊ីតស្ថិតនៅចន្លោះ ៣.៨ ទៅ ៤.២
- អតិសុខុមប្រាណធម្មតាដែលរស់នៅក្នុងទ្វារមាស (normal vaginal microorganisms)

  - Lactobicillus species

  - Bacteroides urealyticus, Phaemolytic and non haemolytic streptococci, Candida albicans, Diphtheroids, Enterococci, Escherichiia coli, Fusobacterium nuc/eatum, Mobiluncus spp, Mycoplasma hominis, Micrococcus pyogenes, Peptostreptococcus spp, Prevotella bivia disiens, Staphylococcus epidermidis, and Ureaplasma urealyticum.



# ការធ្លាក់សមិនធម្មតា

- ទឹករំអិលច្រើនហូរចេញពីទ្វារមាស (vaginal hypersecretion) ដែលមិនទាក់ទងទៅនឹង មុនពេល ឬក្រោយពេលមករដូវ ទេ (not associated with pre-mid and post menstruation) ។
- ស មាន ក្លិនស្អុយ (malordorouse discharge)
- សពិណលឿង (yellowish) ⁄កក (curd) ⁄ពពុះ (frothy)
- ការធ្លាក់សមិនធម្មតាបណ្ដាលមកពីមានការបង្ករោគរួមមានៈ

  - N. gonorrhoeae

  -Chlamydia trachomatis

  -Trichomonas vaginalis

  -Candia albican

  -Anaerobic bacterial

# ភាពខុសគ្នារវាងជំងឺរលាកទ្វារមាស និង ជំងឺរលាកមាត់ស្បូន

| ជំងឺរលាកទ្វារមាស | ជំងឺរលាកមាត់ស្បូន |
|---|---|
| • ជំងឺដែលបង្កដោយ Trichomonas, Candidas និងបាក់តេរី (bacterial vaginosis) | ◆ ជំងឺបង្កដោយ Gonorrhoea និង ជំងឺបង្កដោយ Chlamydia ។ |
| • ជាមូលហេតុញឹកញាប់ជាងគេ ដែលធ្វើ ឱ្យធ្លាក់ស | ◆ មិនមែនជាមូលហេតុញឹកញាប់ដែលបង្ក ឱ្យធ្លាក់ស ទេ |
| • ងាយធ្វើរោគវិនិច្ឆ័យ | ◆ ពិបាកធ្វើរោគវិនិច្ឆ័យ |
| • មិនចាំបាច់ព្យាបាលដៃគូរួមភេទទេ ចំពោះជម្ងឺដែលបង្កឡើងដោយ Candida និង bacterial vaginosis ។ | ◆ ចាំបាច់ត្រូវព្យាបាលដៃគូរួមភេទ ។ |



# គំនូសបំព្រួញសំរាប់ការធ្លាក់ ស/ហូរខ្ទុះចេញពីទ្វារមាស






# គំនូសបំព្រួញសំរាប់ការធ្លាក់ ស/ហូរខ្ទុះចេញពីទ្វារមាស






# គំនូសបំព្រួញស្តីពីការធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស ពិនិត្យដោយដៃទាំងពីរ,ចំពុះទា និង តេស្ត មន្ទីរពិសោធន៍ សំរាប់ស្ត្រីប្រឈមមុខទាប



## ការព្យាបាលជម្ងឺរលាកមាត់ស្បូន លុះណាតែ ៖

### កត្តាប្រឈមមុខនឹងគ្រោះថ្នាក់ "វិជ្ជមាន" ៖

១- អ្នកជម្ងឺត្អូញត្អែរថា ៖ ធ្លាក់ សពីណាលឿងខាប់ដូចខ្ទុះ (mucopurulent discharge)

២- ដៃគូរួមភេទរបស់អ្នកជម្ងឺ មានរោគសញ្ញាកាមរោគ (Partner has symptoms of STI)

"វិជ្ជមាន" លុះណាតែអ្នកជំងឺឆ្លើយយល់ស្របទៅនឹងសំនួរ ០១ ក្នុងចំណោមសំនួរទាំងនេះ ។

ដូច្នេះ គេត្រូវព្យាបាលជំងឺទាំងពីរ គឺ រលាកមាត់ស្បូន និងរលាកទ្វារមាស រួមគ្នាតែម្តង ។



## ការព្យាបាលជំងឺរលាកមាត់ស្បូន

១) ព្យាបាលជម្ងឺរលាកមាត់ស្បូនបង្កដោយមេរោគ Gonococcal:

ជំរើសទី១: **Cefixime 400mg** លេបតែ ១ ដងគត់

ជំរើសទី២: **Spectinomycin 2g** ឬ **Ceftriaxone 250mg** ចាក់សាច់ដុំតែ ១ ដងគត់ ។

រួមជាមួយនឹង

២) ព្យាបាលជម្ងឺរលាកមាត់ស្បូនបង្កដោយមេរោគ Chlamydia:

ជំរើសទី១: Azithromycin 1g លេប តែម្តងគត់ឬ

ជំរើសទី២: - **Doxycycline 100mg** លេប ២ ដង ក្នុងមួយថ្ងៃ រយះពេល ៧ ទៅ ១៤ ថ្ងៃ

- **Erythromycin 500mg** លេប ៤ ដង ក្នុងមួយថ្ងៃ រយះពេល ៧ ថ្ងៃ ។



## ការព្យាបាលជំងឺរលាកទ្វារមាស (១)

**១-ការព្យាបាលជំងឺដែលបង្កដោយ Trichomoniasis**

*ជំរើសទី១:*

- Metronidazole 2g *លេបតែមួយដង គត់ ក្រោមការត្រួតពិនិត្យរបស់ បុគ្គលិកសុខាភិបាល*
- Tinidazole 2g *លេបតែមួយដង គត់*

*ជំរើសទី២:*

- Metronidazole 500mg *លេប២ ដង ក្នុងមួយថ្ងៃ ក្នុងរយះពេល ៧ ថ្ងៃ*
- Tinidazole 500mg *លេប២ ដង ក្នុងមួយថ្ងៃ ក្នុងរយះពេល ៧ ថ្ងៃ*



## ការព្យាបាលជំងឺរលាកទ្វារមាស (២)

**១-ការព្យាបាលជំងឺដែលបង្កដោយ Bacterial vaginosis**

*ជំរើសទី១:*

- Metronidazole 500mg *លេប២ ដង ក្នុងមួយថ្ងៃ ក្នុងរយះពេល ៧ ថ្ងៃ*

*ជំរើសទី២:*

- Metronidazole 2g *លេបតែមួយដង គត់ ឬ*
- Clindamycin 300mg *លេប២ ដង ក្នុងមួយថ្ងៃ ក្នុងរយះពេល ៧ ថ្ងៃ ឬ*
- Metronidazole cream 0.75%, 5g *លាបទ្វារមាសមួយថ្ងៃ២ដងរយះពេល៥ថ្ងៃ ឬ*
- Clindamycin cream 2%, 5g *លាបទ្វារមាសពេលចូលគេងរយះពេល៧ថ្ងៃ*

*កំណត់សំគាល់ : ហាមប្រើជាតិអាល់កុលពេលពេលលេបឱសថ*Metronidazole

*ជាតិប្រេងនៅក្នុងក្រែមអាចធ្វើឱយខូចគុណភាពរបស់ស្រោមអនាម័យ ។*

# ការព្យាបាលជំងឺរលាកទ្វារមាស (៣)

**១-ការព្យាបាលជំងឺដែលបង្កដោយផ្សិត (Candida)**

*ជំរើសទី១:*

- Clotrimazole 500mg *ស៊ុលទ្វារមាសតែម្តងគត់ពេលយប់ ឬ*
- Miconazole or Clotrimazole 200mg *ស៊ុលទ្វារមាសមួយយប់ ១គ្រាប់រយៈពេល០៣យប់ ឬ*
- Fluconazole 150mg *លេប១គ្រាប់តែម្តងគត់*

*ជំរើសទី២:*

- Nystatin 200000IU *ស៊ុលទ្វារមាសមួយយប់ ១គ្រាប់រយៈពេល០៧យប់ ឬ*
- Nystatin 100000IU *ស៊ុលទ្វារមាសមួយយប់ ១គ្រាប់រយៈពេល១៤យប់ ឬ*



# ការគ្រប់គ្រងថែទាំដៃគូរួមភេទ

១-គ្រប់ដៃគូរួមភេទរបស់អ្នកជម្ងឺ (រយៈពេល២ខែកន្លងទៅ) ត្រូវទទួលការព្យាបាលដូចគ្នានឹងអ្នកជម្ងឺ (ព្យាបាលជម្ងឺប្រមេះទឹកបាយ និង ក្លាមីឌីយ៉ា)

២- ចំពោះជម្ងឺរលាកទ្វារមាសមិនចាំបាច់ព្យាបាលដៃគូទេ លុះត្រាតែអ្នកជម្ងឺកើតសារចុះសាឡើង (unless discharge recurs) ទើបព្យាបាល បុរសដែលជាដៃគូ ដោយផ្តល់ឱ្យនូវឱសថ Miconazole 2g លេបតែម្តងគត់ ។



# ជម្ងឺរលាកមាត់ស្បូនដែលបង្កឱ្យមានការហូរខ្ទុះ
(Mucupurulent cervicitis )

- ■ បង្កដោយមេរោគហ្គោណូកូក (GC), ក្លាមីឌីយ៉ា, អែរប៉េស, ឬ ទ្រីកូម៉ូណាស់ (GC, Ct, herpes or trichomonas).
- ■ មិនអាចកំណត់មូលហេតុមេរោគឱយបានច្បាស់តាមរយៈការពិនិត្យសរីរាង្គបានទេ (can not identified etiology by physical examination).
- ■ ភាគច្រើនគ្មានស្តែងចេញជារោគសញ្ញា, ប៉ុន្តែអាចមានហូរខ្ទុះ ឬ ធ្លាក់ឈាមមិនធម្មតា (may have discharge or abnormal bleeding).
- ■ ការពិនិត្យសរីរាង្គ អាចឃើញមានមាត់ស្បូនឡើងក្រហមដាច់ដោយ (erosion), ឬ មានហូរខ្ទុះលាយឈាម (friability of cervix with mucopurulent discharge).
- ■ ផលវិបាកបង្កអោយមានជម្ងឺរលាកប៉ែលវីស (Pelvic inflammatory disease).



# ការវាយតំលៃជម្ងឺរលាកមាត់ស្បូន
(Evaluation of cervicitis )

- ■ វត្ថុរាវពណ៌លឿងប្រឡាក់ដុំសំឡីដែលលូកចូលក្នុងរន្ធមាត់ស្បូន (yellow endocervical exudate on swab from cervix) គឺបញ្ជាក់ថាតេស្តដុំសំឡីវិជ្ជមាន (Positive swab test).
- ■ ឈាមប្រឡាក់ដុំសំឡីនៅពេលដែលជូតសំអាតមាត់ស្បូន (cervical bleeding with cotton swab: friability) .
- ■ ការបំពាក់ពណ៌ក្រាមលើសារធាតុសរីរៈដែលយកចេញពីមាត់ស្បូន:
  - -បង្ហាញវត្ថុមានគោលិកា ស លើស ឬស្មើ ២០ក្នុងមួយរង្វង់មីក្រូទស្សន៍,
  - - ភាគរយចំពោះមេរោគហ្គោណូកូក (sensitive 50-70%) ក្នុងករណីមិនឃើញវត្ថុមាន intracellular diplococci ទេចាំបាច់ត្រូវតែធ្វើការព្យាបាលជម្ងឺរលាកមាត់ស្បូន ដោយផ្អែកលើការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់
- ■ ពិនិត្យសក្នុងសភាពស្រស់ដើម្បីរកវត្ថុមានមេរោគទ្រីកូម៉ូណាស់ (saline wet mount for trichomonas).



Yellow discharge coming out of cervix



Yellow secretion on endocervical swab




Deep pain at bimanual palpation



≥20WBCs/HPF on Endocevical smear



# ការព្យាបាលជម្ងឺរលាកមាត់ស្បូន

(Cervicitis Treatment )

- ការព្យាបាលដោយសន្មត់ (Presumptive treatment)

  -អ្នកជម្ងឺដែលប្រឈមមុខខ្ពស់ទៅនឹងការឆ្លងមេរោគហ្គោណូកុក/ក្លាមីឌីយ៉ា (Risk assessment positive ឬកន្លែងដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់),

  -ចំពោះអ្នកជម្ងឺដែលមិនត្រឡប់មកតាមដានបន្ទាប់ពីធ្វើតេស្តហ្គោណូកុក/ក្លាមីឌីយ៉ា

  -កន្លែងដែលមិនមានលទ្ធភាពធ្វើតេស្តមេរោគហ្គោណូកុក/ក្លាមីឌីយ៉ា ត្រូវផ្តល់ការព្យាបាលដោយផ្អែកលើចង្កោមរោគសញ្ញា ។

- ការព្យាបាលដៃគូរួមភេទ (Partner treatment) ,

  -អនុវត្តតាមចង្កោមរោគសញ្ញាការធ្លាក់ស/ហូខ្ទុះតាមទ្វារមាស បើសិនជាគ្មានតេស្តសំរាប់ការធ្វើរោគវិនិច្ឆ័យ,

  -គ្រប់ដៃគូរួមភេទរបស់អ្នកជម្ងឺត្រូវទទួលការព្យាបាលដូចគ្នានឹងអ្នកជម្ងឺ (ព្យាបាលជម្ងឺប្រមេះទឹកបាយ និងក្លាមីឌីយ៉ា ឬ ទ្រីកូម៉ូណាស់) ។



# ការបង្ករោគក្លាមីឌីយ៉ា

(Chlamydia Infections )

- រលាកមាត់ស្បូន (cervicitis)
- រលាកបង្ហូរនោម (urethritis),
- រលាកភ្នែក (conjunctivitis),
- រលាកចុងពោះវៀនធំ (proctitis),
- ជម្ងឺរលាកជុំវិញថ្លើម: Pri-hepatitis (Fitz-Hugh Curtis syndrome),
- ៧០-៨០ភាគរយមិនស្តែងចេញជារោគសញ្ញា (70-80% asymptomatic),



# ការគ្រប់គ្រងថែទាំដៃគូរួមភេទដែលបង្កឡើងដោយក្លាមីឌីយ៉ា

(Chlamydia Partner Management )

- អាចចំលងបាន (transmissibility)

  -ពីបុរសទៅស្ត្រី: ៤៥-៧០ភាគរយ (male to female 45-70%),

  - ពីស្ត្រីទៅបុរស: ២៨-៦៨ភាគរយ (female to male 28-68%),

- ការព្យាបាលដៃគូរួមភេទ (Partner treatment) ,

  -គ្រប់ដៃគូរួមភេទរបស់អ្នកជម្ងឺ(កំឡុងពេល២ខែមុនធ្វើរោគវិនិច្ឆ័យ) ត្រូវវាយតំលៃដើម្បីធ្វើតេស្តពិនិត្យរកមេរោគ និងផ្តល់ព្យាបាល ។

  -បើសិន រយៈពេល២ខែមុនធ្វើរោគវិនិច្ឆ័យមិនមានដៃគូរួមភេទទេ ត្រូវព្យាបាលដៃគូថ្មីៗ

# ការបង្ករោគហ្គោណូកូកនៅលើស្ត្រី
(Gonococcal Infections in women )

- រលាកមាត់ស្បូន (cervicitis)
- រលាកបង្ហូរនោម (urethritis),
- រលាកភ្នែក (conjunctivitis),
- រលាកចុងពោះវៀនធំ (proctitis),
- រលាកបំពង់ក (pharyngitis),
- ការបង្ករោគនៅលើក្រពេញ Bartholin
- ការឈឺចុកចាប់ផ្នែកក្រោមនៃពោះ (PID)
- ជម្ងឺរលាកជុំវិញថ្លើម: Pri-hepatitis (Fitz-Hugh Curtis syndrome),
- ការរាតត្បាតមេរោគហ្គោណូកូកក្នុងឈាម (DGI)
- ៥០ភាគរយមិនស្តែងចេញជារោគសញ្ញា (50% asymptomatic),
- រោគសញ្ញាផ្សេងៗរួមមាន: ធ្លាក់សលាយឈាម, នោមឈឺផ្សា-ក្រហាយ



# រោគវិនិច្ឆ័យជម្ងឺប្រមេះទឹកបាយ

- ការបំពាក់ពិណក្រាមលើសារធាតុសរីរៈយកចេញពីមាត់ស្បូន:

  - Sensitive ៥០-៧០ ភាគរយ, ការព្យាបាលត្រូវផ្អែកលើការវាយតំលៃប្រឈមមុខនឹងគ្រោះថ្នាក់ បើសិនការបំពាក់ពិណក្រាមអវត្តមានមេរោគហ្គោណូកូក (would treat based on risk assessment if Gram stain negative for GC)

  - ការបណ្តុះមេរោគ Sensitive ៨០-៩៥ភាគរយ

  - ការធ្វើតេស្ត Gen-probe sensitive ៩០-៩៥ភាគរយ



# ការគ្រប់គ្រងថែទាំដៃគូរួមភេទដែលបង្កដោយហ្គោណូកូក
(GC Partner Management )

- អាចចំលងបាន (transmissibility)

  -ពីបុរសទៅស្ត្រី: ៥០-៩០ភាគរយ (male to female 50-90%),

  - ពីស្ត្រីទៅបុរស: ២០-៨០ភាគរយ (female to male 20-80%),

- ការព្យាបាលដៃគូរួមភេទ (Partner treatment) ,

  -គ្រប់ដៃគូរួមភេទរបស់អ្នកជម្ងឺ( កំឡុងពេល២ខែមុនធ្វើរោគវិនិច្ឆ័យ) ត្រូវវាយតំលៃដើម្បីធ្វើតេស្តពិនិត្យរកមេរោគ និងផ្តល់ព្យាបាល ។

  -បើសិន រយៈពេល២ខែមុនធ្វើរោគវិនិច្ឆ័យមិនមានដៃគូរួមភេទទេ ត្រូវព្យាបាលដៃគូថ្មីៗ



# សញ្ញាគ្លីនិក ជម្ងឺរលាកទ្វារមាស

- ធ្លាក់សខុសប្រក្រតី (abnormal vaginal discarge)
- រមាស់យោនី (vulvar itch)
- ធុំក្លិន (odor)
- មានអារម្មណ៍ក្រហល់ក្រហាយ (discomfort)
- នោមឈឺផ្សា-ក្រហាយ (burning with urination)
- ឈឺចាប់ពេលរួមភេទ (painful intercorse)

## មូលហេតុនៃជម្ងឺរលាកទ្វារមាស

- បាក់តេរី (bacterial vaginosis)
- ទ្រីកូម៉ូណាស់ (trichomonas)
- កង់ឌីដាស (candida)

រោគវិនិច្ឆ័យបែងចែក (differential diagnosis)

- Gonorrhoeae
- Chlamydia
- Atrophic vaginitis
- Allergy
- Foreign body
- Urinary tract infection



## ការវាយតំលៃជម្ងឺរលាកទ្វារមាស

- សភាពលក្ខណៈនៃ សដែលហូរចេញពីទ្វារមាស (characteristics of vaginal discharge)
- រូបរាងនៃទឹករអិល (appearance of mucosa)
- តេស្ត pH ទ្វារមាស (vaginal pH)
- តេស្តក្លិន (amine test)
- ការពិនិត្យស ក្នុងសភាពស្រស់ (saline and KOH wet mount)
- តេស្តសំឡីមានដង (swab test)
- ធ្វើតេស្តក្លាមីឌីយ៉ា និង ហ្គោណូកូក (CT and GC tests)



## ជម្ងឺរលាកទ្វារមាសដែលបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ (Trichomonasis)

- បង្កឡើងដោយទ្រីកូម៉ូណាស់ (trichomonas vaginalis)
- អាចបង្ករោគនៅលើមាត់ស្បូន,ទ្វារមាស,បង្ហួរនោម ឬប្លោកនោម (cervix, vagina, urethra or bladder)
- រលាកបង្ហួរនោមនៅលើបុរស ប៉ុន្តែវាអាចបាត់ទៅវិញដោយឯកឯង
- ជាអនុសាសន៍ត្រូវព្យាបាលដៃគូរួមរួមចំពោះអ្នកជម្ងឺរលាកទ្វារមាសដែលបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ (ការធ្វើតេស្តរកមេរោគទ្រីកូម៉ូណាស់នៅលើបុរសមានការលំបាក)



## រោគសញ្ញានៃការរលាកទ្វារមាសដែលបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់

- ស ធំក្លិនអាក្រក់, ពណលឿង-បៃតង, ឈឺក្រហាយ, រមាស់យោនី (malodorous yellow-green discharge, irritation, vulvar itching)
- អាចឃើញមានចំណុចក្រហមតូចៗនៅលើមាត់ស្បូន (strawberry cervix)
- ជាញឹកញាប់ប្រមាណ៥០ភាគរយមិនស្តែងចេញជារោគសញ្ញា (≥50% asymptomatic)
- យោងតាមឯកសារបង្ហាញថានៅលើបុរស និងស្ត្រី មិនស្តែងចេញជារោគសញ្ញា ដែលមានរយៈពេលយូរអង្វែង ។

## រោគវិនិច្ឆ័យជម្ងឺរលាកទ្វារមាសដែលបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់

- ស មានលក្ខណៈរាវ, ពពុះ, ពណ៌លឿង-បៃតង (thin frothy grey/yellow vaginal discharge)
- អាចឃើញមានចំណុចក្រហមតូចៗនៅលើមាត់ស្បូន (strawberry cervix 5-10%)
- វត្តមានទ្រីកូម៉ូណាស់នៅពេលពិនិត្យស ភ្លាមៗដោយប្រើសេរ៉ូមប្រៃ (motile trichomonads on saline wet mount)
- តេស្ត pH>4.5
- តេស្តក្លិនអាចវិជ្ជមាន (whiff test may be positive)
- ការពិនិត្យស ក្នុងសភាពស្រស់ (saline and KOH wet mount)
- បណ្តុះមេរោគទ្រីកូម៉ូណាស់ដោយប្រើតេស្ត In Pouch (culture-in pouch TV test)



## ជម្ងឺរលាកយោនី-ទ្វារមាសដែលបង្កឡើងដោយមេរោគកង់ឌីដាស (vulvovaginal candidiasis)

- បង្កឡើងដោយកង់ឌីដាសផ្សេងៗគ្នា (albicans 75-90%, glabrata 5-10%, tropicalis 5-10%)
- ១០-១៥ភាគរយនៅលើស្ត្រីពពួកកង់ឌីដាសអាច colonize ដូច្នេះត្រូវពិចារណាក្នុងករណីបង្កជម្ងឺ គឺមានរោគសញ្ញ (pathogen if symptomatic)
- ការបង្ករោគជួបប្រទះញឹកញាប់

  - ចំពោះស្ត្រី ៧០-៧៥ភាគរយ ក្នុងកំឡុងពេលរស់នៅ (70-75% of women during their lifetime)

  - ៤០-៥០ ភាគរយយ៉ាងហោចណាស់កើតសាឡើងវិញម្តង (40-50% have at least one recurrence)



## ជម្ងឺរលាកយោនី-ទ្វារមាសដែលបង្កឡើងដោយមេរោគកង់ឌីដាស (vulvovaginal candidiasis)

កត្តាប្រឈមមុខ (risks factor)

- អ័រម៉ូនប្រែប្រួល (hormonal changes)
- ពេលមានផ្ទៃពោះ (pregnancy)
- អ្នកជម្ងឺទឹកនោមផ្អែម (diabetes)
- ប្រើប្រាស់អង់ទីប៊ីយូទិក (antibiotic use)
- HIV infection
- ប្រើប្រាស់ស្តេរ៉ូអ៊ីត (steroid)



## រោគសញ្ញានៃការរលាកយោនី-ទ្វារមាសដែលបង្កឡើងកង់ឌីដាស់

- ធ្លាក់ស, ទ្វារមាសរលាកឡើងក្រហម, ឈឺផ្សា-ក្រហាយ, និងរមាស់ (vaginal discharge, vaginal soreness, burning, itching)
- រមាស់យោនី ឬនោមឈឺផ្សា-ក្រហាយ (vulva pruritis or dysuria)
- ស មានសភាព កក, អាចរាវ-ខាប់ ដូចទឹកដោះគោ (discharge white, thin and watery to thick and curd-like)
- ទ្វារមាស-យោនីរលាកឡើងក្រហម (erythematous vaginal and vulva) ។

# រោគវិនិច្ឆ័យជំងឺរលាកយោនី_ទ្វារមាសដែលបង្កឡើងដោយកង់ឌីដាស់

- ស មានសភាព កក, អាចរាវខាប់ ដូចទឹកដោះគោ (discharge white, thin and watery to thick and curd-like)
- ការពិនិត្យតាមរយៈមីក្រូទស្សន៍បង្ហាញវត្តមាន:

  - yeast or pseudohyphae (ការពិនិត្យស ភ្លាមៗ)

  - yeast or pseudohyphae (ការបំពាក់ពិណក្រាមសារធាតុសរីរៈយកចេញពីទ្វារមាស)
- តេស្ត pH normal





# ការធ្វើរោគវិនិច្ឆ័យបែងចែកនៃជំងឺរលាកទ្វារមាស

| | BV | VCC | TV |
|---|---|---|---|
| រោគសញ្ញា | ធ្លាក់ស មានក្លិន | ធ្លាក់ស រមាស់ | ធ្លាក់ស រមាស់ |
| ការធ្លាក់ស | ប្រាវ ដូចទឹកដោះគោ ស្មើសាច់ ធំក្លិនស្អុយ | ពណស កក ដូច cheesy | ពណប្រផេះ ពពុះ ធំក្លិនស្អុយ |
| pH | >4.5 | ធម្មតា | |
| តេស្តក្លិន | វិជ្ជមាន | អវិជ្ជមាន | វិជ្ជមាន/អវិជ្ជមាន |
| ពិនិត្យសភ្លាមៗ | Clue cells | Yeast/hyphea | Motile protozoa |
| បំពាក់ពិណក្រាម | ពិន្ទុ Nugent ≥7 | Yeast/hyphea | |



# Normal vaginal flora អាចប្រែប្រួលតាមរយៈ

- ការលូកលាងសំអាតផ្នែកខាងក្នុងទ្វារមាស (douching)
- ការព្យាបាលរោគដោយប្រើ antibiotic និង antifungal
- ការប្រែប្រួលអ័រម៉ូន, មានផ្ទៃពោះ, ការលេបថ្នាំពន្យាកំណើត (hormonal changes, pregnancy, birth control pills)
- ការប្រើ spermacides, lubricant
- ការប្រើ tampons, IUD, diaphragm
- ទឹកកាម (semen)



# តើការលាងសំអាតផ្នែកក្នុងនៃទ្វារមាសគឺជាអ្វី?

## (What is vaginal douching?)

គឺជាការលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាសដោយការប្រើប្រាស់ទឹក ឬ សូលុយស្យុងផ្សេងៗ ដូចជា:

-ទឹកអំបិល (salted water)

-ទឹកសាប៊ូ (soap water)

-ទឹកក្រូចឆ្មារ (lemon juice)

-ទឹកខ្មេះ (vinegar)

-ថ្នាំដុសធ្មេញ (tooth paste)

-សាច់ជូ ស (white alum) ។ល។

## ហេតុអ្វីបានជាស្ត្រីលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាស?

**(why women use vaginal douches?)**

- វាជាការអនុវត្តតៗគ្នាដែលគេគិតថាវាមានតាំងពីយូរយារមកហើយ
- គោលបំណងដែលស្ត្រីធ្វើការលូកលាងសំអាតផ្នែកខាងក្នុងនៃក្នុងទ្វារមាសគឺៈ

  -លាងសំអាតឈាមចេញ ( ពេលកំពុងមានរដូវ ឬក្រោយពេលមានរដូវ)

  -លាងសំអាតក្នុងទ្វារមាសក្រោយពីរួមភេទដើម្បីចៀសវាងការឆ្លងជម្ងឺកាមរោគ ឬបង្ការភាពមានគិក

  -កាត់បន្ថយក្លិនស្អុយ



## បញ្ហានៃការលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាស

**(Problems of vaginal douching)**

ការលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាសអាចបណ្តាលឱ្យៈ

- ទ្វារមាសរលាកឡើងក្រហម
- ការបង្ករោគដោយពពួកបាក់តេរី
- ប្រឈមមុខនឹងការឆ្លងជម្ងឺកាមរោគ/មេរោគអេដស៏
- ងាយបង្កឱ្យកើតជម្ងឺឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ
- ផលវិបាកនៃជម្ងឺឈឺចុកចាប់ផ្នែកក្រោមនៃពោះរ៉ាំរ៉ៃ ដូចជាៈ អសមត្ថភាពបន្តពូជ, កូនក្រៅស្បូន
- ផលវិបាកនៃជម្ងឺបង្កឡើងពពួកមេរោគ Bacterial vaginosis ដូចជាៈ ការបែកស្រោមទឹកភ្លោះមុនពេលសំរាល ,រលាកស្រោមទឹកភ្លោះ,កូនកើតមិនគ្រប់ខែ,និងរលាកអង់ដូម៉ែត្រក្រោយពេលសំរាល



## តើការលូកលាងសំអាតផ្នែកខាងក្នុងទ្វារមាសមានសុវត្ថិភាពដែរឬទេ?

**(Is vaginal douching safe?)**

អ្នកផ្តល់សេវាមិនត្រូវធ្វើការណែនាំអ្នកមកទទួលសេវាឱ្យលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាសទេពីព្រោះៈ

- ការលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាសបណ្តាលឱ្យមានការប្រែប្រួលលំនឹងនៃជាតិគីមីនៅក្នុងទ្វារមាស (chemical balance in vagina) និងពពួកអតិសុខុមប្រាណ (vaginal flora) ដែលជាមូលហេតុ បណ្តាលឱ្យមានការកើនឡើងនៃការបង្ករោគដោយពពួកបាក់តេរី ។
- វាអាចបណ្តាលឱ្យមានការរីកសាយភាយនៃមេរោគដែលមាននៅក្នុងទ្វារមាស ឬ មេរោគដែលបង្ករោគនៅមាត់ស្បូនឡើងទៅបង្ករោគសរីរាង្គប៉េលវីស ដូចជាៈ ដៃស្បូន, អូវែ ។ល។



## សន្និដ្ឋាន (Conclusions)

- ជាទូទៅទ្វារមាសសំអាតដោយខ្លួនឯង
- ស្ត្រីដែលមានអារម្មណ៏ចង់ឱ្យទ្វារមាសស្អាតពួកគេអាចលាងសំអាតផ្នែកខាងក្រៅនៃទ្វារមាសជាមួយទឹក ឬទឹកនិងសាប៊ូ ។ ប៉ុន្តែមិនត្រូវលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាសទេ (inside the vagina)
- ការលូកលាងសំអាតក្នុងទ្វារមាសជាគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរពីព្រោះវាប្រឈមមុខទៅនឹងការបង្ករោគ
- ការលាងសំអាតក្នុងទ្វារមាសមុនពេលមកពិគ្រោះជម្ងឺនៅគ្លីនិកកាមរោគជាមូលហេតុធ្វើឱ្យមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យ ។
- ដូច្នេះអ្នកផ្តល់សេវារួមជាមួយអ្នកអប់រំផ្ទាល់ត្រូវតែធ្វើការពន្យល់ណែនាំដល់ស្ត្រីរកស៊ីផ្លូវភេទ និងម្ចាស់បនឱ្យយល់ច្បាស់ស្តីពីបញ្ហាគ្រោះថ្នាក់ទាំងឡាយដែលអាចកើតមាន ដើម្បីចៀសវាងស្ត្រីទាំងនោះកុំឱ្យលូកលាងសំអាតផ្នែកខាងក្នុងនៃទ្វារមាស ។

## ជម្ងឺរលាកទ្វារមាសដែលបង្កឡើងដោយបាក់តេរី
(Bacterial vaginosis)

- ពពួក Lactobacilli ត្រូវជំនួសដោយពពួកមេរោគ anerobes (mobiluncus) និង Gardnerella
- កត្តាប្រឈមមុខនឹងគ្រោះថ្នាក់: មានដៃគូរួមភេទច្រើន, មានដៃគូរួមភេទថ្មីច្រើន, លូកលាងសំអាតផ្នែកខាងក្នុងទ្វារមាស (multiple or new partners, routine douching)
- មិនមែនជាជម្ងឺកាមរោគទេ ប៉ុន្តែទាក់ទងនឹងការរួមភេទ
- បង្កអោយមានរលាកអង់ដូម៉ែត្រ បន្ទាប់ពីដាក់កង, ពន្លូតកូន, endometrial biopsy, hysteroscopy
- បង្កើនការចំលងមេរោគអេដស៍



## រោគសញ្ញានៃការរលាកទ្វារមាសដែលបង្កឡើងដោយបាក់តេរី

- ស ធុំក្លិនស្អុយ (foul"fishy" odor)
- បរិមាណនៃ ស មានការកើនឡើង (increased amount discharge)
- រមាស់ និង/ឬ ឈឺផ្សា-ក្រហាយ យោនី (vaulvar itching and/or irritation)
- រោគសញ្ញាកាន់តែធ្ងន់ធ្ងរក្រោយពីរួមភេទ និងកំឡុងពេលមករដូវ (symptoms worse after intercourse and during mense)
- ប្រហែល ៥0ភាគរយ មិនស្តែងចេញជារោគសញ្ញា (50% may be asymptomatic)



## បាក់តេរីនៅទ្វារមាសដែលបណ្តាលអោយមានការបង្ករោគរើឡើងវិញ
(Bacterial vaginosis: recurrent infection)

ជាញឹកញាប់ Bacterial vaginosis មានការបង្ករោគឡើងវិញ

- ២៥ភាគរយ ក្នុងកំឡុងសប្តាហ៍ទី ២-៦ ក្រោយពីព្យាបាល
- ក្នុងរយ:ពេល១ឆ្នាំ នឹងមានការបង្ករោគឡើងវិញរហូតទៅដល់ ៨៥ភាគរយ
- អាចបង្ករោគឡើងវិញបន្ទាប់ពីប្រើ Metronidazol ឬ clindamycin
- ការព្យាបាលដៃគូមិនអាចកាត់បន្ថយការបង្ករោគឡើងវិញបានទេ ។

យុទ្ធសាស្រ្តក្នុងការគ្រប់គ្រង

- ប្រើ Metronidazol gel លាប១ដង ឬ ២ដង ក្នុង១សប្តាហ៍ រយ:ពេល ៣-៦សប្តាហ៍
- ប្រើស្រោមអនាម័យដើម្បីកាត់បន្ថយទឹកកាមដែលប៉ះពាល់ (condoms to reduce semen exposure)



## ការធ្វើរោគវិនិច្ឆ័យជម្ងឺរលាកទ្វារមាសបង្កឡើងដោយបាក់តេរី

**Amsel criterial:**

**ការធ្វើរោគវិនិច្ឆ័យយ៉ាងហោចត្រូវផ្អែកទៅលើ0៣លក្ខណ:ក្នុងចំណោមលក្ខណ:0៤ខាងក្រោម**

1. តេស្ត pH ទ្វារមាសធំជាង ៤.៥
2. ស មានលក្ខណ:រាវ, ស្មើសាច់, ស ដូចទឹកដោះគោ ស្អិតជាប់ ជញ្ជាំងទ្វារមាស (thin, homogenous/ milky-white discharge adherent to vaginal walls)
3. ក្លិនតេស្តវិជ្ជមាន (whiff test positive)
4. វត្តមាន Clue cells

# លក្ខណៈរបស់ Amsel criterial:



តេស្តក្លិន (Amine odor)



វត្តមានឃ្លូសែល (Clue cells)



ស រាវ ស្មើសាច់ (thin homogenous)



តេស្ត pH ទ្វារមាស> 4.5 (vaginal pH> 4.5)






## Gram's stain Vaginal flora

Normal

Intermediate

Bacterial vaginosis



# ការបំពាក់ពណ៌ក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស



ការបំពាក់ពិណក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស
បង្ហាញវត្តមាន កង់ឌីដាសក្រាមវិជ្ជមាន (mycelia)



ការបំពាក់ពិណក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស
បង្ហាញវត្តមាន កង់ឌីដាសក្រាមវិជ្ជមាន (budding yeast)

# ម៉ូឌុលទី ៣.៤

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបន្តរោគតាមការរួមភេទ និងប្រដាប់បន្តពូជ

## ការធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស នៅលើស្ត្រីបំរើសេវាកំសាន្ត

## (VAGINAL DISCHARGE IN FEMALE SEX WORKERS)

1

# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ការធ្លាក់ ស ឬហូរខ្ទុះតាមទ្វារមាស ចំពោះស្ត្រីបំរើសេវាកំសាន្ត

2

**គំនូសបំព្រួញទី១**

**សំរាប់ពិនិត្យព្យាបាលការធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស លើស្ត្រីបំរើសេវាកំសាន្ត ( ករណីគ្មានតេស្តមន្ទីរពិសោធន៏ )**




3

**គំនូសបំព្រួញទី២**

**សំរាប់ពិនិត្យព្យាបាលការធ្លាក់ស/ហូរខ្ទុះតាមទ្វារមាស លើស្ត្រីបំរើសេវាកំសាន្ត ( ករណីមានតេស្តមន្ទីរពិសោធន៏ )**




4

## ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ចំពោះជម្ងឺរលាកមាត់ស្បូន
## តាមរយៈការសាកសួរ   ចំពោះស្ត្រីបំរើសេវាកំសាន្ត

១-គូ្រញត្អែរមានធ្លាក់សពិណលឿងខាប់

២-មានឈឺចុកចាប់ផ្នែកក្រោមនៃពោះគ្រប់ពេលរួមភេទជាមួយភ្ញៀវ

៣-ទទួលភ្ញៀវជាមធ្យមលើសពី០៥នាក់ក្នុង១ថ្ងៃ

៤-មិនបានប្រើស្រោមជាមួយភ្ញៀវថ្មីៗ

ប្រសិនបើស្ត្រីបំរើកំសាន្តឆ្លើយស្រប (ចាស់) នូវចំលើយពីរក្នុងចំណោមចំលើយទាំង៤ខាងលើនេះ ត្រូវព្យាបាលជម្ងឺរលាកមាត់ស្បូន



## ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ចំពោះជម្ងឺរលាកមាត់ស្បូន
## តាមរយៈការពិនិត្យគ្លីនិក   ចំពោះស្ត្រីបំរើសេវាកំសាន្ត

១- ធ្លាក់ស ឬហូរខ្ទុះពណ៌លឿងចេញពីមាត់ស្បូនមកក្រៅ ឬ

២- វត្ថុរាវពណ៌លឿងប្រឡាក់ដុំសំឡីដែលលូកទៅក្នុងមាត់ស្បូន ឬ

៣- មាត់ស្បូនរលាកដាច់ដោច ឬមានហូរឈាម ឬ

៤- មានការឈឺចុកចាប់ផ្នែកក្រោមពោះពេលលូកនិងស្ទាបដោយដៃទាំងពីរ

ប្រសិនបើរកឃើញមានរោគសញ្ញាណាមួយក្នុងចំណោមរោគសញ្ញាទាំង៤ខាងនេះ ត្រូវព្យាបាលជម្ងឺរលាកមាត់ស្បូន



## ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ចំពោះជម្ងឺរលាកមាត់ស្បូន
## តាមរយៈការធ្វើតេស្តមន្ទីរពិសោធន៍   ចំពោះស្ត្រីបំរើសេវាកំសាន្ត

- ស្រង់យកវត្ថុរិភាគពីមាត់ស្បូន (endocervical smear)
- បំពាក់ពិណក្រាម (Gram stain)
- ពិនិត្យដោយមីក្រូទស្សន៍ ដើម្បីរាប់ចំនួនគោលិកា ស :

***ប្រសិនបើ គោលិកា ស មានចំនួនលើសពី ១០ (≥10/HPF)  ត្រូវព្យាបាលជំងឺរលាកមាត់ស្បូន***





Yellow discharge coming out of cervix



Yellow secretion on endocervical swab




Deep pain at bimanual palpation



≥10WBCs/HPF on Endocevical smear

# ការធ្វើរោគវិនិច្ឆ័យជំងឺរលាកទ្វារមាសបង្កឡើងដោយបាក់តេរី

## Amsel criterial:

**ការធ្វើរោគវិនិច្ឆ័យយ៉ាងហោចត្រូវផ្អែកទៅលើ០៣លក្ខណៈក្នុងចំណោមលក្ខណៈ០៤ខាងក្រោម**

1. តេស្ត pH ទ្វារមាសធំជាង ៤.៥
2. ស មានលក្ខណៈរាវ, ស្មើសាច់, ស ដូចទឹកដោះគោ ស្អិតជាប់ ជញ្ជាំងទ្វារមាស (thin, homogenous/ milky-white discharge adherent to vaginal walls)
3. ក្លិនតេស្តវិជ្ជមាន (whiff test positive)
4. វត្តមាន Clue cells



# លក្ខណៈរបស់ Amsel criterial:



តេស្តក្លិន (Amine odor)



វត្តមានឃ្លូសែល (Clue cells)



ស រាវ ស្មើសាច់ (thin homogenous)



តេស្ត pH ទ្វារមាស> 4.5 (vaginal pH > 4.5)






## Gram's stain Vaginal flora

Normal

Intermediate

Bacterial vaginosis



# ការបំពាក់ពណ៌ក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស



ការបំពាក់ពិណក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស បង្ហាញវត្តមាន កង់ឱីដាសក្រាមវិជ្ជមាន (mycelia)



ការបំពាក់ពិណក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស បង្ហាញវត្តមាន កង់ឱីដាសក្រាមវិជ្ជមាន (budding yeast)

# ការសិក្សាករណីទី១

**អ្នកជំងឺ :** នាងមុំ ជាស្ត្រីរកស៊ីផ្លូវភេទមានអាយុ ១៨ឆ្នាំ ជាស្ត្រី បំរើសេវាកំសាន្ត ។

**ប្រវត្តិជំងឺ:** នាងមកពិនិត្យសុខភាពជាប្រចាំនៅគ្លីនិកសុខភាពគ្រួសារ ។

**ការពិនិត្យ:** ពេលពិនិត្យដោយចំពុះទាបង្ហាញឱ្យឃើញថាផ្នែកខាងក្រៅនៃជញ្ជាំងទ្វារមាសមានធ្លាក់ ស បន្តិចបន្តួច ហើយមាត់ស្បូនមានសភាពហើមក្រហម **(edema, erythematous)** និងមានហូរខ្ទុះពិណលឿងខាប់ចេញពីរន្ធមាត់ស្បូន **(mucopurulent discharge from the cervical os)** នៅពេលពិនិត្យដោយប្រើដៃទាំងពីរ **(bimanual examination)** អ្នកជំងឺពុំមានការឈឺចុកចាប់ផ្នែកក្រោមនៃពោះ និងគ្មានដុំពោះទេ ។





# លទ្ធផលតេស្តមន្ទីរពិសោធន៍

ការបំពាក់ពិណក្រាម នៅលើសារធាតុសរីរៈយកចេញពីមាត់ស្បូនបង្ហាញវត្តមានមេរោគហ្គោណូកុក និង គោលិកា ស លើសពី៣០ ក្នុង មួយវង្វង់មី ក្រូទស្សន៍

(Cervical exudates shows WBC>30 ) ។





## ១- តើរោគវិនិច្ឆ័យរបស់នាងជាជំងឺអ្វី?

ក.ជំងឺបង្កឡើងដោយមេរោគហ្គោណូកុក (Gonorrhoear)

ខ.ជំងឺបង្កឡើងដោយមេរោគក្លាមីឌីយ៉ា (Chlamydia infection)

គ.ជំងឺរលាកមាត់ស្បូនបង្កឡើងដោយមេរោគហ្គោណូកុក និងមរោគក្លាមីឌីយ៉ា (Gonorrhoear and Chlamydia)

ឃ.ជំងឺរលាកទ្វារមាសរួមជាមួយរលាកមាត់ស្បូន (Vaginal discharge)

## ២- តើអ្នកផ្តល់ការព្យាបាលដូចម្តេច?

ក. Cefixime 400mg លេបតែម្តងគត់

ខ. Azithromycin 1g លេបតែម្តងគត់ ឬ

គ. Doxycycline 100mgx2 ដងក្នុងមួយថ្ងៃរយះពេល៧ថ្ងៃ

ឃ. ក និងខ



# ការសិក្សាករណីទី២

**អ្នកជំងឺ:** អ្នកជម្ងឺមានអាយុ ១៨ឆ្នាំ ជាស្ត្រីបំរើសេវាកំសាន្ត។

**ប្រវត្តិជំងឺ:** អ្នកជម្ងឺបានប្រើឱសថ antibiotic ព្យាបាលជម្ងឺ bacterial urinary tract infection អស់រយ:ពេល១០ថ្ងៃ ប៉ុន្តែសភាពជម្ងឺពុំបានធូរស្រាលឡើយ។ អ្នកជម្ងឺត្អូញត្អែរថា យោនី មានសភាពរមាស់ខ្លាំង (vulvar itching) និងមានធ្លាក់សកាន់តែច្រើន អស់រយ:ពេល0២ ថ្ងៃមកហើយ ។

**ការពិនិត្យ:** បង្ហាញឱ្យឃើញថាយោនីហើម-ក្រហម (vulvar erythema) ស មានសភាព ពិណស (white discharge) និងមានស្នាមបន្ទះស១ នៅលើមាត់ស្បូន (patches on cervix) ក្រៅពីនេះគឺមានសភាពធម្មតា។





# លទ្ធផលតេស្តមន្ទីរពិសោធន៍

ការពិនិត្យសរយកចេញពីទ្វារមាសបង្ហាញថា មានវត្តមាននៃពពួក Budding yeasts/Hyphae





## ១- តើរោគវិនិច្ឆ័យរបស់នាងជាជំងឺអ្វី?

ក.ជំងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ (Trichomonasis)

ខ.ជំងឺបង្កឡើងដោយមេរោគហ្គោណូកូក (Gonorrhoea)

គ-ជំងឺបង្កឡើងដោយមេរោគបាក់តេរីវ៉ាស៊ីណូស៊ីស (Bacterial vaginosis)

ឃ.ជំងឺរលាកទ្វារមាសបង្កឡើងដោយមេរោគផ្សិត (Candiasis)

## ២ -តើអ្នកផ្តល់ការព្យាបាលដូចម្តេច?

ក Cefixime 400mg លេបតែម្តងគត់ រួមជាមួយ Azithromycin 1g លេបតែម្តងគត់

ខ. Metronidazole 500mgx2 លេបដង ក្នុង១ថ្ងៃរយះពេល៧ថ្ងៃ

គ. Clotrimazole 500mg ស៊ុលទ្វារមាសតែម្តងពេលយប់

ឃ-មិនបាច់ព្យាបាល



# ការសិក្សាករណីទី៣

**អ្នកជំងឺ** : អាយុ ២០ឆ្នាំ ជាស្ត្រីបំរើស្រាបៀរ ។

**ប្រវត្តិជំងឺ:** នាងត្អូញត្អែរថាធ្លាក់សច្រើន និងរមាស់យោនី អស់រយះពេល០២សប្តាហ៍មកហើយ និងធ្លាប់មានដៃគូរួមភេទម្នាក់កាលពី០២ខែកន្លងទៅ ។

**ការពិនិត្យ:** បង្ហាញឱ្យឃើញថាផ្នែកខាងក្រៅប្រដាប់បន្តពូជមានសភាពធម្មតា, ទ្វារមាសហើមក្រហម មានធ្លាក់រំអិលបន្តិចបន្តួចពណ៌លឿង ។ រីឯមាត់ស្បូនមានលក្ខណៈ ectopy ហើមឡើងក្រហម នៅពេលពិនិត្យដោយដៃទាំងពីរមានការឈឺចាប់បន្តិចបន្តួច និងពុំមានដុំពោះទេ ។





# លទ្ធផលតេស្តមន្ទីរពិសោធន៍

- តេស្ត pH 5.5 ,តេស្តក្លិនវិជ្ជមាន (whiff test positive)

-ពិនិត្យសភ្លាមៗបង្ហាញវត្តមានៈ Leucocytes, motile trichomonads, clue cells

-ការបំពាក់ពណ៌ក្រាមនៅលើសារធាតុសរីរៈ យកចេញពីមាត់ស្បូនបង្ហាញថា ចំនួន គោលិកា ស លើសពី២០ក្នុងមួយរង្វង់មីក្រូទស្សន៍ និងមិនមានមេរោគហ្គោណូកូកទេ (Gram stained of cervical exudates shows WBC>20 without ICD) ។

-ការបណ្តុះមេរោគហ្គោណូកូកៈ វិជ្ជមាន និងធ្វើតេស្តរកមេរោគអេដស៍ វិជ្ជមាន

-តេស្ត RPR អវិជ្ជមាន

# ការសិក្សាករណីទី៣

១-តើរោគវិនិច្ឆ័យរបស់នាងជាជំងឺអ្វី?

២-តើអ្នកធ្វើការគ្រប់គ្រងដូចម្តេច?

៣-តើអ្នកនឹងធ្វើការគ្រប់គ្រងដៃគូរួមភេទដូចម្តេច?



# ការសិក្សាករណីទី៤

**អ្នកជំងឺ:** មានអាយុ ២២ឆ្នាំ ជាស្ត្រីបំរើសេវាកំសាន្ត។

**ប្រវត្តិជំងឺ:** អ្នកជម្ងឺត្អូញត្អែរថាធ្លាក់ស ធំក្លិនស្អុយ អស់រយៈពេល ០១សប្តាហ៍ និងកាលពី០១ខែកន្លងទៅ នាងមានមិត្តប្រុសថ្មី ម្នាក់ (new boyfriend one month preously ។

**ការពិនិត្យ:** បង្ហាញឱ្យឃើញថា ស មានសភាពស្មើសាច់ (homogenous white discharge) ស្អិតជាប់ជញ្ជាំងទ្វារមាស មាត់ស្បូនមានលក្ខណៈ ectopy និងមានរំអិលច្រើននៅតាមមាត់ស្បូន (cloudy mucus) ការពិនិត្យដោយដៃទាំងពីរគឺអ្នកជម្ងឺមាន សភាពធម្មតា។





# លទ្ធផលតេស្តមន្ទីរពិសោធន៍

-បំពាក់ពិណក្រាមលើសារធាតុសរីរៈយកចេញពីទ្វារមាស បង្ហាញវត្តមាន Nugent score>7 និងអវត្តមាននៃពពួក budding yeast/mycelea ។

-ពិនិត្យស យកចេញពីមាត់ស្បូនបង្ហាញថាមានវត្តមាននៃពពួកគោលិកា ស តិចជាង១០ក្នុងមួយរង្វង់មីក្រូទស្សន៍ និងអវត្តមាននៃមេរោគហ្គោណូកុក (WBC<10 /HPF without Gram negative intracellular diplococci)

-តេស្ត RPR អវិជ្ជមាន

-តេស្ត HIV អវិជ្ជមាន



Gram stain of vaginal discharge



## ១- តើរោគវិនិច្ឆ័យរបស់នាងជាជំងឺអ្វី?

ក.ជំងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ (Trichomonasis)

ខ.ជំងឺបង្កឡើងដោយមេរោគហ្គោណូកុក (Gonorrhoea)

គ-ជំងឺបង្កឡើងដោយមេរោគបាក់តេរីវ៉ាស៊ីណូស៊ីស (Bacterial vaginosis)

ឃ.ជំងឺបង្កឡើងដោយក្លាមីឌីយ៉ា (Chlamydia trachomatis)

## ២-តើអ្នកផ្តល់ការព្យាបាលដូចម្តេច?

ក Cefixime 400mg លេបតែម្តង

ខ. Metronidazole 500mgx2 លេបដង ក្នុង១ថ្ងៃរយះពេល៧ថ្ងៃ

គ. Metronidazole 1g លេបតែម្តង

ឃ- Doxycycline 100mgx2 លេបដង ក្នុង១ថ្ងៃរយះពេល៧ថ្ងៃ

# ម៉ូឌុលទី ៣.៥

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ជំងឺរលាកអាងត្រគាក

**(Pelvic Inflammatory Disease)**



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្រ្តនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល

  ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ



# រោគសញ្ញា និងមូលហេតុនៃការឈឺចុកចាប់ផ្នែកក្រោមនៃពោះ






# ការពិនិត្យការឈឺចុកចាប់ផ្នែកក្រោមនៃពោះនៅលើស្ត្រី

**ស្រង់ប្រវត្តិ និងការពិនិត្យអ្នកជម្ងឺដូចខាងក្រោម:**

-សាកសួរពីការធ្លាក់ហូរឈាមតាមទ្វារមាស

-សាកសួរពីការធ្លាក់សមិនធម្មតា

-សាកសួរពីរយៈពេលមករដូវលើកចុងក្រោយ

-សាកសួរពីការរលូតកូន, ការពន្លូតកូន
ឬការសំរាលកូនក្នុងរយៈពេល ០៦សប្តាហ៏កន្លងមក

-វាស់សីតុណ្ហភាព

-ស្ទាបពោះ រកមើលការឈឺចុកចាប់ផ្នែកខាងក្រោម
នៃពោះ, ការកន្ត្រាក់រឹងសាច់ដុំនៃពោះ, ពោះឈឺ
ឡើងរឹងនៅពេលស្ទាប ឬស្ទាបរកមើលក្រែងមានដុំពោះ

-ពិនិត្យទ្វារមាស



# គំនូសបំព្រួញសំរាប់ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះស្ត្រី




# លក្ខណៈគ្លីនិក និងការណែនាំស្តីពីការព្យាបាល

**លក្ខណៈគ្លីនិក**

-សីតុណ្ហភាពលើសពី ៣៨.៣ អង្សារសេ

-ស ពិណលឿងខាប់ហូរចេញពីមាត់ស្បូន ឬទ្វារមាស

-ពិនិត្យសភ្លាមៗដោយប្រើទឹកសេរ៉ូមប្រៃតាមរយៈមីក្រូទស្សន៍បង្ហាញវត្តមានគោលិកា ស

-តេស្ត ក្លាមីឌីយ៉ា ឬហ្គោណូកូក វិជ្ជមាន

**ការណែនាំស្តីពីការព្យាបាល**

-ការធ្វើចលនាមាត់ស្បូនមានការឈឺចាប់ (cervical motion tenderness)

-ឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ

-ធ្លាក់ស តាមទ្វារមាស





# ករណីអ្នកជម្ងឺឈឺចុកចាប់ផ្នែកក្រោមនៃពោះត្រូវសំរាកមន្ទីរពេទ្យ

- រោគវិនិច្ឆ័យមិនច្បាស់លាស់
- មិនអាចញែកបាន ដូចជា ជម្ងឺរលាកខ្នែងពោះវៀន ឬ កូនក្រៅស្បូន
- សង្ស័យមានខ្ទុះនៅតំបន់អាងត្រគៀក
- អ្នកជម្ងឺធ្ងន់ធ្ងរមិនអាចព្យាបាលសំរាកនៅផ្ទះបាន
- អ្នកជម្ងឺមានផ្ទៃពោះ
- អ្នកជម្ងឺមិនអាចប្រព្រឹត្តតាម ឬទ្រាំទ្របានពីការព្យាបាលមិនសំរាកពេទ្យ



# ករណីដែលត្រូវបញ្ជូនទៅកាន់ផ្នែកឯកទេស

- បាត់ ឬក្រមករដូវ ឬ
- ទើបតែសំរាល /រលូតកូន/ពន្លូតកូន ចេញថ្មីៗ ឬ
- ពោះឈឺឡើងរឹងនៅពេលស្ទាប ឬ
- មានការកន្ត្រាក់រឹងសាច់ដុំនៃពោះ ឬ
- ហូរឈាមចេញពីទ្វារមាស

# ការព្យាបាលជម្ងឺការឈឺចុកចាប់ផ្នែកក្រោមនៃពោះ

**អ្នកជម្ងឺមិនសំរាកពេទ្យ :**

<u>ចំពោះមេរោគហ្គោណូកូក</u>

- Cefixime, 400mg លេបតែម្តងគត់ ឬ
- Ceftriaxone, 250mg ចាក់សាច់ដុំតែម្តងគត់ ឬ
- Spectinomycin, 2g ចាក់សាច់ដុំតែម្តងគត់

**រួមជាមួយ**

<u>ចំពោះមេរោគក្លាមីឌីយ៉ា</u>

- Doxycycline, 100mg លេប ២ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ

**រួមជាមួយ**

<u>ចំពោះមេរោគបាក់តេរីអាណាអេរ៉ូបី</u>

- Metronidazole, 500mg លេប ២ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ



# ការព្យាបាលជម្ងឺការឈឺចុកចាប់ផ្នែកក្រោមនៃពោះ

**អ្នកជម្ងឺសំរាកពេទ្យ :**

<u>ចំពោះមេរោគហ្គោណូកូក</u>

- Ceftriaxone, 250mg ចាក់សាច់ដុំ ១ថ្ងៃម្តង

**រួមជាមួយ**

<u>ចំពោះមេរោគក្លាមីឌីយ៉ា</u>

- Doxycycline, 100mg លេប ឬចាក់តាមសសៃ ១ថ្ងៃ ២ដង

**រួមជាមួយ**

<u>ចំពោះមេរោគបាក់តេរីអាណាអេរ៉ូបី</u>

- Metronidazole, 500mg លេប ឬចាក់តាមសសៃ ១ថ្ងៃ ២ដង

**កំណត់សំគាល់:** គ្រប់ឱសថទាំងអស់ត្រូវតែបន្តការព្យាបាលយ៉ាងហោចណាស់ឱយបាន២ថ្ងៃបន្ទាប់ពីអ្នកជម្ងឺធូរស្រាល រួចត្រូវបន្តការព្យាបាលដោយប្រើឱសថ doxycycline និង metronidazole លេប ១ថ្ងៃ២ដងរយៈពេល ១៤ថ្ងៃ ។

**ចៀសវាងប្រើប្រាស់ជាតិអាល់កុល ពេលកំពុងប្រើឱសថ** metronidazole ។



# ការតាមដាន និងការគ្រប់គ្រងដៃគូរួមភេទ

- ចំពោះអ្នកជម្ងឺមិនសំរាកពេទ្យ ៣ថ្ងៃត្រូវពិនិត្យឡើងវិញដើម្បីធានាថាអ្នកជម្ងឺមានការធូរស្រាល ។ បើសិនជាអ្នកជម្ងឺមិន ធូរស្រាលចាំបាច់ត្រូវព្យាបាលដោយការចាក់តាមសសៃ និងឱយអ្នកជម្ងឺសំរាកនៅមន្ទីរពេទ្យ ។
- គ្រប់ដៃគូរួមភេទរបស់អ្នកជម្ងឺ (២ខែកន្លងទៅ) ត្រូវទទួលការព្យាបាល ជម្ងឺបង្កឡើងដោយប្រមេះទឹកបាយ និងក្លាមីឌីយ៉ា ។

# ម៉ូឌុលទី ៣.៦

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ការបង្ករោគនៅរន្ធគូទ

(Ano-rectal infections )



## វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ការបង្ករោគនៅរន្ធគូទ



## បែបផែននៃការចំលងរោគចំពោះបុរសរួមភេទជាមួយបុរស (Mode transmission in MSM)

- Penile penetration ( ការស៊កកបញ្ចូលលឹង្គ )
- Fingers ( ម្រាមដៃ)
- Analingus, oral-anal contact ( រន្ធគូទ-លឹង្គ , ការប៉ះពាល់មាត់ជាមួយរន្ធគូទ)
- Sex toy ( គ្រឿងប្រដាប់រួមភេទ )
- Objects used in sexual manner
- Iatrogenic (from unclean clinic condition)



## មូលហេតុនៃការបង្ករោគនៅលើពោះវៀន ឬ រន្ធគូទតាមរយៈការរួមភេទ

**(Sexually transmissible causes of intestinal or anal infections)**

ចំពោះបុរសរួមភេទជាមួយបុរសមេរោគដែលបង្ករោគនៅលើរន្ធគូទ និងពោះវៀនតូចរួមមាន:

**1- Bacterial pathogens**

-Neisseria gonorrhoeae

-Chlamydia trachomatis

-Haemophilus ducreyi

-Treponema pallidum

-Calymmatobacterium granulomatis

# មូលហេតុនៃការបង្ករោគនៅលើពោះវៀន ឬ រន្ធគូថតាមរយៈការរួមភេទ

**(Sexually transmissible causes of intestinal or anal infections)**

ចំពោះបុរសរួមភេទជាមួយបុរសមេរោគដែលបង្ករោគនៅលើរន្ធគូទ និងពោះវៀនតូចរួមមាន:

**2- Enteric bacterial pathogens**

-camphylobacter spp

-salmonella spp

-shigella spp

-yersinia spp

**3- Virus**

-Herpes simplex virus (HSV)

-HPV

-Hepatitis A, B

-HIV



# មូលហេតុនៃការបង្ករោគនៅលើពោះវៀន ឬ រន្ធគូថតាមរយៈការរួមភេទ

**(Sexually transmissible causes of intestinal or anal infections)**

ចំពោះបុរសរួមភេទជាមួយបុរសមេរោគដែលបង្ករោគនៅលើរន្ធគូទ និងពោះវៀនតូចរួមមាន:

**4- Protozoa**

-Giardia lambia

-Entamoeba histolytica

-Amoebae

-Cryptosporidia spp

**3- Parasitic infections**

-Scabies

-Lice



# គំនូសបំព្រួញស្តីពីជម្ងឺកាមរោគនៅលើរន្ធគូថ ( គ្មានរោគសញ្ញា)

(ANORECTAL STIs IN ASYMPTOMATIC PATIENTS)






# គំនូសបំព្រួញស្តីពីជម្ងឺកាមរោគនៅលើរន្ធគូថ ( មានរោគសញ្ញា)

(ANORECTAL STIs IN ASYMPTOMATIC PATIENTS)



## រោគសញ្ញាគ្លីនិកនៃការរលាកចុងពោះវៀនធំ (Symptoms of Proctitis)

- រលាកចុងពោះវៀនធំ គឺជាការរលាកស្រទាប់ មុយកឺរបស់រន្ធគូទ
- រោគសញ្ញា :

  - ទល់លាមក (constipation)

  -ឈឺបត់ជើងធំតែមិនចេញលាមក (tenemus)

  -អារម្មណ៏ ឈឺ ឬក្រហល់ក្រហាយ រន្ធគូទ (discomfort or pain)

  -បត់ជើងលាមកមានឈាម (bloody stools)

  -ហូរខ្ទុះចេញពីទ្វារលាមក (mucopurelent rectal discharge)

  -ជួលកាល ធ្វើឱយអ្នកជម្ងឺមានការភ័ន្ត ច្រឡំថា រាគ (diarrhea)



រលាកចុងពោះវៀនធំ (proctitis)



## រោគសញ្ញាគ្លីនិកនៃការរលាកពោះវៀនតូច (Symptoms of Enteritis)

- ការរលាកពោះវៀនតូចគឺជាការរលាកផ្នែកដើម-កណ្តាល និងផ្នែកខាង ចុងពោះវៀនតូច (duodenum, jejunum and ileum)
- រោគសញ្ញា (symptoms):

  –រាគ (diarrhea)

  –ចុកពោះ (bdominal pain) . ហើមពោះ (bloating) . រមួលពោះ (cramps) និងក្អួតចង្អោរ (nausea)

  –ហូររំអិលចេញពីទ្វារលាមក (mucous rectal discharge) .

  –ករណើធ្ងន់ធ្ងរជុះលាមកខ្មៅ (severe cases,melana)

  -រោគសញ្ញាផ្សេងទៀតដូចជា: ក្តៅខ្លួន (fever) ការបាត់បង់ជាតិទឹក (dehydratation) វិបត្តិនៃការស្រូបអាហារនៅពោះវៀន (malabsorption) ស្រកទំងន់ (weight loss) និងឈឺចុកចាប់តាមសាច់ដុំ (myalgia).



## មូលហេតុ និងរោគសញ្ញាគ្លីនិក នៃដំបៅជុំវិញរន្ធគូទ

**(Cuase & Symptoms of Perianal lesions)**

- ជាទូទៅដំបៅនៅជុំវិញរន្ធគូទបណ្តាលមកជម្ងឺ

  -ស្វាយ (syphilis)

  -ពងបែកលើប្រដាប់បន្តពូជ (HSV)

  -ឆ័នក្រយ (chancroid)

  -ហើមគ្រលាន ( inguinal)

  -ជម្ងឺសិរមាន់ (genital warts)

- រោគសញ្ញាសំខាន់ៗនៃការបង្ករោគនៅតំបន់រន្ធគូទ

  - ឈឺចុកចាប់ (painful)

  -ទល់លាមក (constipation)

  -មានអារម្មណ៏បត់ជើងធំតែមិនចេញលាមក (tenesmus)



Perianal chancre (syphilis)



Rectal HSV infection



## រោគសញ្ញាគ្លីនិកនៃការរលាកបំពង់ក (Symptoms of Pharyngeal)

- អវត្តមាននៃការបណ្តុះមេរោគ ឬការធ្វើតេស្ត nucleic acid amplification
  ការធ្វើរោគវិនិច្ឆ័យជម្ងឺរលាកបំពង់កអាចសង្ស័យតែមួយគត់ដោយផ្អែកទៅលើលក្ខណៈដូចតទៅ:

  -មានប្រវត្តិរួមភេទថ្មីៗតាមមាត់ (oral sex) ជាមួយដៃគូដែលមានការបង្ករោគ (infected partner)

  -អ្នកជម្ងឺមានរោគសញ្ញាលើប្រដាប់បន្តពូជ (genital symptoms)
- អ្នកជម្ងឺមានការប្រឈមមុខទៅនឹងការឆ្លងមេរោគ ដូច្នេះអ្នកជម្ងឺគួរតែទទួលនូវការព្យាបាល ជម្ងឺរលាកបំពង់កបង្កឡើងដោយមេរោគប្រមេះទឹកបាយ និងក្លាមីឌីយ៉ា
- ការរលាកបំពង់កដែលបង្កឡើងដោយមេរោគប្រមេះទឹកបាយ វាមិនស្តែងចេញច្បាស់ ដូច ការបង្ករោគនៅលើបង្ហួរនោមទេ ។



រលាកបំពងក ដោយមេរោគហ្គោណូកូក (pharyngeal gonorrhoea)

## រោគវិនិច្ឆ័យ (Diagnosis)

១- ការស្រង់ប្រវត្តិ និងពិនិត្យជម្ងឺ (history & examination)

- ស្រង់ប្រវត្តិជម្ងឺដោយសាកសួរពីៈ រោគសញ្ញា(symptoms) បែបផែននៃការរួមភេទ (type of sexual practices) ការប្រើប្រាស់ស្រោមអនាម័យ (codom use) ការប៉ះពាល់មេរោគដែលជាមូលហេតុបង្កអោយកើត ជម្ងឺ proctitis, proctololitis, enteritis
- គ្រូពេទ្យត្រូវពិនិត្យរន្ធគូទ និងឆ្លុះរន្ធគូទរកមើលភាពមិនធម្មតានៃភ្នាសមុយកឺ

២- តេស្តមន្ទីពិសោធន៍ (laboratory)

- បំពាក់ពិណក្រាម (Gram stained smear)លើសារធាតុសរីរៈយកចេញពីរន្ធគូទ ( គោលិកា ស ≥ ៥ បញ្ជាក់ថា proctitis )
- បណ្តុះមេរោគ ហ្គោណូកូក, ក្លាមីឌីយ៉ា (cultures for Neisseria gonorrhoea, chlamydia)
- ក្នុងករណីមានពងបែកជុំវិញរន្ធគូទ ត្រូវធ្វើតេស្តបន្ថែមដូចជាៈ RPR or VDRL & TPPA
- ពងបែកលើប្រដាប់បន្តពូជៈ តេស្ត nucleic acid amplification



## រោគវិនិច្ឆ័យ (Diagnosis)

បើសិនជា enteritis ឬ proctocolitis ដោយផ្អែកទៅលើ រោគសញ្ញាមួយចំនួន ដូចជាៈ

-ក្តៅខ្លួន (fever) ,

-រាគឈាម (bloody diarrheal ) ,

-រាគភក់ៗយូរៈ រយៈពេល០១សប្តាហ៏ (milder diarrheal symptoms persisting one week)

-បណ្តុះលាមករកមេរោគៈ salmonella, shigella, campylobacter

-ពិនិត្យលាមក រកមើល ពង និង ប៉ារ៉ាស៊ីត (ova and parasites)



## ការព្យាបាលជំងឺរលាកចុងពោះវៀនធំ (Teatment for Proctitis)

១) ព្យាបាលជម្ងឺរលាកចុងពោះវៀនធំបង្កដោយមេរោគ Gonococcal:

ជំរើសទី១: Cefixime 400mg លេបតែ ១ ដងគត់ ឬ

ជំរើសទី២: Spectinomycin 2g ឬ Ceftriaxone 250mg ចាក់សាច់ដុំតែ ១ ដងគត់ ។

**រួមជាមួយនឹង**

២) ព្យាបាលជម្ងឺរលាកចុងពោះវៀនធំបង្កដោយមេរោគ Chlamydia:

ជំរើសទី១: Azithromycin 1g លេប តែម្តងគត់ឬ

ជំរើសទី២: - Doxycycline 100mg លេប ២ ដង ក្នុងមួយថ្ងៃ រយៈពេល ៧ ទៅ ១៤ ថ្ងៃ ឬ

- Erythromycin 500mg លេប ៤ ដង ក្នុងមួយថ្ងៃ រយៈពេល ៧ ថ្ងៃ ។



## ការព្យាបាលជំងឺផ្សេងៗទៀត (Treatment for other diseases)

ព្យាបាលជម្ងឺបង្កដោយមេរោគ Giardia:

- Metronidazole 400mg លេប២ដង ក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

ព្យាបាលជម្ងឺបង្កដោយមេរោគ Amebic:

- Metronidazole 500mg លេប៣ដង ក្នុងមួយថ្ងៃ រយៈពេល ១០ថ្ងៃ

ព្យាបាលជម្ងឺបង្កដោយមេរោគ Shigella:

- Ciprofloxacin 500mg លេប២ដង ក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

ព្យាបាលជម្ងឺបង្កដោយមេរោគ Campylobacter enteritis:

- Ciprofloxacin 500mg លេប២ដង ក្នុងមួយថ្ងៃ រយៈពេល ៧ ថ្ងៃ

## ការព្យាបាលជំងឺផ្សេងៗទៀត (Treatment for other diseases)

**ព្យាបាលផ្ទឹមធំពៅរន្ធគូទ:**

-សូមអានទំព័រស្តីពីការព្យាបាលដំបៅលើប្រដាប់បន្តពូជ

**ព្យាបាលផ្ទឹ Pharyngeal gonococcal :**

ជំរើសទី១: Cefixime 400mg លេបតែ ១ ដងគត់ **ឬ**

ជំរើសទី២: Ceftriaxone 250mg ចាក់សាច់ដុំតែ ១ ដងគត់ ។

*រួមជាមួយនឹង*

**២) ព្យាបាលផ្ទឹ Pharyngeal chlamydia:**

ជំរើសទី១: Azithromycin 1g លេប តែម្តងគត់ឬ

ជំរើសទី២: - Doxycycline 100mg លេប ២ ដង ក្នុងមួយថ្ងៃ រយះពេល ៧ ទៅ ១៤ ថ្ងៃ

# ម៉ូឌុលទី ៣.៧

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល
## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ជម្ងឺហើមក្រលៀន និងហើមពងស្វាស

**(Inguinal Bubo & Scrotal Swelling )**



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល

  ជំងឺហើមក្រលៀន និងហើមពងស្វាស



# គំនូសបំព្រួញសំរាប់ការហើមក្រលៀន






# ហើមកូនកណ្តុរក្រលៀន
**(Inguinal’Bubo )**

- ការហើមក្រលៀន គឺកូនកណ្តុរមានការរីកមាឌធំនៅតំបន់ក្រលៀន
- កូនកណ្តុរមានលក្ខណៈទន់ ឈឺ (tender inguinal) និងភាគច្រើនកើតនៅលើក្រលៀន តែម្ខាង (unilateral) ដំបៅ (ulcer) ពេលខ្លះមានករខ្ទុះ (inoculation) ទៀតផង ។
- ជម្ងឺនេះបង្កឡើងដោយមេរោគក្លាមីឌីយ៉ា ប្រភេទ L1-L2-L3 និងជាញឹកញាប់ជម្ងឺនេះតែងតែលាយឡំជាមួយជម្ងឺ chancroid
- ការហើមក្រលៀនដែលមិនមែនជាជម្ងឺកាមរោគដូចជា: ការបង្ករោគនៅផ្នែកក្រោមនៃជើង (infection of the lower limb) ឬ របេងកូនកណ្តុរ (tuberculous lymphadenopathy)
- ការធ្វើរោគវិនិច្ឆ័យគឺផ្អែកទៅលើ លក្ខណៈគ្លីនិក (clinical) ឬ អេពីដេមីសាស្ត្រ (epidemiologic)



Inguinal bubo

# ការព្យាបាលជម្ងឺហើមគ្រលៀន

**១-** <u>**ការព្យាបាលជំងឺ** Chancroid:</u>

– Azithromycin 1g លេបតែ ១ ដងគត់ **ឬ**

– Ciprofloxacin 500mg លេប ១គ្រាប់ម្តង១ថ្ងៃ២ ដង រយៈពេល ៣ថ្ងៃ **ឬ**

**២-** <u>**ការព្យាបាលជំងឺ** Lymphogranuloma venereum:</u>

– Doxycycline 100mg លេប២ ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ **ឬ**

– Erythromycin 500mg លេប៤ ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ

<u>**ចំណាំ :**</u> កំណត់ចំណាំៈ ករណីខ្លះការព្យាបាលអាចមានរយៈពេលលើសពី១៤ថ្ងៃ ។ កូនកណ្តុរដែលករខ្ទុះ គួរតែ ធ្វើការបូមខ្ទុះ នោះចេញនៅត្រង់កន្លែងស្បែកស្អាត ។ មិនត្រូវធ្វើការវះកាត់កន្លែងនោះទេ ពីព្រោះវាបណ្តាលឱយយូរជា ស្បះស្បើយ ។



## ការពិនិត្យវិនិច្ឆ័យពិសេសចំពោះអ្នកដែលមានផ្ទុកមេរោគអេដស៍ (HIV infection)

- អ្នកជម្ងឺដែលហើមគ្រលៀន និងមានផ្ទុកមេរោគអេដស៍ ការព្យាបាលគឺដូចគ្នានឹងអ្នកជម្ងឺដែលគ្មានផ្ទុកមេរោគអេដស៍ដែរ ។
- ការព្យាបាលអាចប្រើរយៈពេលយូរបើសិនអ្នកជម្ងឺមិនទាន់បាត់រោគសញ្ញា ឬ មិនទាន់ជាស្បះស្បើយ ។



# គំនូសបំព្រួញសំរាប់ការហើមពងស្វាស






# ការព្យាបាលការហើមពងស្វាស

<u>*១-ការព្យាបាលជំងឺហើមពងស្វាសបង្កដោយ Gonorrhoea*</u>

<u>ជំរើសទី១:</u> Cefixime 400 mg លេបតែមួយដង **ឬ**

<u>ជំរើសទី២:</u> Spectinomycin 2g ឬ Ceftriaxone 250mg ចាក់សាច់ដុំតែម្តង

រួមជាមួយនឹងៈ

<u>*២-ការព្យាបាលជំងឺហើមពងស្វាសបង្កដោយមេរោគ Chlamydia*</u>

<u>ជំរើសទី១:</u> Doxycycline 100mg លេប២ ដង ក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ

<u>ជំរើសទី២:</u> Erythromycin 500mg លេប៤ ដង ក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ ។

# ម៉ូឌុលទី ៣.៨

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបន្តរោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ជម្ងឺរលាកភ្នែកចំពោះទារកដែលទើបនឹងកើត

(Neonatal Conjunctivitis )



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ជំងឺរលាកភ្នែកចំពោះទារកដែលទើបនឹងកើត



# ជម្ងឺរលាកភ្នែកលើទារកទើបនឹងកើត

(Neonatal Conjunctivitis )

- ជម្ងឺរលាកភ្នែកនៅលើទារកទើបនឹងកើតបង្កឡើងដោយមេរោគប្រមេះទឹកបាយ និងក្លាមីឌីយ៉ា
- ជម្ងឺនេះអាចបណ្តាល ឱយទារក ខ្វាក់ភ្នែក បើមិនបានព្យាបាល ឬព្យាបាលមិនត្រឹមត្រូវ
- រោគសញ្ញាសំខាន់ៗនៃជម្ងឺរលាកភ្នែកលើទារកទើបនឹងកើត ដូចជា: ភ្នែកឡើងក្រហម . ហើមត្របកភ្នែក ឬភ្នែកបើកមិនរួច ឬមានហូខ្ទុះចេញពីភ្នែក
- អ្នកផ្តល់សេវាត្រូវផ្តល់ការព្យាបាលមេរោគពីរ តែម្តង ( ប្រមេះទឹកបាយ និងមេរោគក្លាមីឌីយ៉ា)



ជម្ងឺរលាកភ្នែកនៅលើទារកទើបនឹងកើត



# គំនូសបំព្រួញសំរាប់ការរលាកភ្នែកលើទារកទើបនឹងកើត



## ការបង្ការជម្ងឺលោកភ្នែកលើទារកទើបនឹងកើត

(Prevention of opthalmia neonatorum)

- បន្ទាប់ពីទារកកើតភ្លាមត្រូវជូតសំអាត ភ្នែកដោយប្រុងប្រយ័ត្ន
- បន្តក់សូលុយស្យុង siver nitrate 1% ឬ
- ដាក់ប៉ូម៉ាត tetracycline 1% លើភ្នែកសង ខាងរបស់ទារក
- ការបង្ការនេះត្រូវអនុវត្តគ្រប់ទារក ដែល ទើបកើត





## ការព្យាបាលជម្ងឺលោកភ្នែកលើទារកទើបនឹងកើត

(Treatment of neonatal conjunctivitis)

គ្រប់ទារកទើបនឹងកើត មានជម្ងឺរលាកភ្នែក អ្នកផ្តល់សេវាត្រូវតែផ្តល់ការព្យាបាលជំងឺបង្កឡើងដោយ មេរោគប្រមេះទឹកបាយ និង មេរោគក្លាមីឌីយ៉ា ក្នុងពេលតែមួយ ពីព្រោះភាគច្រើនជម្ងឺនេះ មានការបង្ករោគចំរុះ (mixed infection)

**មេរោគប្រមេះទឹកបាយ (N. gonorrhoeae)**

- Ceftriaxone 50mg/kg (maximum: 125mg) ចាក់សាច់ដុំតែម្តងគត់

**រួមជាមួយ**

**មេរោគក្លាមីឌីយ៉ា (C. trachomatis)**

Erythromycin base ឬ Ethylsuccinate ផឹក៤ដងក្នុង១ថ្ងៃ រយៈពេល១៤ ថ្ងៃ



## ការគ្រប់គ្រងម្តាយ និងដៃគូរួមភេទ

(Management of Mother and their Sex Partner)

- ម្តាយរបស់ទារក និងដៃគូដែលមានការបង្ករោគដោយ មេរោគហ្គោណូកូក និងក្លាមីឌីយ៉ា ត្រូវធ្វើការព្យាបាលជម្ងឺនេះ ដោយផ្អែកទៅតាមគោលការណែនាំរបស់ជាតិ ស្តីពីការព្យាបាលជម្ងឺ បង្កឡើងដោយមេរោគហ្គោណូកូក និងក្លាមីឌីយ៉ា នៅលើមនុស្សធំ (adults) ។



# ម៉ូឌុលទី ៣.៩

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ជម្ងឺសិរមាន់លើប្រដាប់បន្តពូជ

## (GENITAL WARTS)



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្ត្រនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺសិរមាន់លើប្រដាប់បន្តពូជ



# គំនូសបំព្រួញសំរាប់ជំងឺសិរមាន់លើប្រដាប់បន្តពូជ






# ជម្ងឺសិរមាន់លើប្រដាប់បន្តពូជ (genital warts)

- ការបង្ករោគគឺចំលងតាមរយៈ:
  - ទឹករំអិល និងការដាច់រលាត់ស្បែកនៅពេលរួមភេទ
  - ពីម្តាយទៅកូន ( ឆ្លងតាមទងសុក. ពេលសំរាល ឬក្រោយពេលសំរាល) ប៉ុន្តែវាមិនទាំងអស់នោះទេ
- ប្រភេទ HPV ដែលគេជួបប្រទះញឹកញាប់គឺ HPV-6, HPV-11, HPV-16
- ប្រភេទពិសេសនៃវីរុស HPV អាចបង្កឱយមានជម្ងឺមហារីកនៅលើមាត់ស្បូន ។ ជាអនុសាសន៏ គ្រប់ស្រ្តីទាំងអស់ដែលមានជម្ងឺកាមរោគគួរតែធ្វើការពិនិត្យមើលស្បូន និងធ្វើការស្រាវជ្រាវមាត់ស្បូន (cervical smear) ឱយបានទៀងទាត់តាមរយៈការធ្វើតេស្ត Papanicolaou





## ជម្ងឺសិរមាន់លើប្រដាប់បន្តពូជ (genital warts)

- ជាទូទៅការដុះសាច់លើប្រដាប់បន្តពូជមានលក្ខណៈជា : flat, papular pedunculated
- ការដុះសាច់លើប្រដាប់បន្តពូជ អាចកើតនៅលើ មាត់ស្បូន (cervix), ទ្វារមាស (vagina) , បង្ហួរនោម (urethra), រន្ធគូទ (anus)
- ការដុះសាច់លើប្រដាប់បន្តពូជ គឺមិនបង្កឱ្យមានការឈឺចាប់ (painless) និងបណ្តាលឱ្យមានផលវិបាកធ្ងន់ធ្ងរទេ លើកលែងតែ ជម្ងឺនេះអាចបង្កមាន ឧបសគ្គ ជាពិសេសនៅលើស្រ្តីមានផ្ទៃពោះ ។
- អ្នកជម្ងឺដែលដុះសាច់នៅលើរន្ធគូទ និងប្រដាប់បន្តពូជ គួរតែដឹងថាពួកគេអាចចំលងជម្ងឺនេះទៅដល់ដៃគូរួមភេទពួកគេ ។ ការប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវ និងជាប់ជាប្រចាំអាចជួយកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងជម្ងឺ .
- គួរតែពិនិត្យដៃគូរួមភេទរបស់អ្នកជម្ងឺ ក្រែងមានដុះសាច់លើប្រដាប់បន្តពូជ



## ការព្យាបាលជម្ងឺសិរមាន់

- ប្រើ Podophyllotoxin 0.5% solution or cream លាបមួយថ្ងៃ ២ដងរយៈពេល ៣ថ្ងៃ បន្ទាប់មកតាមដានរយៈពេល៤ថ្ងៃ ។ ប្រើរបៀបនេះ មួយសប្តាហ៍ម្តង រយៈពេល ០៤សប្តាហ៍ ( មិនត្រូវលើសពី ០.៥មីល្លីលីត្រក្នុងមួយថ្ងៃ) ។ ឬ
- ប្រើ Imiquimod 5% cream លាបនៅលើកន្លែងដុះសាច់ មុនពេលចូលគេង ទុកវារយៈពេលមួយយប់ ប្រើរបៀបនេះ ៣ដងក្នុងមួយសប្តាហ៍ រហូតដល់រយៈពេល ១៦សប្តាហ៍ ។ រយៈពេល ៦-១០ម៉ោង ក្រោយពីលាបត្រូវលាងសំអាត ជាមួយ សាប៊ូ និងទឹក ត្រូវលាងដៃចេញភ្លាម ជាមួយទឹកនិង សាប៊ូ ក្រោយប៉ះថ្នាំនោះ ។



## ការព្យាបាលជម្ងឺសិរមាន់

បែប Chemical

- ប្រើ Podophyllin 10-25% លាបនៅលើកន្លែងដុះសាច់ប្រដាប់បន្តពូជ ឬ ជុំវិញរន្ធគូទ ដោយប្រុងប្រយ័ត្ន ដោយទុករយៈពេល១-៤ម៉ោង បន្ទាប់មកត្រូវលាងទឹកចេញ ។ លាប១សប្តាហ៍ម្តង រយៈពេល ៤-៦សប្តាហ៍ ( ត្រូវចៀសវាងប៉ះពាល់លើកន្លែងជាលិកាធម្មតា) ។
- ប្រើ TCA 80-90% លាបនៅលើកន្លែងដុះសាច់ ដោយប្រុងប្រយ័ត្នដោយប្រើលាយ ជាមួយម្សៅតាល់ ឬ សូដ្យូមប៊ីការបូណាត (sodium bicarbonate) ដើម្បីជួយកាត់បន្ថយជាតិអាស៊ីត លាបឡើងវិញរយៈពេល០១សប្តាហ៍ម្តង ។



## ការព្យាបាលជម្ងឺសិរមាន់

បែប Physical

- Cryotherapy liquid nitrogen ឬ cryoprobe រៀងរាល់ ១-២សប្តាហ៍ម្តង ឬ
- ដុតដោយម៉ាស៊ីនអគ្គីសនី (Electrosurgery)
- វះកាត់យកចេញ (Surgical removal)

<u>ក-ការព្យាបាលនៅលើទ្វារមាស</u>

- Cryotherapy liquid nitrogen ឬ
- Podophillin 10-25% ដោយទុកកន្លែងនោះឱ្យស្ងួតមុនពេលដកចំពុះទាចេញ ឬ
- TCA 80-90% ឬ
- ដុត ដោយម៉ាស៊ីនអគ្គីសនី (Electrosurgery)

# ម៉ូឌុលទី ៣.១០

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល
## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

# ជម្ងឺសើស្បែកកំរជួបប្រទះ
# ដែលបង្កឡើងតាមតាមការរួមភេទ
## (RARE STI/RTI WITH CUTANEOUS INFESTATION)



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីវិធីសាស្រ្តនៃការធ្វើរោគវិនិច្ឆ័យនិងព្យាបាលការបង្ករោគ
  តាមការរួមភេទ និងប្រដាប់បន្តពូជជាមួយនឹងជំងឺសើស្បែក ដែលកំរជួបប្រទះ



## Molluscum Contagiosum

- ជម្ងឺ Molluscum contagioum បង្កឡើងដោយវីរុស apox virus
- ជាធម្មតាជម្ងឺនេះកើតឡើងនៅលើប្រដាប់បន្តពូជ ហើយ ឆ្លងតាមការ រួមភេទ
- **រោគសញ្ញាគ្លីនិក** (CLINICAL FEATURES)
- ស្នាម lesion molluscum contagioum គឺវាមានលក្ខណៈ ដាច់តែឯង (discrete).ពកររលោង (smooth pearly) ឬ ពណ៌ស្រស់ (fresh) មានកំពូលសណ្ឋានជាស្នាមកន្ទួល (dome shaped papules)
- ភាគច្រើនកើតនៅតំបន់ប្រដាប់បន្តពូជ
- បាតស្នាមកន្ទួលនិមួយៗ អាចមានពណ៌ក្រហមល្មម (mildly erythematous base) និងនៅចំចំណុចកណ្តាល មានស្នូលពណ៌សដូចដូចទឹកដោះគោ កក ( a central punctum beneath which lies a white curdlike core )







## តេស្តមន្ទីរពិសោធន៍ និងការព្យាបាល
## (LABORATORY TESTS AND TREATMENT)

- សង្កត់យកគ្រាប់ស្នូល (expressed core from punctum) បំពាក់ពណ៌ Giemsa ឬ ធ្វើ biopsy ស្បែក និងបង្ហាញវត្តមាន molluscum bodies
- ជាធម្មតាជម្ងឺនេះអាចបាត់ទៅវិញដោយឯកឯង (heal spontaneously).
- ការព្យាបាលមិនមែនជាការ ចាំបាច់ទេ (treatment is not mandatory )

  -ប្រើ curette មុតស្រួច ឬម្ជុល ឆ្កឹះយកស្នូលដុះពកចេញ

  -ដុតបំផ្លាញដុំពក (lesion) ដោយប្រើសូលុយស្យុង nitrogen ឬ លាបអាស៊ីត trichloroacetic ឬម៉ាស៊ីនដុត (electrocauter) .

  -ជាញឹកញាប់ការព្យាបាលត្រូវការច្រើនដង
- លើកទឹកចិត្តឱយអ្នកជម្ងឺបញ្ជូនដៃគូរួមភេទមកពិនិត្យ និងទទួលការព្យាបាលបើសិនជាមានរោគសញ្ញា ។

## Pediculosis Pubis





- គឺជាការរាលដាលនៃពពួកប៉ារ៉ាស៊ីតនៅតំបន់រន្ធគូទនិងប្រដាប់បន្តពូជ ដែលបង្កដោយពពួកចៃជើងប្រាំបី (crab louse) phthirus pubis
- ជម្ងឺនេះឆ្លងតាមការរួមភេទ
- **រោគសញ្ញាគ្លីនិក**

  - ចៃពិណពោតនៅលើស្បែកថ្ងាស (brown adult lice on the pubic skin) និងពងចៃនៅលើរោមថ្ងាស (ova on pubic hair shafts)

  - ស្នាម ចំណុចចេញឈាមនៅលើ ស្បែកថ្ងាស/ប្រដាប់បន្តពូជ និងខោទ្រនាប់ផងដែរ (small haemorrhagic spots on the pubic/genital skin and underwear)



## តេស្តមន្ទីរពិសោធន៍ និងការព្យាបាល
(LABORATORY TESTS AND TREATMENT)

- ការធ្វើរោគវិនិច្ឆ័យតេស្តមន្ទីរពិសោធន៍បង្ហាញវត្តមានចៃ ឬ ពងចៃនៅលើរោមថ្ងាស (lice or nits from pubic hair).
- លាប Malathion lotion 0.5% រយៈពេល១២ម៉ោង ក្រោយលាងចេញ ឬ
- លាបក្រែម Permethrin 1% រយៈពេល១០នាទីក្រោយលាងចេញ ឬ
- ប្រើសាប៊ូ Lindane 1% រយៈពេល៤នាទីក្រោយលាងចេញ (ហាមប្រើលើស្ត្រីមានផ្ទៃពោះ ឬបំបៅ ដោះកូន) ឬ
- បើកើតនៅលើរោមភ្នែក (eyelashes) ត្រូវប្រើប៉ូម៉ាត (opthalmic ointment) ឬប្រេងវ៉ាស្លីន (vasoline) លាបលើត្របកភ្នែកសិន (eyelid) ។Lindane ប្រើ១ថ្ងៃ0២ដងរយៈពេល១០ថ្ងៃ ឬប្រើចន្លៀស/ដង្កៀប ចាប់ចៃចេញ ។
- ការព្យាបាលនៅលើស្ត្រីមានផ្ទៃពោះ ឬ ឬបំបៅ ដោះកូនគួរតែប្រើ Permethrin
- ប្រាប់អ្នកជម្ងឺឱយត្រឡប់មកជួបវិញរយៈពេល៧ថ្ងៃក្រោយ ។ បើសិនជាឃើញមានចៃ ឬពងចៃ ត្រូវធ្វើការព្យាបាលឡើងវិញ។
- ត្រូវហៅដៃគូរួមភេទទៀងទាត់ក្នុងកំឡុងពេលមួយខែកន្លងមកឱយមកពិនិត្យ និងទទួលការព្យាបាល ។



## Scabies



- គឺជាការបង្ករោគដោយពពួកប៉ារ៉ាស៊ីត sarcoptes scabei var hominis
- **លក្ខណៈគ្លីនិក** (Clinical features)

  -ស្នាមកន្ទួលរមាស់ នៅលើ ប្រដាប់បន្តពូជ, ចង្អែកដៃ, ករដៃ, ក្លៀក, និង កំប៉េះគូទ ហើយវារមាស់ខ្លាំងនៅពេលយប់

  -ចំណែកឯ សមាជិកក្រុម គ្រួសារក៏មានរោគសញ្ញាដូចគ្នាដែរ

- **តេស្តមន្ទីរពិសោធន៍** (Laborytory tests)

  - ប៉ារ៉ាស៊ីត (mite) ត្រូវបានរកឃើញដោយការពិនិត្យ មីក្រូទស្សន៍លើកំទេចស្បែកដែល កោសយកពីរន្ធស្បែក (scraping from burrwos on the skin)






## ការព្យាបាល (TREATMENT)

- ប្រើ Emulsion benzyl benzoate (EBB) 25% ចំពោះមនុស្សធំ និង 10% ចំពោះកូនក្មេងអាយុតិច ជាង១០ឆ្នាំ ដោយលាបពេញដងខ្លួន នៅពេលយប់ចាប់ពី ករចុះមកក្រោម ឬ
- ប្រើ Melathion 0.5% lotion លាបសើៗពេញ ខ្លួនទាំងអស់ ចាប់ពីករ ចុះមក និងលាងចេញវិញក្រោយពីលាបបាន ២៤ម៉ោង ប្រើរយៈពេល២យប់

***កំណត់សំគាល់: ឱសថទាំងអស់ខាងលើនេះហាមប្រើលើក្មេងអាយុតិចជាង២ឆ្នាំ ។***

***ការព្យាបាលផ្សេងទៀត:***

- ប្រើ Gamma benzene hexachloride 1% (Lindane) លាបតែម្តងនៅពេលយប់,ចៀសវាងមុជទឹក ២ ម៉ោង មុនប្រើថ្នាំ ពីព្រោះស្បែកសើមធ្វើឱយជ្រាបចូលកាន់តែខ្លាំង ។

***កំណត់សំគាល់: ហាមប្រើលើស្ត្រីមានផ្ទៃពោះ និង បំបៅដោះកូន ឬក្មេងអាយុតិចជាង២ឆ្នាំ ។***

## ការព្យាបាល (TREATMENT)

**<u>ការព្យាបាលនៅលើក្មេងអាយុតិចជាង២ឆ្នាំ</u>**

- ប្រើ Permethrine 5% creame លាបពេលយប់ ហើយប្រើម្តងទៀត នៅ១សប្តាហ៍ក្រោយមក ឬ
- ប្រើ Sulphur 6% creame លាបរយះពេល ៣-៥ យប់ ឬ
- ប្រើ Crotamiton 10% lotion (Eurax) ឱសថនេះខ្សោយក្នុងការសំលាប់ scabie ត្រូវការប្រើរយះពេល៧ថ្ងៃ

**<u>ការព្យាបាលនៅលើស្ត្រីមានផ្ទៃពោះ</u>**

- ប្រើ Emulsion benzyl benzoate (EBB) 25% ***ឬ***
- ប្រើ Permethrin 5% ***ឬ***
- ប្រើ Crotamiton 10% lotion (Eurax)

**<u>ចំពោះ Crust (Norwegian) scabies</u>**

- ជាទូទៅកើតលើអ្នកកង្វះអាហារឧបត្ថម្ភ (malnourished) ប្រព័ន្ធការពារចុះខ្សោយ (immuno-deficeint) និងអ្នកជម្ងឺដែលមានវិបត្តិសរសៃប្រសាទ (nerological disturbance) ការព្យាបាលប្រើ ឱសថបញ្ចូលគ្នា ថ្នាំលាប និងថ្នាំលេប Ievermectin (0.2mg/kg) ២-៣កំរិត រៀងរាល់ ១-២សប្តាហ៍ ។



## ការតាមដាន និងគ្រប់គ្រងដៃគូរួមភេទ

(Follow-up and Management of Sexual Partner)

- ខោអាវ និងសំភារះប្រើប្រាស់លើគ្រែត្រូវបោកគួកជាមួយទឹកក្តៅ ឬបោកស្ងួត
- ចំពោះអ្នកជម្ងឺដំបូងមានការរមាស់ខ្លាំង អាចប្រើឱសថ antihistamimines ដើម្បីបន្ធូរការរមាស់ ។
- ជាញឹកញាប់ចាំបាច់ត្រូវព្យាបាលឡើងវិញដោយប្រើឱសថផ្សេងទៀត ពីព្រោះបណ្តាលមកពីភាព បរាជ័យក្នុងការព្យាបាល ដូចជា មេរោគស៊ាំជាមួយថ្នាំ, ការប្រើខុសបច្ចេកទេស, ការជ្រាបថ្នាំចូលមិនល្អ ព្រោះក្រម៉ក្រាស់, ថ្នាំមិនចូលទៅដល់តំបន់ដែលមានពពួកប៉ារ៉ាស៊ីត(mites) និងមានការឆ្លងរោគសារជាថ្មី ។
- រមាស់អាចមានរយះពេល ២ - ៣សប្តាហ៍ក្រោយព្យាបាល ដូច្នេះត្រូវប្រើ steroids និង antihistamine ។
- ដៃគូរួមភេទ និងសមាជិកក្រុមគ្រួសារដែលមានការប៉ះពាល់ត្រូវតែព្យាបាលទោះជាគ្មានរោគសញ្ញាក៏ ដោយ ។



## Scabicide

| Scabicide | Frequency of application | Toxicity |
|---|---|---|
| Permethrin 5% cream | One application left on over 8–12 hours | Low |
| Malathion liquid emulsion | One application left on over 4 hours | Low |
| Benzyl benzoate | Two applications over 48 hours | Low |
| Lindane | Two applications 72 hours apart | Medium |
| Sulfur ointment | Each night for 3 nights | Low |

# ម៉ូឌុលទី ៣.១១

## ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល

## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

## ជម្ងឺដំបៅ/ដុំពកលើប្រដាប់បន្តពូជដែលមិនមែនជាជម្ងឺកាមរោគ

**(Non STI Genital Lesions)**



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃម៉ូឌុលនេះ សិក្ខាកាមនឹងអាច :**

- កំណត់បានត្រឹមត្រូវពីដំបៅ/ដំពកលើប្រដាប់បន្តពូជដែលមិនមែនជាជំងឺកាមរោគ



## ការរលាកស្បែកនៅលើប្រដាប់បន្តពូជ

**INFLAMMATORY DERMATOSES OF THE GENITALS**

- ជម្ងឺភ្លឺ (psoriasis) ជាទូទៅបណ្តាលមកពីប្រតិកម្មនៃការរលាក (inflammatory reaction) ដែលកើតមាននៅលើប្រដាប់បន្តពូជ ហើយវាអាចមាន២ទំរង់ ។
- លេចចេញជាស្នាម បន្ទះ ពិណក្រហមភ្លឺនៅតំបន់ក្រលៀន ដូចជា inverse psoriasis
- នៅចំកណ្តាលគ្មានចំណុចច្បាស់លាស់ដែលជាទូទៅឃើញនៅក្នុង tinea
- ស្នាមបន្ទះក្រហមមានសភាពស្មើសាច់ វាអាចកើតនៅកន្លែង ផ្សេងទៀតដូចជា: ក្លៀក ឬ កន្លាក់ជើង
- វាមិនដូច psoriasis កន្លែងផ្សេងទេ inverse psoriasis អាចរមាស់ និង ជាញឹកញាប់ ពីមុនមក គ្មានប្រវត្តិកើត psoriasis ទេ។
- ជម្ងឺ psoriasis អាចកើតលើលឹង្គ ជាពិសេសលើក្បាលលឹង្គ (gland penis)
- ស្នាមបន្ទះ ពិណក្រហម ស្តើង ស្លេក, ជាមួយនឹង scale តិចតួច ដែលឃើញនៅក្នុងទំរង់ ដាច់តែឯង ឬ កំពុងកើត (discrete or continuous form)



- អត់មានពងទឹក, មិនមានការដាច់ដោច, គ្មានរមាស់ ឬក្រហាយទេ
- វាអាចបណ្តាលឱយធ្ងន់ធ្ងរដោយសារការប៉ះទង្គិច
- ជម្ងឺ psoriasis ទាំងពីរប្រភេទអាចឆ្លើយតបបានល្អជាមួយនឹង creams cortisone ដែលមានកំរិតទាប
- ហាមប្រើ steroid កំរិតមធ្យម ឬ ខ្ពស់ ដើម្បីចៀសវាង atrophy
- វាជាការល្អបើប្រើ ក្រែមដែលលាយបញ្ចូល Hydrocortisone 2.5% ជាមួយនឹង Ketonazole
- ក្រែម calcipitriol ឬ vitamine D derivative ជាជំរើសផ្សេងទៀតដែលមានលក្ខណៈជា non steroidal អាចប្រើបានលើ psoriasis កន្លែងផ្សេងទៀត ឬ psoriasis នៅលើក្បាលលឹង្គ (glans penis).



Psoriasis of the glands penis in an uncircumcised



Psoriasis of the glands penis in a circumcised

## Reiter’s disease

- ជម្ងឺ Reiter’s រួមមានរលាកសន្លាក់, រលាកបង្ហូរនោម និង រលាកសន្ទានភ្នែក ។
- ជម្ងឺនេះអាចវិវត្តន៍ទៅជា balanitis circipata ដែលមានរាងជា បន្ទះសើម (moist serpiginous plaques) មានគែមរឆញរឆ្វញពិណសនៅលើ កន្លាក់ក្បាលលឹង្គ (glans penis).







## ជម្ងឺត្រអក

## (Eczema)

- ជាញឹកញាប់កើតនៅលើតំបន់ប្រដាប់បន្តពូជ ជាពិសេសនៅលើ ស្រោមពងស្វាស
- រមាស់ខ្លាំង ហើយ ជារឿយៗមានចេញទឹករងៃ និងឡើងក្តៅ
- មាន lichennified erythematous plague នៅផ្នែកគែម នៃ ស្រោមពងស្វាស
- ជាញឹកញាប់ អ្នកជម្ងឺស្បែកខ្មៅមាន លក្ខណៈ hyperpigment ជាង erythematous ដែលធ្វើឱយគ្រូពេទ្យពិបាកក្នុងការប៉ាន់ស្មាន កំរិតនៃការរលាក
- ក្នុងករណី ស្រួចស្រាវយើងប្រើ steroide ដែលមានកំរិតទាបលាប លើ ស្បែករយៈពេលយ៉ាងច្រើន២សប្តាហ៍





## ជម្ងឺត្រអក

## (Eczema)

- ករណី រ៉ាំរ៉ៃ មានថ្នាំលាបជាច្រើនដែលអាចធ្វើឱយធូរស្រាលក្នុងរយៈពេលតែប៉ុន្មាន ម៉ោងប៉ុណ្ណោះ
- ជាញឹកញាប់អ្នកជម្ងឺមានអារម្មណ៍ថា លាងសំអាតកន្លែងដែលឈឺខ្លាំង ជាមួយសាប៊ូអាចនឹងជួយ ដោះស្រាយបញ្ហានេះបាន
- ទឹកខាប់ Zinc oxide ជួយអោយធូរស្រាលខ្លាំងណាស់ និងជួយអោយស្រូបទឹករងៃ (absorb sweat)
- ការលេចចេញនូវការរលាក (inflammatory eruption) យើងអាច ប្រើក្រែម Hydrocortisone 2.5% layCamYy Zinc oxide
- ការរលាក (eruption) អាចវិវត្តិន៍ទៅ lichen simplex រ៉ាំរ៉ៃដែលមានលក្ខណៈជា lichenification ខ្លាំង និង hypertrophy ស្បែកដែលប៉ះពាល់ ។
- លទ្ធផល lichenification គឺបណ្តាលមកពីការអេះ និងត្រដុសយូរ
- ការប្រើ antihistamines នៅពេលយប់អាចជួយបន្ធូរការ រមាស់បណ្តោះអាសន្ន



## Contact Dermatitis

- អាចចែកចេញជាទំរង់ irritant និង allergic
- តាមទ្រឹស្តីគ្រប់អ្នកជម្ងឺដែលមាន Contact dermatitis ច្រើនបណ្តលមកពីការរលាក (irritant)
- វាអាចវិវត្តន៏ទោជារ៉ាំរ៉ៃដោយការប្រើសាប៊ូ ឬសូលុយស្យុងសំលាប់មេរោគ (disinfectants or aseptic solution)
- ការរលាក (irritant) អាចឆ្លង ពីដៃទៅប្រដាប់បន្តពូជ
- ក្រែម 5-Flourracil ប្រើសំរាប់ actinic keratoses នៅលើមុខ (on the face)

## Allergic Contact Dermatitis

- លឹង្គអាចហើមធំមានពណ៌ក្រហម និងបែកស្រកា (scaling)
- ការហើមលេចចេញច្បាស់ដោយសារស្បែកមានសភាពយឺត និងស្តើង (thin elastic skin on genitalia).
- មានសារធាតុ និងឱសថជាច្រើនដែលធ្វើឱ្យមានប្រតិកម្ម (allergy) នៅពេលប្រើលើដងខ្លួន ហើយវាអាចរាលដាលទៅលើប្រដាប់បន្តពូជ
- ជាតិពុល ivy និង rhus dermatitis ជាទូទៅត្រូវបានរាលដាលពីដៃ ទៅប្រដាប់បន្តពូជ
- ជាទូទៅរបួស (lesion) អាចកើតមាននៅកន្លែងផ្សេងទៀត





## Allergic Contact Dermatitis

- ជាញឹកញាប់ ឱសថ Benzocaine ប៉ូម៉ាតអង់ទីប៊ីយូទិក ៣មុខ (triple antibiotic ointment) និង topical benadryl ជាអ្នកបង្កហេតុ ។
- ការស្រង់ប្រវត្តិនៃ ការប្រើប្រាស់ឱសថជាការសំខាន់ណាស់: ឱសថផ្សេងៗមួយចំនួនដែលអ្នកជម្ងឺប្រើសំរាប់អនាម័យ ឬ ជម្ងឺកាមរោគ (hygiene or STDs)
- បុរសដែលប្រតិកម្មជាមួយជាតិកៅស៊ូ (latex allergy) អាចធ្វើឱ្យលឹង្គទាំងមូលឡើងក្រហម និងបែកស្រកា (Erythema and scale)
- ការព្យាបាលគឺលាប steroids កំរិតមធ្យម ហើយត្រូវធ្វើការប្តូរស្រោមអនាម័យដែលមិនមែនជាតិកៅស៊ូ



## Fixed drug eruption

- អាចកើតឡើងបន្ទាប់ពី ប្រើថ្នាំ ផ្សេះ ដូចជា:Tetracycline ឬថ្នាំបញ្ចុះលាមក ដែលមានជាតិ phenolpthalein
- eruption មានលក្ខណ:ស្រួចស្រាវ ដែលមានស្នាមបន្ទះ (plaque) មួយឬច្រើនកន្លែងនៅផ្នែកខាងចុងនៃតួលឹង្គ
- eruption នេះអាចមានជាលក្ខណ:ពងទឹក (bullous) ដែលផ្ទៃរបស់វាអាច ឡើងខ្មៅរលួយ (necrotic) ដូចជា ដែកដុតក្តៅ (hot iron)



## Lichen Planus

- ជំងឺនេះជាវិបត្តិនៃការរលាកដែលលេចចេញជាស្នាមកន្ទួល violaceous flat-topped អាចកើតនៅគ្រប់ ទីកន្លែងនៃដងខ្លួន (part of the body).
- ជាទូទៅក្បាលលឹង្គមានស្នាម flat-topped តូចៗ ជាច្រើន ដែលមានទំហំពី ២-៥មល្លីម៉ែត្រ ។
- ហើយមិនឃើញមានពងទឹក, erosion ឬក្រម៉ (crust)ទេ ។




# Lichen nitidus

- មានលក្ខណៈប្រហាក់ប្រហែលទៅវិបត្តិនៃការរលាក (similar inflammatory disorder)
- មិនដឹងមូលហេតុច្បាស់លាស់
- ស្នាមកន្ទួលតែមួយបែប (monomorphic) ដែលទំហំ ១-២មីលីម៉ែត្រ នៅតាមបណ្តោយតួលឹង្គ (shaft of penis)







# Lichen sclerosis

- ស្បែកមានសភាពឡើងក្រិនបន្តិចម្តងៗ (progressive sclerosing) ដោយមិនដឹងពីមូលហេតុ ។
- ស្នាមបន្ទះ ក្រិន ពណស ជាច្រើន (white atrophic plaques) ដែលកើតនៅលើផ្នត់ស្បែក (prepuce) និង ក្បាលលឹង្គ ។
- ការរលាក (eruption) អាចវិវត្តទៅរកការប្រេះ (fissure) និងជាប់ស្អិត (adhesion)
- ចំពោះស្ត្រី ស្នាមបន្ទះ ក្រិន ពណស (white atrophic plaques ) អាចគ្រប់ដណ្តប់ទៅលើយោនី (vulvar) និងតំបន់ជុំវិញរន្ធគូទ (perianal)
- ការធ្វើ biopsy លើស្បែកវាជាការសំខាន់សំរាប់ធ្វើរោគវិនិច្ឆ័យ ។







# Vitiligo

- ជំងឺនេះអាចលេចចេញដូច lichen sclerosis បង្ហាញឡើងដោយ hypopigment និង depigment នៅតំបន់ប្រដាប់បន្តពូជ ។
- ជាទូទៅចំពោះបុរស មានការ ប៉ះពាល់ក្បាលលឹង្គ និងតួលឹង្គ ហើយគ្មានរោគសញ្ញា ។
- ការធ្វើរោគវិនិច្ឆ័យអាចជួយបានដោយសារមានវត្តមាន depigment នៅកន្លែងដ៏ទៃទៀតនៃដងខ្លួន ជាពិសេសនៅមុខ និងខ្នងដៃ ។
- ការព្យាបាលប្រើ steroid ដែលមានកំរិតទាបអាចមានប្រយោជន៏ក្នុងករណីខ្លះ ។





# Zoo’n balanitis

- ជាការរលាករ៉ាំរ៉ៃនៅលើចុងលឹង្គដែលមិនពន្លាត់ (uncircumcised) ។
- ស្នាម របួស មានផ្ទៃសើម ដែលអាចបង្ហាញអោយឃើញច្បាស់ ។




# Purple straie

- បណ្តាលមកពីការប្រើ steroid កំរិតខ្ពស់ (high potency) ដែលមានរយៈពេល០១ខែ ហើយជា ញឹកញាប់កើតឡើងនៅ តំបន់ក្រលៀន (inguinal) និងភ្លៅ (thighs) ។

## Sebaceous hyperplasia

- ជាទូទៅនៅលើប្រដាប់បន្តពូជបរុស និងស្ត្រី ពេលអ្នកជំងឺពិនិត្យ ដោយខ្លួនឯងអាចមានការភ័យខ្លាច ដោយសង្ស័យថាមានដុំពក នៅតាមបណ្តោយយោនី ឬ តាម បណ្តោយតួលឹង្គ ។
- មានទំហំ ពី ១ - ២ មីល្លីម៉ែត្រ ពិណលឿងស្រស់ ដែលមាន រូបរាងជាកន្ទួលតែមួយប្រភេទ ជួនកាលអាច មានរោម ។
- អ្នកផ្តល់សេវាត្រូវធ្វើការប្រាប់ដល់អ្នកជំងឺ ថាវាជារូបភាពធម្មតា ដើម្បីកុំអោយ អ្នកជំងឺ គិតថា វាជាជំងឺសិរមាន់លើប្រដាប់បន្តពូជ ។






## Vestibular papillae

- មានលក្ខណៈធម្មតាត្រូវបានគេឃើញនៅលើស្ត្រី ចំណាស់ ដែលបណ្តាលមកពីការជិតអស់រដូវ ។
- មានរូបរាងតែមួយប្រភេទជា filiform tubular តូចៗដែលលេចចេញនៅ vestibule និង អាចធ្វើអោយច្រឡំជាមួយ ជំងឺសិរមាន់ នៅលើប្រដាប់បន្តពូជ ។
- អ្នកផ្តល់សេវា ត្រូវមានការធានា (reassureance) ចំពោះអ្នកជំងឺ ជាការចាំបាច់ ។





## Pearly penile papule (PPP)

- មាននៅតំបន់ corona sulcus នៃក្បាលលឹង្គ មានរូបរាង ជាកន្ទួលតែមួយប្រភេទ ទំហំ ១-២ មីល្លីម៉ែត្រ មានលក្ខណៈរលោង (flesh colored smooth)
- អាចឃើញមាន នៅពេលយុវវ័យ និង ធ្វើអោយច្រឡំជាមួយសិរមាន់ លើប្រដាប់បន្តពូជ ។
- ស្នាមកន្ទួលនេះមិនមានរោគសញ្ញាអ្វីឡើយ ។
- អ្នកផ្តល់សេវាត្រូវមានការធានា (Reassurance) ចំពោះអ្នកជំងឺជាការចាំបាច់ ។





## Scrotal cysts

- ជាទូទៅវាមានលក្ខណៈដូចដុំថ្មកំបោរ ដែលបង្កើតបានជាដុំរឹងក្រិន (rock hard deposits) ។
- មាន lesion calcinosis ជាច្រើន នៅលើស្រោមពងស្វាស (scrotal) ។
- មិនមានការព្យាបាលទេ ប៉ុន្តែ lesion អាចកាត់ចេញបាន ។
- ដុំពកកើតនៅថ្នេរកណ្តាលខាងមុខនៃលឹង្គ (ventral midlin … រ បញ្ចូលគ្នា ។



# Angiokeratomas

- ជាទូទៅគ្មានរោគសញ្ញា ហើយសរសៃឈាមនៃ lesion លេចចេញនៅលើស្រោមពងស្វាស ។
- lesion ទាំងអស់នេះ ត្រូវបានរកឃើញដោយចៃដន្យ ។
- វាជា nodules មានពិណក្រហម ឬខ្មៅដែលមានទំហំ ១-៤សង្ទីរម៉ែត្រ ហើយជំងឺនេះអាចមានការហូរឈាមបន្ទាប់ពីមានការប៉ះទង្គិច ។





# *MALIGNANT LESION OF THE GENITALS*

***1-Squamous cell carcinoma (SCC)***

- ជាមហារីកស្បែក នៅលើប្រដាប់បន្តពូជ ចំពោះមនុស្សប្រុស អាចកើតមាននៅអាយុពី ៥០ឆ្នាំ-៦០ឆ្នាំ
- កំណត់ឡើងដោយការប្រែប្រួលពិណទៅជាក្រហម ដែលកើតមាននៅតាម coronal sulcus ។
- មានប្រវត្តិចាប់ផ្តើមលេចចេញ ប្រហែល ១ - ២ឆ្នាំ ហើយជាទូទៅបង្ហាញឡើងដោយ

អ្នកជំងឺខ្លះ ព្យាយាម ប្រើ topical creams ក្នុងការព្យាបាល ។



2-Erythoplasia of Queyrat

- ជាទូទៅត្រូវព្យាបាល ដោយការកាត់យកចេញដោយមានការឈឺចាប់តិចតួច ។ គេឃើញមានការរាតត្បាត នៅលើបុរសដែលស្បែក លឹង្គមិនពន្លាត់ ។ ចំពោះស្ត្រីឃើញ នៅលើ យោនីឡើងក្រហម

និងមានបែកស្រកាបន្តិចបន្តួច (erythemtous somewhat scaly plaque)

ការរាតត្បាតនេះ (invasive) ឃើញមាន នៅលើប្រដាប់បន្តពូជបុរសនិងស្ត្រី

ហើយឈានទៅបំផ្លាញ កន្លែងដទៃទៀត និងមាន metastases ។





# *INFECTION (ការបង្ករោគ)*

## 1-Tinea cruis

- បុរសតែងតួញត្អែរមានស្នាមកន្ទួល (rash) បន្តិចបន្តួច ដែលមានរយៈពេលច្រើនសប្តាហ៍ ឬច្រើន ខែ នៅលើក្រលៀន ។ ដូច្នេះការសាកសួរប្រវត្តិ ជាការសំខាន់ណាស់ ។
- កត្តាដែលជំរុញអោយកើត ជំងឺ រួមមាន ធាត់ពេក (obese) ក្តៅហប់ (heat) និងសើម ខ្លាំង ជាទូទៅជំងឺនេះកើតលើបុរសច្រើនជាងស្ត្រី ។
- ស្បែករបស់អ្នកជំងឺ ឡើងក្រហម (erythema) បែកស្រកា (scaling)

និងរាលដាលពាសពេញ សងខាង បណ្តោយ ផ្នត់ក្រលៀន ។





# *INFECTION (ការបង្ករោគ)*

## 2-candidiasis

- ជំងឺនេះមានកើតនៅ លើគន្លាក់ក្រលៀន (inguinal folds) ដែលលេចចេញជាពិណក្រហម (erythemtous) និង បែកស្រកា (scale) និងជាទូទៅគ្មានតែមទេ ។
- ចំពោះការហូរនោមដោយ មិនដឹងខ្លួន (incontinence) និងហប់ (heat) ជាកត្តាជំរុញអោយកើតជំងឺនេះ ។
- ការព្យាបាល tinea cruis និង candidiasis ទាំងពីរនេះមាន ការឆ្លើយតបយ៉ាងរហ័ស ជាមួយនឹងឱសថ topical antifungal ដូចជា: econazole, ketonazole, cicloprox

## 2-candidiasis

- ការបំបាត់កត្តាជំរុញផ្សេងៗដូចជា: ក្តៅហប់ (heat) បែកញើស (sweat) និងធាត់ពេក (obese) ជាការសំខាន់ដើម្បី ការពារកុំអោយមានជំងឺនេះ ។










## 3-Tinea versicolor

- បណ្តាលមកពី pityrosporum អាចមានជាស្នាមបន្ទះ ពិណត្នោត (tan patches) នៅតាមបណ្តោយតំបន់ pubis តែឯង ឬមានស្នាម (lesion) ដូចគ្នា នៅលើដើមទ្រូង និង ខ្នង។ ជាទូទៅ Eruption គ្មានស្តែងចេញរោគសញ្ញា ទេ ហើយការធ្វើរោគវិនិច្ឆ័យពឹងផ្អែកទៅលើការពិនិត្យសភាពស្រស់ ដោយប្រើប៉ូតាស្យូមអ៊ីដ្រុកស៊ីត (KOH prep) ។
- Eruption ឆ្លើយតបជាមួយ នឹង selenium sulfade lotion ឬ axole creams ផ្សេងទៀត ។
- ការផឹក azole អាចប្រើបានបើ eruption មាន លក្ខណៈរាលដាលធំ ។





## 4-Erythrasma

- មូលហេតុបណ្តាលមកពីពពួកបាក់តេរីមិនធម្មតាដូចជា corynebacterium minisutum ។
- លេចជាស្នាមបន្ទះក្រហម ស្តើង ពាសពេញ (diffuse thin red patchess)តាមផ្នត់ក្រលៀន ។







## 5-Folliculitis

- ជាទូទៅបណ្តាលមកពីពពួក staphylococcus aureus ស្តែងចេញជា follicle ច្រើនកើតនៅលើតំបន់ក្រលៀន ។
- លេចចេញជា pustules ទំហំ ១-២មីល្លីម៉ែត្រ ជាច្រើនគ្រាប់ ដែលនៅជុំវិញចំណុចកណ្តាលនិមួយៗ និងមាន hair follicle ។
- Folliculitis អាចកើតនៅគ្រប់ទីកន្លែងនៃប្រដាប់បន្តពូជ និង មិនសូវកើតនៅលើចុងលឹង្គទេ ពីព្រោះ វាគ្មាន follicles ។
- ការហប់ក្តៅ និងការចេញញើសច្រើនជាកត្តាធ្វើអោយធ្ងន់ធ្ងរ ។



# ម៉ូឌុលទី ៤

# ការអប់រំ និង ការផ្តល់ប្រឹក្សាដល់អ្នកជំងឺ



## ការអប់រំ និង ការផ្តល់ប្រឹក្សាដល់អ្នកជំងឺ

**គោលបំណង**

នៅចុងបញ្ចប់នៃការសិក្សាផ្នែកនេះ សិក្ខាកាមនឹងអាចៈ

១- ពន្យល់ពីភាពខុសគ្នារវាងការអប់រំ និងការផ្តល់ប្រឹក្សា

២- ពន្យល់ពីមូលហេតុដែលការអប់រំ និងការផ្តល់ប្រឹក្សាមានសារៈសំខាន់ក្នុងការគ្រប់គ្រងករណីជំងឺកាមរោគ និងជំងឺឆ្លងតាមប្រដាប់បន្តពូជ

៣- នឹកឃើញពីជំនាញទំនាក់ទំនងពិភាក្សាពីការអនុវត្តសកម្មភាពផ្លូវភេទ និងឥរិយាបថនៃការប្រព្រឹត្ត សកម្មភាពផ្លូវភេទសំរាប់ការអប់រំ និងការផ្តល់ប្រឹក្សា

៤- អប់រំ និងផ្តល់ប្រឹក្សាដល់អ្នករកស៊ីផ្លូវភេទ និងបុរសដែលរួមភេទជាមួយបុរសដូចគ្នា (MSM)

៥- កំណត់ប្រធានបទសំខាន់ៗនៃការអប់រំដល់អ្នកជំងឺកាមរោគ និងជំងឺឆ្លងតាមប្រដាប់បន្តពូជ

៦-រៀបរាប់ផលប្រយោជន៏នៃការប្រើប្រាស់ស្រោមអនាម័យ និងនឹកឃើញពីជំហានមូលដ្ឋាននៃការពាក់ស្រោមអនាម័យ និងបង្ហាត់បង្ហាញវាដល់អ្នកជំងឺ



## ១_ ការអប់រំសុខភាព និង ការផ្តល់ប្រឹក្សា

**ការអប់រំសុខភាព**

គឺជាការផ្តល់ព័តិមានដ៏ត្រឹមត្រូវ និងពោរពេញដោយការពិត ដើម្បីឱ្យបុគ្គលម្នាក់អាចទទួលបាននូវចំណេះដឹងអំពីប្រធានបទ និងជ្រើសរើសនូវជំរើសមួយដែលបានដឹងបាន។

**ការផ្តល់ប្រឹក្សា**

គឺជាអន្តរកម្មទៅវិញទៅមកមួយរវាងអ្នកជំងឺ និងអ្នកផ្តល់សេវាសុខភាព។ វាគឺជាទំរង់ការទំនាក់ទំនងដ៏ស្វាហាប់ និងអន្តរបុគ្គលមួយដែលពាក់ពន្ធ័ទៅនឹងប្រភេទមួយនៃកិច្ចព្រមព្រៀងសន្យារវាងអ្នកជំងឺ និងអ្នកផ្តល់ប្រឹក្សាដែលត្រូវបាន បង្វឹកក្នុងមាត្រដ្ឋានដែលគេអាចទទួលយកបានមួយ ហើយជាអ្នកដែលមានការផ្សារភ្ជាប់ទៅនឹងក្រមសីលធមិ និងការអនុវត្ត។



## ១_ ការអប់រំសុខភាព និង ការផ្តល់ប្រឹក្សា (ត)

**ហេតុអ្វីក៏ការអប់រំ និងការផ្តល់ប្រឹក្សាមានសារៈសំខាន់យ៉ាងខ្លាំង?**

- អ្នកជំងឺច្រើនតែចង់ប្រតិបត្តិតាមការព្យាបាល ប្រសិនបើពួកគេយល់ពីមូលហេតុសំខាន់របស់វា
- មនុស្សម្នាក់ដែលមានផ្ទុកជំងឺកាមរោគ មានអត្រាងាយលាប់ជំងឺខ្ពស់
- ការបង្ការការលាប់ជំងឺ ទាមទារឱ្យមានការផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្តឱ្យបានជារៀងរហូត។ អ្នកជំងឺច្រើនតែត្រូវការការអប់រំ និងការផ្តល់ប្រឹក្សា ដើម្បីជំរុញឱ្យពួកគេអាចផ្លាស់ប្តូរការប្រព្រឹត្ត និងទទួលយកការអនុវត្តការរួមភេទដោយសុវត្ថិភាព។

# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី?

១- ការពន្យល់ពីជំងឺកាមរោគ និងការព្យាបាល

២- ការអប់រំពីការបង្ការការឆ្លងរោគទៅថ្ងៃមុខ:

- ការផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្តសកម្មភាពផ្លូវភេទ
- ស្រោមអនាម័យ
- ការអនុវត្តលើការរួមភេទ
- វិធីសាស្ត្រទប់ស្កាត់ដទៃទៀត
- ការអនុវត្តអនាម័យផ្ទាល់ខ្លួន និងការអនុវត្តក្នុងសង្គម

៣- តំរូវការការព្យាបាលចំពោះដៃគូស្នេហា

៤- ការផ្តល់ប្រឹក្សាដើម្បីនាំទៅរកការធ្វើតេស្តឈាមរកមេរោគអេដស៍



# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

## ២-១- ការពន្យល់ពីជំងឺកាមរោគ និងការព្យាបាល

- វាសំខាន់ណាស់ដែលអ្នកជំងឺម្នាក់អាចយល់ច្បាស់ថាជំងឺនេះគឺឆ្លងច្រើនបំផុតតាមការរួមភេទជាមួយអ្នកដែលមានផ្ទុកជំងឺនេះ ។
- ពន្យល់ពីជំងឺកាមរោគណាដែលអ្នកជំងឺមាន និងការព្យាបាលណាដែលសំខាន់ ដូចជា ឈ្មោះថ្នាំ និងរបបនៃការប្រើប្រាស់ តើត្រូវប្រើវាញឹកញាប់ប៉ុណ្ណា និងរយៈពេលប៉ុណ្ណា ។
    - ស្វែងយល់ថា អ្នកជំងឺយល់បានអ្វីខ្លះអំពីជំងឺកាមរោគ និងការព្យាបាលវា ហើយគាត់នៅមានសំនួរ ឬកង្វល់អ្វីផ្សេងទៀតដែរឬទេ?
    - ឱ្យដំបូន្មានអ្នកជំងឺពីប្រតិកម្មរបស់ការព្យាបាលដែលតែងតែកើតមានជាធម្មតា
    - លើកទឹកចិត្តអ្នកជំងឺឱ្យប្រតិបត្តិតាមការព្យាបាល



# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

## ២-២- ការអប់រំអំពីការបង្ការការឆ្លងជំងឺទៅថ្ងៃមុខ

អ្នកជំងឺត្រូវតែព្រមទទួលស្គាល់ការប្រឈមនឹងការលាប់ជំងឺនោះឡើងវិញ

**ការផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្តសកម្មភាពផ្លូវភេទ**

- ការប្រព្រឹត្តដែលមានការប្រឈមនឹងការឆ្លងខ្ពស់ គឺជាការប្រព្រឹត្តដែលអ្នកជំងឺត្រូវប្រឈមនឹងឈាម និងវត្ថុរាវពេលរួមភេទ ។ ដូច្នេះការផ្លាស់ប្តូរឥរិយាបថការប្រព្រឹត្តពីការប្រឈមខ្ពស់មកទាបវិញ គឺជាវិធីមួយដើម្បីបង្ការការឆ្លងដែលអាចកើតមាននៅពេលអនាគតបាន ។
- កាត់បន្ថយចំនួនដៃគូរួមភេទ ឬអត្រាការផ្លាស់ប្តូរដៃគូរួមភេទមានសារៈសំខាន់ណាស់ ។
- ការតមមិនរួមភេទអាចធានាប្រឆាំងនឹងការប៉ះពាល់ ឬការចំលងជំងឺកាមរោគបាន ។ នេះរឹតតែមានសារៈសំខាន់ទៅទៀតនៅក្នុងកំឡុងពេលព្យាបាលជំងឺកាមរោគ ។



# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

**ស្រោមអនាម័យ**

- ការអនុវត្តមួយបែបទៀតដើម្បីបង្ការការឆ្លងរាលដាលនៃជំងឺកាមរោគ គឺការប្រើប្រាស់ស្រោមអនាម័យ ។
- ស្រោមអនាម័យកៅស៊ូរបស់បុរស អាចកាត់បន្ថយការប្រឈមនឹងការប៉ះពាល់ ឬចំលងជំងឺកាមរោគបាន ប្រសិនបើវាត្រូវបានគេប្រើយ៉ាងត្រឹមត្រូវ និងជាប់លាប់ ។
- បុគ្គលិកសុខាភិបាលត្រូវតែបង្ហាញការប្រើប្រាស់ស្រោមអនាម័យឱ្យបានត្រឹមត្រូវ ដោយប្រើលិង្គគំរូ នៅកន្លែងណាដែលអាចរកបាន ។
- អនុញ្ញាតឱ្យអតិថិជនអនុវត្តលើលិង្គគំរូនោះ ដើម្បីឱ្យពួកគេបានយល់ពីរបៀបពាក់ស្រោមអនាម័យ ឱ្យពួកគេអាចបង្ហាញពីជំនាញនេះបាន និងឱ្យពួកគេមានទំនុកចិត្តលើការប្រើប្រាស់ស្រោមអនាម័យ ។

# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

**ការអនុវត្តលើការរួមភេទ**

- វាសំខាន់ណាស់ក្នុងការប្រាប់ដល់អតិថិជនថា ការអនុវត្តលើការរួមភេទមានការប្រឈមនឹងជំងឺខ្ពស់ណាស់ ។ ឧទាហរណ៍ ការរួមភេទតាមទ្វារលាមក មិនថាចំពោះ បុរសនិងស្ត្រី ឬបុរសនិងបុរស សុទ្ធតែនាំទៅរកការប្រឈមនឹងជំងឺជាងការរួមភេទតាម លិង្គនិងយោនី ។

**វិធីសាស្ត្រទប់ស្កាត់ដទៃទៀត**

- ប្រាប់អតិថិជនរបស់អ្នកពីវិធីបង្ការទប់ស្កាត់ដទៃទៀតដែលមាន ដូចជាការប្រើប្រាស់ថ្នាំរំងាប់ទឹកកាមដែលអាចជាថ្នាំរំងាប់បាក់តេរី ថ្នាំរំងាប់អតិសុខុមប្រាណ ឬវ៉ាក់សាំងការពារ (ឧ. ចំពោះរោគរលាកថ្លើមប្រភេទB) ។



# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

**ការអនុវត្តអនាម័យផ្ទាល់ខ្លួន និងការអនុវត្តក្នុងសង្គម**

- ឧទាហរណ៍ ការបាញ់លាងទ្វារមាស អាចកំចាត់ចោលបាក់តេរីដែលការពារនៅក្នុងទ្វារមាស ហើយបែរជាបង្កើនការប្រឈមនឹងការឆ្លងជំងឺកាមរោគមួយចំនួនបាន ដូចជាវីរុសអេដស៍ជាដើម ។ ការលាងសំអាតជាមួយសាប៊ូ និងទឹក អាចជួយបង្ការការឈ្លានពានរបស់ប៉ារាសិត ដូចជា ចៃលើរោមប្រដាប់ភេទ ឬកមរមាស់ជាដើម ។



# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

**២-៣- តំរូវការការព្យាបាលចំពោះដៃគូស្នេហា**

- ជានិច្ចកាលប្រាប់អ្នកជំងឺថា វាមានសារៈសំខាន់ប៉ុណ្ណា ចំពោះការឱ្យដៃគូរួមភេទដែលពួកគេស្គាល់ទាំងអស់បានទទួលការព្យាបាល ។
- បញ្ជាក់ដល់អ្នកជំងឺឱ្យកាន់តែច្បាស់ថា អ្នកនឹងរក្សាការសំងាត់នេះឱ្យបាន ហើយត្រូវពិភាក្សាគ្នាថា ពួកអ្នកអាចធ្វើបែបណាដើម្បីអាចបញ្ចុះបញ្ចូលដៃគូអ្នកជំងឺឱ្យមកទទួលការព្យាបាលបាន ។ សូមសង្កត់ធ្ងន់ថា ការព្យាបាលនេះនឹងផ្តល់ប្រយោជន៍ដល់ដៃគូទាំងសងខាង ពីព្រោះថាវានឹងគ្មានការប្រឈមនឹងការលាប់ជំងឺឡើងវិញ ហើយអ្នកជាដៃគូដែលប្រហែលជាមិនបានដឹងពីជំងឺនេះ នឹងអាចទទួលការព្យាបាលជំងឺកាមរោគបាន ហើយថែមទាំងអាចជៀសផុតពីបញ្ហាធ្ងន់ធ្ងរទាំងឡាយបានទៅថ្ងៃមុខ ។



# ២. ការអប់រំសុខភាព. តើអប់រំលើអ្វី? (ត)

**២-៤- ការផ្តល់ប្រឹក្សាដើម្បីនាំទៅរកការធ្វើតេស្តឈាមរកមេរោគអេដស៍**

- ផ្នែកនេះនឹងអាចឱ្យអ្នកពន្យល់បានពីសារៈសំខាន់ និងទំនាក់ទំនងរបស់ការពិនិត្យឈាមរកមេរោគអេដស៍ ។ យើងអាចផ្តល់ប្រឹក្សាដល់អ្នកជំងឺ ឬអតិថិជនឱ្យគេអាចធ្វើការសំរេចចិត្តពីការត្រូវបញ្ជូនទៅពិនិត្យឈាមរកមេរោគអេដស៍ ។
- សារៈសំខាន់នៃការធ្វើតេស្តឈាមរកមេរោគអេដស៍ គឺដើម្បីបានដឹងពីស្ថានភាពមេរោគអេដស៍របស់ពួកគេ ។ បន្ទាប់មកអតិថិជននឹងមានភាពងាយស្រួលក្នុងការបង្ការសុខភាពរបស់ពួកគេ ទោះបីជាពួកគេទទួលលទ្ធផលអវិជ្ជមាន ឬវិជ្ជមានក៏ដោយ ។

# ៣. ការផ្តល់ប្រឹក្សាសំរាប់ជំងឺកាមរោគ ជំងឺឆ្លងតាមប្រដាប់បន្តពូជ និងជំងឺអេដស៍

១- ការប៉ាន់ស្មានកំរិតប្រឈមនឹងការឆ្លងរោគរបស់អ្នកជំងឺ

- កត្តានានាសំរាប់ប៉ាន់ស្មានកំរិតប្រឈមនៃការឆ្លងរោគជំងឺកាមរោគរបស់អ្នកជំងឺ
- ការជួយអ្នកជំងឺឱ្យស្គាល់ពីកត្តាគ្រោះថ្នាក់របស់ពួកគេ

២- តំរូវការឱ្យអ្នកជំងឺផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្តការរួមភេទ

៣- ឧបសគ្គនានាក្នុងការផ្លាស់ប្តូរឥរិយាបថនៃការប្រព្រឹត្ត

- ឧបសគ្គផ្នែកភេទ
- ការអនុវត្តខាងផ្នែកវប្បធម៌
- សាសនា
- ភាពក្រីក្រ អស្ថេរភាពសង្គម និងកោលាហលក្នុងចំណោមប្រជាពលរដ្ឋ

៤- ការផ្លាស់ប្តូរទាំងឡាយដែលអ្នកជំងឺនឹងប្រព្រឹត្តនៅក្នុងការរួមភេទ



# ៤. អប់រំ និងផ្តល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា?

- ជំនាញទំនាក់ទំនងមានសារៈសំខាន់ណាស់ (ណែនាំក្នុងម៉ូឌុលទី៣)
  - ប្រើការនិយាយស្តី និងកាយវិកា
  - ប្រើសំនួរបើក
  - ការសំរបសំរួល
  - ការសង្ខេប និងការត្រួតពិនិត្យ
  - ការធានា ការដឹកនាំ ការចេះយល់ចិត្ត និង
  - ការបង្ហាញភាពជាដៃគូ
- ការជួយអ្នកជំងឺ និងអតិថិជនឱ្យសំរេចបាននូវចំណង់ក្នុងការផ្លាស់ប្តូររបស់គេ
  - ការពន្យល់ និងណែនាំ
  - ការលើកជាឧទាហរណ៍
  - ការជំរុញកំលាំងចិត្តដែលអ្នកឃើញនៅក្នុងខ្លួនអ្នកជំងឺ
  - ការជួយអ្នកជំងឺឱ្យបានដឹងពីជំរើសផ្សេងៗ
  - ការហាត់សមនូវអ្វីដែលអ្នកជំងឺនឹងធ្វើ ឬនិយាយ
  - ការធានាបញ្ជាក់នូវការសំរេចចិត្តរបស់អតិថិជន



# ៤. អប់រំ និងផ្តល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា? (ត)

## ៤-១- ការពន្យល់ និងការណែនាំ

នេះគឺជាជំនាញនានាដែលបុគ្គលិកសុខាភិបាលជាច្រើនបានប្រើស្ទើរតែរាល់ពេល

**ការណែនាំ** ការប្រាប់អ្នកជំងឺពីអ្វីដែលត្រូវធ្វើ និងរបៀបធ្វើអ្វីមួយ ដូចជាការប្រើប្រាស់ស្រោមអនាម័យ ឬការប្រើប្រាស់ឱសថ ដូចជា៖

"សូមចាំថា ត្រូវលេបថ្នាំឱ្យបានគ្រប់គ្រាន់រហូតដល់គ្រាប់ចុងក្រោយ ...។"

**ការពន្យល់** ការប្រាប់ដល់អ្នកជំងឺពីរបៀប ឬមូលហេតុដែលត្រូវធ្វើអ្វីមួយ ដូចជា៖

"អ្នកឈឺផ្នែកខាងក្រោមក្បាលពោះ ព្រោះតែអ្នកឆ្លងជំងឺនៅពេលដែលអ្នករួមភេទ ...។"



# ៤. អប់រំ និងផ្តល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា? (ត)

## ៤-២- ការលើកជាឧទាហរណ៍

- ជំនាញនេះនឹងអាចឱ្យអ្នកបង្ហាញពីឧទាហរណ៍នៃ របៀបដែលឥរិយាបថនៃការប្រព្រឹត្ត ឬការព្យាបាលដែលត្រូវបានណែនាំបានទទួលជោគជ័យនៅក្នុងករណីដទៃទៀត។
- និយាយឱ្យស្រួលស្តាប់ គឺអ្នកនឹងផ្តល់ជាឧទាហរណ៍ក្នុងផ្លូវវិជ្ជមានសំរាប់ការផ្លាស់ប្តូរ។
- វាមានសារៈសំខាន់ណាស់ ការឱ្យឧទាហរណ៍អាក្រក់ៗដូចជា "ប្រសិនបើអ្នកមិនផ្លាស់ប្តូរការប្រព្រឹត្តរបស់អ្នកចេញទេ អ្នកនឹងកើតអេដស៍ ហើយស្លាប់!" អាចនឹងមានការពិតខ្លះមែន ក៏ប៉ុន្តែវាកំរនឹងបញ្ចុះបញ្ចូលឱ្យយើងផ្លាស់ប្តូរបានណាស់។

## ៤. អប់រំ និងផ្ដល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា? (ត)

### ៤-៣- ការជំរុញកំលាំងចិត្ត

- នេះចង់សំដៅដល់ការទាញចេញនូវកំលាំងមួយ ឬចរិតលក្ខណៈវិជ្ជមានមួយដែលអ្នកឃើញនៅក្នុងខ្លួនអ្នកជំងឺ គឺអ្វីដែលនឹងជួយពួកគេឱ្យបានជាពីជំងឺកាមរោគ ឬឱ្យចេះការពារខ្លួនពីការលាប់ឡើងវិញនូវជំងឺកាមរោគ ។
- ការជំរុញកំលាំងចិត្តក៏អាចមានប្រយោជន៍ក្នុងការជួយពួកគេដើម្បីគ្រប់គ្រងអារម្មណ៍ ដើម្បីឱ្យបុគ្គលិកសុខាភិបាលអាចដឹកនាំនាងឱ្យមករកការព្យាបាលវិញ ។



## ៤. អប់រំ និងផ្ដល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា? (ត)

### ៤-៤- ការស្វែងយល់ពីជំរើសផ្សេងៗ

- ផ្នែកនេះនិយាយអំពីការរំលឹកឡើងវិញដល់ជំរើស ឬជំហានផ្សេងៗរបស់អ្នកជំងឺ ដើម្បីព្យាបាលជំងឺកាមរោគដែលកំពុងតែកើតលើខ្លួន ឬដើម្បីការពារជំងឺកាមរោគផ្សេងទៀត ។ អ្នកជំងឺអាចសំរេចចិត្តនៅពេលបន្ទាប់មកទៀតថា ជំរើសមួយណាដែលល្អបំផុតសំរាប់ខ្លួន ហើយអាចធ្វើទៅបាន ។
- ការផ្ដល់ជាជំរើសមួយក៏ធ្វើឱ្យអ្នកជំងឺកាន់តែមានថាមពលដែរ ដែលអ្នកទាំងនោះនឹងមានអារម្មណ៍ថាកាន់តែទុកចិត្តជាងមុនក្នុងការសំរេចចិត្ត ដែលពួកគេនឹងធ្វើនោះ ។ អ្នកជំងឺនឹងមានអារម្មណ៍ “ម្ចាស់ការ” លើការសំរេចចិត្តរបស់ខ្លួន ។



## ៤. អប់រំ និងផ្ដល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា? (ត)

### ៤-៥- ការហាត់សមលើការសំរេចចិត្ត

នៅពេលដែលអ្នកបានច្បាស់ក្នុងចិត្តហើយថា អ្នកជំងឺបានធ្វើការសំរេចចិត្តរួចរាល់ហើយចំពោះការប្រព្រឹត្តដែលប្រកបដោយសុវត្ថិភាព វាមានសារៈសំខាន់ណាស់ក្នុងការស្នើឱ្យគាត់ពិចារណាលើជំហានទាំងឡាយឱ្យបានល្អិតល្អន់ ដើម្បីដាក់ការសំរេចចិត្តនេះឱ្យចេញជាការអនុវត្តផ្ទាល់ ។



## ៤. អប់រំ និងផ្ដល់ប្រឹក្សា៖ តើធ្វើឡើងដោយរបៀបណា? (ត)

### ៤-៦- ការធានាបញ្ជាក់លើការសំរេចចិត្ត

- នេះគឺជាវិធីដ៏មានសារៈប្រយោជន៍មួយក្នុងការសន្និដ្ឋានបញ្ចប់ការសម្ភាស ។ អ្នកបានជួយអ្នកជំងឺឱ្យរៀបចំខ្លួនសំរាប់អ្វីដែលពួកគេនឹងធ្វើបន្ទាប់ពីចាកចេញពីគ្លីនិកទៅ ។
- ការស្នើឱ្យអ្នកជំងឺធានាបញ្ជាក់ពីការសំរេចចិត្តមួយ អាចជួយឱ្យពួកគេមានអារម្មណ៍ថា កំពុងតែត្រូវបានជំរុញឱ្យចាកចេញពីគ្លីនិក ។ ដោយមានការពង្រឹងការសំរេចចិត្តពីអ្នក ពួកគេទំនងជាចង់អនុវត្តការរួមភេទដោយសុវត្ថិភាពជាងពេលមុន ។

# ៥. ការប្រើប្រាស់ស្រោមអនាម័យដើម្បីឱ្យបានជាសះស្បើយ

- រាយឈ្មោះសារៈប្រយោជន៍នៃការប្រើប្រាស់ស្រោមអនាម័យ
- បង្ហាញពីរបៀបប្រើប្រាស់ស្រោមអនាម័យ
- ពន្យល់ពីរបៀបថែរក្សា និងទុកដាក់ស្រោមអនាម័យ



# ៥. ការប្រើប្រាស់ស្រោមអនាម័យដើម្បីឱ្យបានជាសះស្បើយ (ត)

**ការបង្ហាញពីការប្រើប្រាស់ស្រោមអនាម័យ**

- បង្ហាញពី ថ្ងៃ ខែ ផលិត និងផុតកំណត់ប្រើប្រាស់ ហើយពន្យល់ថា ស្រោមអនាម័យមិនត្រូវផុតកំណត់ប្រើប្រាស់ ផុំក្លិន ស្អិត ឬមានសភាពរឹងនៅពេលពន្លានោះទេ ។
- ពន្យល់ពីរបៀបបើកកញ្ចប់យ៉ាងប្រុងប្រយត្ន័ ដោយមើលទៅលើកន្លែងសំរាប់ហែក ។
- បង្ហាញពីផ្នែកត្រូវរបស់ស្រោមអនាម័យដើម្បីពាក់លើលិង្គ ដោយពន្យល់ថា វានឹងមិនរលាចុះក្រោមទេ បើដាក់វាម្ខាងទៀត ។
- បង្ហាញពីរបៀបកាន់ចុងស្រោមអនាម័យ ដើម្បីសង្កត់ខ្យល់ចេញឱ្យអស់មុននឹងពន្លាវាចុះក្រោមលិង្គដែលកំពុងរឹង ។



# ៥. ការប្រើប្រាស់ស្រោមអនាម័យដើម្បីឱ្យបានជាសះស្បើយ (ត)

**ការបង្ហាញពីការប្រើប្រាស់ស្រោមអនាម័យ**

- បញ្ជាក់ឱ្យច្បាស់ថា ស្រោមអនាម័យត្រូវតែពន្លារហូតដល់គល់របស់វា
- ពន្យល់ថា ស្រោមអនាម័យគួរតែបានដកចេញភ្លាម១ ក្រោយពីលិង្គបាត់បង់ភាពរឹងរបស់វា ហើយថា អ្នកជំងឺគួរតែកាន់វាយ៉ាងប្រុងប្រយត្ន័ពីគល់ស្រោម ហើយទាញវាចេញយឺត១ ។
- ពន្យល់ថា អ្នកជំងឺគួរតែចងផ្នែកខាងលើនៃស្រោមអនាម័យ រួចហើយយកវាទៅបោះចោលដោយសុវត្ថិភាព ។



# ការប្រើប្រាស់ស្រោមអនាម័យបង្ការការឆ្លងជម្ងឺកាមរោគ



STI/RTI Unit/NCHADS

# ការប្រើប្រាស់ស្រោមអនាម័យបង្ការការឆ្លងជម្ងឺកាមរោគ



# ម៉ូឌុលទី ៥

# ការគ្រប់គ្រងថែទាំនិងព្យាបាលដៃគូរួមភេទរបស់អ្នកជម្ងឺ



# វត្ថុបំណងនៃការសិក្សា

- **នៅចុងបញ្ចប់នៃការសិក្សានេះ សិក្ខាកាមនឹងអាច :**
  - ✓ ពន្យល់ឱ្យបានច្បាស់លាស់ថាហេតុអ្វីបានជាការអញ្ជើញដៃគូរួមភេទឱ្យមកទទួលការព្យាបាលមានសារៈសំខាន់?
  - ✓ ពិភាក្សាថា តើដៃគូរួមភេទណាមួយដែលត្រូវបានអញ្ជើញឱ្យមកទទួលការព្យាបាល?
  - ✓ អធិប្បាយអំពីវិធីសាស្រ្តនានាដែលអាចអនុវត្តបាន ដើម្បីកំណត់រកដៃគូរួមភេទរបស់ជម្ងឺ
  - ✓ ពិនិត្យមើលឡើងវិញអំពីប័ណ្ណអញ្ជើញដៃគូរួមភេទឱ្យមកទទួលការព្យាបាល
  - ✓ ការព្យាបាលដៃគូរួមភេទ



# គោលការណ៍សំខាន់ៗនៃការអញ្ជើញដៃគូរួមភេទឱ្យមកទទួលការថែទាំព្យាបាល

- **ភាគច្រើននៃការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ ពុំមានលេចចេញជារោគសញ្ញាទេ**
- **ដៃគូរបស់អ្នកជម្ងឺកាមរោគអាចនឹងមិនមានរោគសញ្ញាកាមរោគ ។ ដូច្នេះបើទោះបីជាមានការព្យាបាលអ្នកជម្ងឺកាមរោគក៏ដោយ ក៏អ្នកជម្ងឺអាចនឹងឆ្លងមេរោគកាមរោគសារជាថ្មីទៀតពីដៃគូរបស់គាត់ ប្រសិនបើដៃគូនោះមិនបានទទួល ការព្យាបាល ។**
- **ការកំណត់អំពីដៃគូរួមភេទមិនមែនសំដៅតែទៅលើដៃគូក្នុងពេលបច្ចុប្បន្នទេ តែក៏ត្រូវស្រាវជ្រាវរកដៃគូដែលមានទំនាក់ទំនងផ្លូវភេទតាំងពី ៣ ខែកន្លងទៅដែរ (ដំបៅលើប្រដាប់បន្តពូជ, រលាកប៉ៃលីស, ការបង្ករោគនានានៅលើមាត់ស្បូន) ។**

*<u>កំណត់ចំណាំ :</u> ប្រសិនបើអ្នកជម្ងឺត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជម្ងឺស្វាយ ត្រូវកំណត់រកដៃគូរួមភេទក្នុងកំលុងពេលមួយឆ្នាំកន្លងទៅ ។*



# តើអ្នកណាជាដៃគូរួមភេទដែលត្រូវអញ្ជើញឱ្យមកទទួលការថែទាំព្យាបាលជម្ងឺកាមរោគ

**ការបង្ករោគនៅប្រដាប់បន្តពូជមិនមែនសុទ្ធតែឆ្លងតាមការរួមភេទទាំងអស់នោះទេ ។ ដូច្នេះគ្រូពេទ្យព្យាបាលត្រូវតែធ្វើរោគវិនិច្ឆ័យឱ្យបានត្រឹមត្រូវសិនថាអ្នកជម្ងឺមានការបង្ករោគឆ្លងតាមការរួមភេទ ទើបចាប់ផ្តើមអញ្ជើញដៃគូឱ្យមកទទួលការថែទាំព្យាបាល :**

- **គ្រប់អ្នកជម្ងឺដែលមានដំបៅនៅប្រដាប់បន្តពូជ**
- **គ្រប់អ្នកជម្ងឺដែលមានការបង្ករោគផ្សិតប៉ុន្តែមិនបានជាសះស្បើយឡើយ បើទោះបីជាបានទទួលការថែទាំព្យាបាលយ៉ាងត្រឹមត្រូវក៏ដោយ ឬដៃគូនោះកំពុងមានរោគសញ្ញាដូចគ្នានឹងអ្នកជម្ងឺដែរ ។**
- **អ្នកជម្ងឺបុរសដែលមានការហូរខ្ទុះតាមបង្ហូរនោម**
- **អ្នកជម្ងឺស្ត្រីដែលមានចង្កោមរោគសញ្ញាឈឺចុកចាប់នៅផ្នែកខាងក្រោមនៃពោះ**
- **អ្នកជម្ងឺស្ត្រីដែលមានការបង្ករោគនៅមាត់ស្បូន ។**

# តើត្រូវធ្វើដូចម្តេចដើម្បីអញ្ជើញដៃគូរួមភេទរបស់អ្នកជម្ងឺឱ្យមកទទួលការថែទាំព្យាបាល?

- បណ្តុះបណ្តាលមន្ត្រីសុខាភិបាលនិងអ្នកស្ម័គ្រចិត្តសហគមន៍ អំពីការស្វែងរកដៃគូរួមភេទរបស់អ្នកជម្ងឺ
- វាយតំលៃទៅលើលទ្ធភាពនៃការនាំយកដៃគូរួមភេទរបស់អ្នកជម្ងឺឱ្យមកពិនិត្យនៅគ្លីនិក
- ជំហ៊ាន បី សំខាន់ៗជាយុទ្ធសាស្ត្រ :
  - ប្រសិនបើអ្នកជម្ងឺមិនអាចនាំដៃគូរួមភេទរបស់គាត់ឱ្យមកទទួលការព្យាបាលនៅគ្លីនិកទេ ចូរផ្តល់ឱសថព្យាបាលសំរាប់អ្នកទាំងពីរ ដោយធ្វើការពន្យល់ណែនាំឱ្យបានច្បាស់លាស់អំពីរបៀបធ្វើឱ្យដៃគូរបស់គាត់ជឿទុកចិត្តនិងយល់ព្រមទទួលការព្យាបាល
  - ប្រសិនបើអ្នកជម្ងឺអាចនាំដៃគូរួមភេទរបស់គាត់ឱ្យមកទទួលការព្យាបាលនៅគ្លីនិកបាន ចូរផ្តល់ប័ណ្ណអញ្ជើញដៃគូទៅអ្នកជម្ងឺនោះ ។ រង់ចាំមើលដៃគូរបស់អ្នកជម្ងឺមកគ្លីនិកក្នុងកំលុងពេល២សប្តាហ៍
  - ប្រសិនបើដៃគូអ្នកជម្ងឺមិនមកគ្លីនិកទេ សូមឱ្យអ្នកស្ម័គ្រចិត្តសហគមន៍ជួយអញ្ជើញគាត់ឱ្យមកទទួលការព្យាបាល ។

5

# តើត្រូវធ្វើដូចម្តេចដើម្បីឱ្យដៃគូរួមភេទរបស់អ្នកជម្ងឺងាយស្រួលមកទទួលការថែទាំព្យាបាល?

- បណ្តុះបណ្តាលមន្ត្រីសុខាភិបាលភេទប្រុស ដើម្បីផ្តល់ការថែទាំព្យាបាលដល់អ្នកជម្ងឺបុរស
- ជៀសវាងកុំឱ្យអ្នកជម្ងឺនិងដៃគូរួមភេទរបស់គាត់រង់ចាំយូរ
- ប្រសិនបើត្រូវបង់ថ្លៃពិនិត្យព្យាបាលនៅគ្លីនិក ត្រូវឱ្យគាត់បង់តាមតំលៃធម្មតា បើដៃគូនោះគ្មានរោគសញ្ញាទេ
- ធានានូវការរក្សាការសំងាត់
- វាយតំលៃលើកត្តាប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់
- ធ្វើការពិនិត្យបែបគ្លីនិក និងមន្ទីរពិសោធន៍ បើទោះបីជាដៃគូនោះគ្មានរោគសញ្ញាកាមរោគក៏ដោយ
- ផ្តល់ការថែទាំព្យាបាលដល់ដៃគូរួមភេទដូចគ្នានឹងការបង្ករោគរបស់អ្នកជម្ងឺដែរ បើទោះបីជាដៃគូនោះមានឬគ្មានរោគសញ្ញាកាមរោគក៏ដោយ
- កំណត់កាលបរិច្ឆេទណាត់ជួបលើកក្រោយទៀត ប្រសិនបើជាការចាំបាច់ ។

6

# តើត្រូវធ្វើដូចម្តេចដើម្បីពិនិត្យតាមដានការព្យាបាល?

- ផ្តល់ដំបូន្មានដល់អ្នកជម្ងឺឱ្យត្រឡប់មកវិញ បើគ្មានការធូរស្បើយទេ ក្នុងកំឡុងពេលក្រោយពីទទួលការព្យាបាលបានរយៈពេល :
  - ៣ ថ្ងៃ សំរាប់ជម្ងឺរលាកប៉ៃលវីស
  - ៧ ថ្ងៃ សំរាប់ជម្ងឺដំបៅនៅប្រដាប់បន្តពូជ
- វាយតំលៃអំពីភាពបរាជ័យនៃការព្យាបាល / ការឆ្លងរោគសារជាថ្មី :
  - តើអ្នកជម្ងឺបានបញ្ចប់ការព្យាបាលចប់សព្វគ្រប់ទេ?
  - តើដៃគូរបស់គាត់បានទទួលការព្យាបាលហើយឬនៅ?
  - តើអ្នកជម្ងឺបានប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវ ឬតមមិនរួមភេទនៅពេលចាប់ផ្តើមការព្យាបាលឬទេ?
- ផ្តល់ការព្យាបាលសារជាថ្មីឡើងវិញ ឬបន្ថែមរយៈពេលនៃការព្យាបាល ប្រសិនបើមានការសង្ស័យថា បរាជ័យក្នុងការព្យាបាល ឬមានការឆ្លងរោគសារជាថ្មី ។

7

# ប័ណ្ណអញ្ជើញដៃគូរួមភេទឱ្យមកទទួលការព្យាបាល

| | |
|---|---|
| លេខប័ណ្ណ ___________ | លេខប័ណ្ណ ________ ថ្ងៃខែចេញប័ណ្ណ ___________ |
| ថ្ងៃខែចេញប័ណ្ណ _______ | គ្លីនិកចេញប័ណ្ណ : គ្លីនិកសុខភាពគ្រួសារ.......................... |
| លេខកូដរោគវិនិច្ឆ័យ_______ | ឈ្មោះ ______________________________ |
| ឈ្មោះរបស់ដៃគូ | **សូមមកកាន់គ្លីនិកសុខភាពគ្រួសារ........................** |
| និងព័ត៌មានលំអិតៈ | **ដោយនាំយកប័ណ្ណនេះ មកជាមួយផង** |
| ______________________ | លេខកូដរោគវិនិច្ឆ័យ __________ |
| គ្លីនិកសុខភាពគ្រួសារ | |
| ........................................... | |

8

# ការគ្រប់គ្រងព្យាបាលដៃគូរួមភេទរបស់អ្នកជម្ងឺ

| ចង្កោមរោគសញ្ញារបស់អ្នកជម្ងឺ | ការព្យាបាលដៃគូរួមភេទ |
|---|---|
| ការហូរខ្ទុះតាមបង្ហួរនោម | ព្យាបាលការបង្ករោគដោយមេរោគប្រមេះទឹកបាយ (Gonorrhoea) និងក្លាមីឌីយ៉ា (Chlamydia) |
| ដំបៅលើប្រដាប់បន្តពូជ | ព្យាបាលការបង្ករោគដោយមេរោគស្វាយ (Syphilis) និងឈៃងក្រយ (Chancroid) |
| ការហូរខ្ទុះតាមទ្វារមាស : | |
| • រលាកមាត់ស្បូន/រលាកមាត់ស្បូននិងទ្វារមាស | ព្យាបាលការបង្ករោគដោយមេរោគប្រមេះទឹកបាយ (Gonorrhoea) និងក្លាមីឌីយ៉ា (Chlamydia) |
| • រលាកទ្វារមាស | ព្យាបាលដៃគូរួមភេទ លុះត្រាតែការធ្លាក់ស នោះកើតមានសារចុះឡើងមិនបាត់ ។ |



# ការគ្រប់គ្រងព្យាបាលដៃគូរួមភេទរបស់អ្នកជម្ងឺ

| ចង្កោមរោគសញ្ញារបស់អ្នកជម្ងឺ | ការព្យាបាលដៃគូរួមភេទ |
|---|---|
| ជម្ងឺរលាកប៉ែលវីស (PID) | ព្យាបាលការបង្ករោគដោយមេរោគប្រមេះទឹកបាយ (Gonorrhoea) និងក្លាមីឌីយ៉ា (Chlamydia) |
| ហើមពងស្វាស | ព្យាបាលការបង្ករោគដោយមេរោគប្រមេះទឹកបាយ (Gonorrhoea) និងក្លាមីឌីយ៉ា (Chlamydia) |
| ហើមក្រលៀន | ព្យាបាលការបង្ករោគដោយ Lymphogranuloma Venereum |
| រលាកភ្នែកលើទារកដែលទើបនឹងកើត | ព្យាបាលការបង្ករោគដោយមេរោគប្រមេះទឹកបាយ (Gonorrhoea) និងក្លាមីឌីយ៉ា (Chlamydia) ដល់ឪពុកម្តាយទារកនោះ ។ |

# ម៉ូឌុលទី ៦.១

# ការគ្រប់គ្រងថែទាំការបង្ករោគ តាមការរួមភេទ និងប្រដាប់បន្តពូជ សំរាប់ស្ត្រីមានផ្ទៃពោះ និងទារកទើបនឹងកើត



# វត្ថុបំណងនៃការសិក្សា

នៅចុងបញ្ចប់នៃការសិក្សាម៉ូឌុលនេះ សិក្ខាកាមនឹងអាចៈ

១- ពិពិណនាពីការវាយតំលៃអំពីការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជក្នុងកំឡុងពេលមានផ្ទៃពោះ, ពេលសំរាល និងរយៈពេលក្រោយពីសំរាលកូន

២- រៀបរាប់ពីការវាយតំលៃអំពីការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជនៅពេលពិគ្រោះជំងឺមុនសំរាលកូន លើកដំបូង

៣- រៀបរាប់ពីការវាយតំលៃអំពីការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជនៅពេលពិគ្រោះជំងឺតាមដានមុនពេលសំរាល

៤- ពិពិណនាពីការវាយតំលៃអំពីការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជនៅពេលឈឺពោះសំរាល និងពេលសំរាល

៥- ធ្វើការបង្ការ និងគ្រប់គ្រងថែទាំការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ

៦- រៀបរាប់ពីការវាយតំលៃអំពីការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ ចំពោះទារកទើបនឹងកើតក្នុងរយៈពេលក្រោយពីសំរាល



## ការវាយតំលៃជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជ ក្នុងកំឡុងពេល មានផ្ទៃពោះ, សំរាល និងរយៈពេលក្រោយពីសំរាល

- ការបង្ការនិងការគ្រប់គ្រងថែទាំការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ក្នុងពេលមានផ្ទៃពោះ សំខាន់ដូចជានៅពេល ផ្សេងៗទៀតដែរ ។
- សកម្មភាពផ្លូវភេទរបស់ស្ត្រីម្នាក់អាចកើនឡើងឬថយចុះ ហើយការប្រឈមមុខទៅនឹងការឆ្លងរោគ អាចមានការផ្លាស់ប្តូរ ។
- ជំងឺកាមរោគមួយចំនួន-រួមមានជំងឺស្វាយ, ប្រមេះទឹកបាយ, ប្រមេះទឹកថ្លា, ទ្រីកូម៉ូណាស, ដំបៅលើប្រដាប់បន្តពូជ និងមេរោគអេដស៍- អាចបង្កអោយមានផលវិបាកក្នុងពេលមានផ្ទៃពោះ និងអោយមាន លទ្ធផលនៃការមានផ្ទៃពោះមិនល្អ (poor pregnancy outcome) ។
- ក្នុងចំណោមការឆ្លងរោគដែលគ្មានមូលហេតុច្បាស់លាស់, មេរោគបាក់តេរីនៅនឹងទ្វារមាស គឺត្រូវបានចូលរួមជាមួយ ការឈឺពោះឆ្លងទន្លេមិនគ្រប់ខែ ។



## ការវាយតំលៃជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជ ក្នុងកំឡុងពេល មានផ្ទៃពោះ, សំរាល និងរយៈពេលក្រោយពីសំរាល

- ការបង្ករោគនៅផ្លូវបន្តពូជផ្នែកខាងលើអាចជាផលវិបាកបង្កមកពីការរលូតកូនដោយឯកឯង ឬការពន្លូតកូន, ឬការធ្លាយស្រោមទឹកភ្លោះមុនសំរាល ។
- ក្នុងចំណោមការឆ្លងរោគដែលគ្មានមូលហេតុច្បាស់លាស់, ការបង្ករោគបាក់តេរីនៅនឹងទ្វារមាស ត្រូវបានសង្កេតឃើញថាមានទំនាក់ទំនងជាមួយនឹងការឈឺពោះសំរាលកូនមិនគ្រប់ខែ ។
- ស្ត្រីក្នុងវ័យបន្តពូជ គួរតែត្រូវបានអប់រំអំពីសារៈសំខាន់នៃការថែទាំសុខភាពមុនពេលសំរាលឱ្យបាន ឆាប់រហ័ស និងការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ។

## ការវាយតំលៃជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជ ក្នុងកំឡុងពេល មានផ្ទៃពោះ, សំរាល និងរយៈពេលក្រោយពីសំរាល

- ស្ត្រីគួរតែត្រូវបានលើកទឹកចិត្តអោយទៅពិគ្រោះជំងឺនៅគ្លីនិកថែទាំសុខភាពមុនពេលសំរាលឱ្យបានឆាប់រហ័សក្នុងពេលមានផ្ទៃពោះ ដើម្បីអាចធ្វើការស្រាវជ្រាវរកបញ្ហាមួយចំនួនទាន់ពេលវេលា រួមទាំងការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ។
- ស្ត្រីគួរតែត្រូវបានធ្វើតេស្តរកជំងឺស្វាយនៅពេលមកពិគ្រោះជលើកដំបូង ក្នុងពេលមានផ្ទៃពោះ ។ ការធ្វើតេស្តរកជំងឺស្វាយគួរតែត្រូវបានធ្វើនៅនឹងកន្លែងផ្តល់សេវាផ្ទាល់ ហើយលទ្ធផលនិងការព្យាបាលគួរតែផ្តល់ឱ្យស្ត្រី មុនពេលគាត់ចាកចេញពីគ្លីនិកនោះ ។



## ការវាយតំលៃជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជ ក្នុងកំឡុងពេល មានផ្ទៃពោះ, សំរាល និងរយៈពេលក្រោយពីសំរាល

- ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជផ្សេងៗទៀត, រួមទាំង ការបង្ករោគនៅនឹងមាត់ស្បូន, បាក់តេរីនៅនឹងទ្វារមាស, គួរតែត្រូវបានផ្តល់ឱ្យ បើសិនអាចធ្វើបាន ។
- ស្ត្រីគួរតែត្រូវបានសាកសួរអំពីរោគសញ្ញានៃជំងឺកាមរោគចំពោះខ្លួនពួកគេ និងដៃគូរបស់ពួកគេនៅពេលមកពិគ្រោះក្នុងពេលមានផ្ទៃពោះម្តងៗ ។ ការធ្វើតេស្តរកមេរោគ និង/ឬការព្យាបាលដៃគូរួមភេទគួរតែត្រូវបានផ្តល់អោយ   យ៉ាងហោចណាស់ក៏ជំងឺកាមរោគដែលមានរោគសញ្ញា, ជំងឺស្វាយជាដើម ។



## ការវាយតំលៃជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជ ក្នុងកំឡុងពេល មានផ្ទៃពោះ, សំរាល និងរយៈពេលក្រោយពីសំរាល

- ការបង្ការការបង្ករោគតាមការរួមភេទ និងប្រដាប់ពូជ គួរតែត្រូវបានលើកកំពស់ ក្នុងពេលមានផ្ទៃពោះដោយសារវាជាមធ្យោបាយមួយ ក្នុងការការពារទាំងម្តាយ និងកូន និងរក្សានូវសមត្ថភាពបន្តពូជក្នុងពេលអនាគត ។
- ការផ្តល់ប្រឹក្សា និងការធ្វើតេស្តរកមេរោគអេដស៍, អន្តរាគមន៍ដើម្បីបង្ការការឆ្លងរោគពីម្តាយទៅកូន, និងការថែទាំម្តាយ គួរតែអាចរកបាននៅនឹងកន្លែងផ្តល់សេវា ឬក៏តាមរយៈការបញ្ជូន ។
- ការបង្ការជំងឺរលាកភ្នែកលើទារកទើបនឹងកើត គួរតែត្រូវបានផ្តល់ឱ្យជាប្រចាំដល់ទារកដែលទើបនឹងកើតទាំងអស់ ។



## ការវាយតំលៃអំពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នៅពេលមកពិគ្រោះជាលើកដំបូង មុនពេលសំរាល

- សួរស្ត្រីអំពីរោគសញ្ញានៃការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ថាតើដៃគូរួមភេទរបស់គាត់មានការហូរខ្ទុះតាមបង្ហូរនោម ឬរោគសញ្ញាផ្សេងៗទៀតឬទេ ។ បើសិនជាស្ត្រីឬដៃគូរួមភេទរបស់គាត់មានរោគសញ្ញា, ពួកគេគួរតែត្រូវបានធ្វើការថែទាំព្យាបាលភ្លាមៗ ។
- ការធ្វើតេស្តរកមេរោគស្វាយចំពោះស្ត្រីមានផ្ទៃពោះ គួរតែត្រូវបានអនុវត្តឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។
- ការធ្វើតេស្តរកមេរោគស្វាយនេះ គួរតែត្រូវបានធ្វើនៅនឹងកន្លែង ចំពោះកន្លែងណា ដែលអាចធ្វើបាន, និងស្ត្រីគួរតែទទួលលទ្ធផលរបស់គាត់និងការព្យាបាលមុនពេលចាកចេញពីគ្លីនិក ។

## ការវាយតំលៃអំពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នៅពេលមកពិគ្រោះជាលើកដំបូង មុនពេលសំរាល

- ស្រ្តីមានផ្ទៃពោះដែលមានប្រវត្តិរលូតកូនដោយឯកឯង ឬការសំរាលកូនមិនគ្រប់ខែ គួរតែត្រូវបានធ្វើតេស្តរកមេរោគបាក់តេរីនៅនឹងទ្វារមាស និងទ្រីកូម៉ូណាស់ ។
- ការបង្ការជំងឺកាមរោគ ( បញ្ចូលទាំងមេរោគអេដស៏ ) គួរតែត្រូវបានពិភាក្សាជាមួយស្រ្តី និងដៃគូរួមភេទរបស់គាត់អំពីពិតមានដែលទាក់ទងទៅនឹងការធានាការមានផ្ទៃពោះដែលមានសុខភាពល្អ និងរក្សាបាននូវភាពអាចមានកូន នៅពេលអនាគត ។



## ការវាយតំលៃអំពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នៅពេលមកពិគ្រោះជាលើកដំបូង មុនពេលសំរាល

- ការធ្វើតេស្តរកជំងឺស្វាយគួរតែត្រូវធ្វើឡើងវិញនៅពេលជិតបញ្ចប់នៃការមានផ្ទៃពោះ ប្រសិនបើមិនទាន់បានធ្វើនៅពេលចាប់ផ្តើមមានផ្ទៃពោះ ។
- ស្រ្តីទាំងអស់គួរតែត្រូវបានធ្វើតេស្ត យ៉ាងហោចណាស់ម្តង ក្នុងពេលមានផ្ទៃពោះម្តងៗ, និងស្រ្តីទាំងអស់ដែលមានលទ្ធផលតេស្តវិជ្ជមាន ត្រូវតែទទួលបាននូវការព្យាបាល ។
- ការគ្រប់គ្រងថែទាំនៅក្នុងកំឡុងពេលមានផ្ទៃពោះ ហើយមានផ្ទុកមេរោគអេដស៏ ត្រូវផ្អែកទៅលើគោលការណ៏ណែនាំជាតិស្តីពី ការបង្ការការចំលងមេរោគអេដស៏ពីម្តាយទៅកូន ដែលត្រូវអនុវត្តតាម ។ អ្នកផ្តល់សេវាថែទាំសុខភាពគួរតែពិនិត្យឡើងវិញពី ផែនការកំនើត និងពិភាក្សាពីជំរើសសំរាប់ការចិញ្ចឹមទារក និងការបង្ការការមានផ្ទៃពោះ ក្រោយពីសំរាលកូនរួច ។



## ការវាយតំលៃអំពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នៅពេលឈឺពោះសំរាល និងពេលសំរាល

- ត្រូវរករោគសញ្ញានៃការបង្ករោគ ។ ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ភាគច្រើនមិនមែនជា ការបន្ទាន់ទេ ហើយការព្យាបាលអាចត្រូវបានពន្យាររហូតដល់ក្រោយពេលសំរាលកូនរួច ។
- ពងទឹកឬដំបៅត្រូវនឹកឃើញដល់ការមានជំងឺពងបែកនៅលើប្រដាប់បន្តពូជ ( ការឆ្លងរោគ virus HSV 2 ) ។ ការបញ្ជូនទៅមន្ទីរពេទ្យបង្អែកគួរតែត្រូវបានពិចារណា បើសិនការសំរាលកូនមិនទាន់មកដល់ ។
- ចំពោះជំងឺសិរមាន់លើប្រដាប់បន្តពូជ, បើទោះជាធំក៏ដោយ គេមិនត្រូវធ្វើការបង្កើតកូនដោយវះកាត់ទេ ។



## ការវាយតំលៃអំពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នៅពេលឈឺពោះសំរាល និងពេលសំរាល

- ការធ្លាយស្រោមទឹកភ្លោះមុនពេលសំរាល, និងការធ្លាយស្រោមទឹកភ្លោះមុនការចាប់ផ្តើមឈឺពោះសំរាល ទាមទារនូវការថែទាំព្យាបាលយ៉ាងយកចិត្តទុកដាក់យ៉ាងហ្មត់ចត់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់នៃការឆ្លងរោគ ។
- ការគ្រប់គ្រងថែទាំស្រ្តីដែលមានផ្ទុកមេរោគអេដស៏( រួមបញ្ចូលទាំងការគ្រប់គ្រងការព្យាបាលដោយប្រើឱសថពន្យាការវិវត្តនៃមេរោគអេដស៏ ) ត្រូវពឹងផ្អែកទៅលើគោលការណ៏ណែនាំជាតិ ។
- ការបង្ការជំងឺរលាកភ្នែកលើទារកទើបនឹងកើត ត្រូវតែផ្តល់អោយជាប្រចាំដល់ទារកដែលទើបនឹងកើតទាំងអស់ ។

# ការបង្ការ និងគ្រប់គ្រងថែទាំជំងឺឆ្លងតាមការរួមភេទ និងប្រដាប់បន្តពូជ ចំពោះទារកដែលទើបនឹងកើត





# ការបង្ការ និងគ្រប់គ្រងថែទាំជំងឺឆ្លងតាមការរួមភេទ និងប្រដាប់បន្តពូជ ចំពោះទារកដែលទើបនឹងកើត

**ការបង្ការជំងឺភ្នែកក្រហមលើទារកទើបនឹងកើត**

ដាក់ថ្នាំដែលរៀបរាប់ខាងក្រោមមួយដំណក់ក្នុងភ្នែកនីមួយៗនៅក្នុងរយៈពេលមួយម៉ោងនៃការកើត:

ប៉ូមាតសំរាប់ដាក់ភ្នែក **Tetracycline** (1 %) លាបតែមួយដងគត់

**ឬ**

ផ្តល់ថ្នាំដំណក់ **Iodine 2,5 %** ដាក់តែម្តងគត់

**ឬ**

សូលុយស្យុង **Silver nitrate (1 %)** ដែលផ្សំថ្មីៗ ដាក់តែម្តងគត់



# ការវាយតំលៃអំពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ក្នុងរយៈពេលក្រោយពីសំរាល

- វាយតំលៃរោគសញ្ញានៃការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ :
  ធ្វើយ៉ាងណាកុំអោយមាន ការឆ្លងរោគក្នុងរយៈពេលក្រោយពីសំរាលកូន ។
- ពិភាក្សាពីការបង្ការការឆ្លងរោគពីម្តាយទៅកូន បើសិនស្ត្រីមានផ្ទុកមេរោគអេដស៍, ពិចារណាពីគំរោងការចិញ្ចឹមជំនួស ។
- ពិភាក្សាពីការបង្ការជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជ និងការបង្ការការមានផ្ទៃពោះ ។

# ម៉ូឌុលទី ៦.២

# ការគ្រប់គ្រងថែទាំជំងឺកាមរោគ/ការឆ្លងរោគ តាមផ្លូវបន្តពូជដែលគ្មានរោគសញ្ញា



## វត្ថុបំណងនៃការសិក្សា

នៅចុងបញ្ចប់នៃការសិក្សាម៉ូឌុលនេះ សិក្ខាកាមនឹងអាចៈ

១-ពិពិណនាពីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជដែលគ្មានរោគសញ្ញា

២-កំណត់ពីរបៀបធ្វើតេស្តរកមេរោគជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជសំរាប់ស្ត្រី

៣-កំណត់ពីរបៀបធ្វើតេស្តរកមេរោគជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជសំរាប់បុរស

៤-កំណត់ពីរបៀបធ្វើតេស្តរកមេរោគជំងឺកាមរោគ/ការឆ្លងរោគតាមផ្លូវបន្តពូជសំរាប់បុរសរួមភេទជាមួយបុរស



## ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ដែលគ្មានរោគសញ្ញាចំពោះស្ត្រី និងបុរស

- ស្ត្រី និងបុរសជាច្រើនដែលមានការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ គ្មានលេចចេញជារោគសញ្ញាទេ, ឬមានរោគសញ្ញាតិចតួច ឬក៏មិនដឹងខ្លួនថាមានអ្វីប្លែកពីធម្មតានោះតែម្តង។
- ចំពោះស្ត្រី, ការឆ្លងរោគដែលគ្មានរោគសញ្ញា អាចធ្ងន់ធ្ងរជាងការឆ្លងរោគដែលមានរោគសញ្ញា។
- បុរសអាចមិនដឹងពីរោគសញ្ញា  ប្រសិនបើរោគសញ្ញាទាំងនោះមិនធ្ងន់ធ្ងរទេ។
- ត្រូវធ្វើតេស្តមន្ទីរពិសោធន៏រកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជជាប្រចាំចំពោះអ្នកជំងឺទាំងអស់ដែលប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ។



## ជម្ងឺកាមរោគគឺជាសត្រូវបង្កប់ខ្លួន

STIs are the silent enemy



# អ្នកជម្ងឺដែលអាចប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់នៃការបង្ករោគតាមការរួមភេទ (STIs)




# ការធ្វើតេស្តរកជំងឺបង្កតាមការរួមភេទ និងប្រដាប់បន្តពូជ សំរាប់ស្ត្រី

- ស្ត្រីដែលមានរោគសញ្ញាជំងឺកាមរោគដែលមិនមែនជាដំបៅលើប្រដាប់បន្តពូជ ត្រូវបានធ្វើតេស្តរកការឆ្លងជំងឺស្វាយ ។ ការធ្វើតេស្តរកជំងឺស្វាយ មិនជាការចាំបាច់ទេ ប្រសិនបើអ្នកជំងឺនោះមានដំបៅលើប្រដាប់បន្តពូជ ។ គេគួរតែផ្តល់ការព្យាបាលដល់អ្នកជំងឺតាមចង្កោមរោគសញ្ញា ទាំងជំងឺស្វាយ និងជំងឺ chancroid ដោយមិនចាំបាច់ធ្វើតេស្ត ។
- ស្ត្រីរកស៊ីផ្លូវភេទ ត្រូវបានធ្វើតេស្តរកមេរោគស្វាយនៅពេលពិនិត្យលើកដំបូង និងបន្ទាប់មករៀងរាល់៣ខែម្តង ប្រសិនបើលទ្ធផលតេស្តលើកមុន “អវិជ្ជមាន” ដើម្បីស្រាវជ្រាវរកការចំលងមេរោគស្វាយក្នុងចន្លោះពេលនេះ ។



# ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជសំរាប់ស្ត្រី

## ១-ការធ្វើតេស្តរកមេរោគស្វាយ

- ត្រូវធ្វើតេស្តស្វាយ ចំពោះស្ត្រីមានផ្ទៃពោះ នៅពេលស្ត្រីនោះមកពិគ្រោះជាលើកដំបូង ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ វាអាចត្រូវបានធ្វើឡើងវិញនៅក្នុងត្រីមាសទី ៣ នៃការមានផ្ទៃពោះ ។
- ស្ត្រីដែលមិនបានទៅគ្លីនិកថែទាំសុខភាពពេលមានផ្ទៃពោះ ត្រូវបានធ្វើតេស្តនេះនៅពេលសំរាលកូន ។
- ស្ត្រីដែលមានការរលូតកូនដោយឯកឯង ឬកើតកូនមកស្លាប់ ក៏ត្រូវធ្វើតេស្តស្រាវជ្រាវរកការឆ្លងមេរោគស្វាយដែរ ។



# ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជសំរាប់ស្ត្រី

**ការឆ្លងរោគនៅនឹងទ្វារមាស**

- ស្ត្រីមានផ្ទៃពោះដែលមានប្រវត្តិការរលូតកូនដោយឯកឯងឬការសំរាលកូនមិនគ្រប់ខែ ត្រូវធ្វើតេស្តរកមេរោគបាក់តេរីនៅនឹងទ្វារមាស និងទ្រីកូម៉ូណាស់ តាមរយៈការពិនិត្យ ស ក្នុងសភាពស្រស់/ការបំពាក់ពិណក្រាម (Gram stain) ចំពោះ ស ដែលស្រង់យកពីទ្វារមាស ។

**ការឆ្លងរោគនៅនឹងមាត់ស្បូន**

- ចំពោះស្ត្រីដែលគ្មានរោគសញ្ញា  គេអាចរកឃើញសញ្ញានៃការឆ្លងរោគនៅមាត់ស្បូន ដោយ :

## ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជសំរាប់ស្ត្រី

- ***ការពិនិត្យដោយប្រើស្ពេគុឡូម :***
  - ✓ ឃើញមានការធ្លាក់ ស ឬហូរខ្ទុះចេញពីមាត់ស្បូន,
  - ✓ ងាយចេញឈាម នៅពេលដែលមាត់ស្បូនត្រូវបានប៉ះជាមួយសំលីមានដង
  - ✓ ការធ្វើតេស្ត ដោយប្រើសំលីមានដង "វិជ្ជមាន" (ការប្តូរពិណជាពិណលឿងនៃសំលីមានដង ដែលស៊កទៅក្នុងរន្ធមាត់ស្បូនខាងក្នុង)។
- ***ការធ្វើតេស្តបំពាក់ពិណក្រាមនៃ ស ដែលស្រង់យកពីរន្ធមាត់ស្បូនខាងក្នុង (អាចធ្វើបាននៅក្នុងប្រទេសកម្ពុជាយើង)***



## ការពិនិត្យស្រាវជ្រាវជាប្រចាំ (Routine screening) លើជំងឺកាមរោគ ចំពោះស្ត្រីបំរើសេវាកំសាន្ត






## ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជសំរាប់ស្ត្រី

- ការបណ្តុះរកមេរោគប្រមេះទឹកបាយ (N. gonorrhoeae)
  - មាត់ស្បូន ខាងក្នុង/បង្ហូរនោម
  - ទ្វារលាមក (បើសិនជាមានរួមភេទតាមរន្ធគូថ)
  - បំពង់ក (បើសិនជាមានរួមភេទតាមមាត់)
- ការធ្វើតេស្តរកមេរោគប្រមេះទឹកថ្លា (C. trachomatis)
  - ការបណ្តុះសំលីមានដងដែលយកសពី មាត់ស្បូន ខាងក្នុង
  - NAAT សំលីមានដងដែលយក ស ពីមាត់ស្បូនខាងក្នុង ឬទឹកនោមដែលបត់ជើងតូចដំបូង (first void urine)



## ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជសំរាប់ស្ត្រី

**ការធ្វើតេស្តរកជំងឺមហារីកមាត់ស្បូន**

- ជំងឺមហារីកមាត់ស្បូនគឺជាផលវិបាកនៃជំងឺកាមរោគដែលស្គាល់មួយ, ដែលទាក់ទងទៅនឹងការឆ្លងរោគប្រភេទពិសេស មួយចំនួននៃវីរុសជំងឺសិរមាន់។ ការធ្វើតេស្តរកជំងឺ និងការព្យាបាលនៅដំណាក់ការដំបូង មានប្រសិទ្ធភាពក្នុងការបន្ថយ ការឈឺនិងការស្លាប់ ដោយសារជំងឺមហារីកមាត់ស្បូន។
- តេស្ត Pap smear (papanicolaousmear) ត្រូវបានផ្តល់យោបល់អោយធ្វើ ក្នុងពេលថ្មីៗនេះ, ស្ត្រីទាំងអស់ដែលមានអាយុលើសពី៣៥ឆ្នាំ គួរតែ ត្រូវបានធ្វើតេស្តរាល់ ៥ទៅ ១០ឆ្នាំ។

**ការធ្វើតេស្តរកមេរោគអេដស៍ (ការធ្វើតេស្តរកមេរោគអេដស៍ និងផ្តល់ប្រឹក្សា ដោយស្ម័គ្រចិត្ត)**

## ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជសំរាប់បុរស

**ត្រូវធ្វើតេស្តបំពាក់ពិណក្រោមនៃរំអិលឬខ្ទុះដែលស្រង់យកពីរន្ធបង្ហូរនោម ប្រសិនបើ :**

- អ្នកជំងឺមានរោគសញ្ញារលាកបង្ហូរនោម ឬ,
- អ្នកជំងឺមានហូរខ្ទុះតាមបង្ហូរនោមដែលអាចមើលឃើញដោយភ្នែកទទេ ឬ,
- អ្នកជំងឺបានរួមភេទជាមួយស្ត្រីដែលមានជំងឺរលាកមាត់ស្បូន, ជំងឺរលាកប៉ែលវីស ។

**ការធ្វើតេស្តរកជំងឺស្វាយ ចំពោះ :**

- បុរសដែលមានរោគសញ្ញាជំងឺកាមរោគណាមួយ
- បុរសដែលបានរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ ហើយមិនបានប្រើមធ្យោបាយបង្ការ ។

**ការបណ្តុះរកមេរោគប្រមេះទឹកបាយ ចំពោះខ្ទុះដែលយកពីរន្ធបង្ហូរនោមនិងបំពង់ក និងការបណ្តុះរកមេរោគប្រមេះទឹកថ្លាចំពោះខ្ទុះដែលយកពីរន្ធបង្ហូរនោមគឺអាស្រ័យទៅលើបែបផែននៃការរួមភេទរបស់អ្នកជំងឺនោះ ។**



## ការធ្វើតេស្តរកការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ សំរាប់បុរសរួមភេទជាមួយបុរស

**ការបំពាក់ពិណក្រោមនៃខ្ទុះដែលយកពីទ្វារលាមក (បើសិនជាមានប្រតិបត្តិទទួល ការរួមភេទ តាមរន្ធគូថ)**

-បើសិនជាការហូរខ្ទុះតាមរន្ធគូថត្រូវបានបង្ហាញ ឬ,

-បើសិនជាគ្មានរោគសញ្ញានៅនឹងទ្វារលាមក

**ការបណ្តុះរកមេរោគប្រមេះទឹកបាយ និងប្រមេះទឹកថ្លានូវខ្ទុះដែលយកពីទ្វារលាមក ( បើសិនជាបានប្រតិបត្តិទទួលការរួមភេទតាមរន្ធគូថកាលពីឆ្នាំកន្លងទៅ)**

**ការធ្វើតេស្តរកមេរោគអេដស៍( ការធ្វើតេស្តរកមេរោគអេដស៍និងផ្តល់ប្រឹក្សាដោយស្ម័គ្រចិត្ត) ។**

# ម៉ូឌុលទី ៦.៣

# ការបង្ករោគតាមការរួមភេទ និងការរំលោភផ្លូវភេទ



# វត្ថុបំណងនៃការសិក្សា

នៅចុងបញ្ចប់នៃការសិក្សាម៉ូឌុលនេះ សិក្ខាកាមនឹងអាច :

១-ពិពណ៌នាពីស្ថិតិនៃការរំលោភផ្លូវភេទនៅក្នុងពិភពលោក

២-រៀបរាប់ពីការថែទាំសុខភាព និងការថែទាំផ្សេងៗទៀតសំរាប់អ្នកដែលរងគ្រោះដោយការរំលោភផ្លូវភេទ។

៣-ពិពណ៌នាពីការគ្រប់គ្រងថែទាំសុខភាពបន្ទាន់ដើម្បីបង្ការការមានផ្ទៃពោះ

៤-ពិភាក្សាស្តីពីការបង្ការជំងឺកាមរោគក្រោយពីការរំលោភផ្លូវភេទ។



# ស្ថិតិមួយចំនួននៃការរំលោភផ្លូវភេទ

- ការសិក្សាពីផ្នែកផ្សេងៗនៃពិភពលោកបានរកឃើញថា ៧ ទៅ៣៦ភាគរយ នៃក្មេងស្រី និង ៣ ទៅ ២៩ភាគរយ នៃក្មេងប្រុស ត្រូវរងគ្រោះដោយការរំលោភផ្លូវភេទនៅក្នុងវ័យកុមារភាព។ ការសិក្សាភាគច្រើនរាយការណ៍ថា មានការរំលោភផ្លូវភេទលើក្មេងស្រី ១,៥ ទៅ ៣ដងច្រើនជាងការរំលោភផ្លូវភេទលើក្មេងប្រុស។
- មនុស្សវ័យជំទង់ដែលត្រូវបានបង្ខិតបង្ខំអោយរួមភេទអាចមានប្រហែលពី ៧ទៅ៤៦ ភាគរយចំពោះស្ត្រី និង៣ភាគរយទៅ២០ ភាគរយចំពោះបុរស ទៅតាមប្រទេសនិមួយៗ។



# ស្ថិតិមួយចំនួននៃការរំលោភផ្លូវភេទ

- ការសិក្សាដែលផ្អែកទៅលើប្រជាជន បានរាយការណ៍ថា រវាង៦ភាគរយ និង៤៦ភាគរយនៃស្ត្រីបានជួបនឹងការរួមភេទដែលត្រូវបានប៉ុនប៉ងបង្ខំ ឬបានបង្ខំទាំងស្រុងដោយដៃគូដែលស្និទ្ធស្នាល ឬអតីតដៃគូនៅក្នុងពេលខ្លះនៃជីវិតរបស់ពួកគេ។
- ការចាប់រំលោភនិងអំពើហឹង្សានៅក្នុងផ្ទះជាមូលហេតុដែលធ្វើអោយការបាត់បង់សុខភាពល្អ ពី៥-១៦ភាគរយ ចំពោះស្ត្រីស្ថិតក្នុងវ័យបន្តពូជ។
- ជំងឺកាមរោគត្រូវបានរកឃើញដល់ទៅ៤៣ភាគរយនៃមនុស្សដែលត្រូវបានគេចាប់រំលោភ,។ តាមរយៈការសិក្សាជាច្រើន បានបង្ហាញនូវអត្រាឆ្លងជំងឺនេះ ពី៥ ទៅ១៥ភាគរយ អាស្រ័យលើប្រភេទជំងឺកាមរោគ និងប្រភេទនៃតេស្ត ដែលយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវ។

# ការថែទាំសុខភាព និងការថែទាំផ្សេងៗទៀត សំរាប់ជនរងគ្រោះដោយការរំលោភផ្លូវភេទ

សេវាដូចខាងក្រោម នេះគួរតែអាចរកបាននៅនឹងកន្លែង ឬតាមរយៈការបញ្ជូន សំរាប់អ្នកជំងឺដែលបានរងគ្រោះដោយការរំលោភផ្លូវភេទ :

- ការថែទាំសុខភាពចាំបាច់សំរាប់ការមានរបួស និងបញ្ហាសុខភាព,
- ការប្រមូលភស្តុតាងសំរាប់ធ្វើតេស្តវិទ្យាសាស្ត្រ,
- ការវាយតំលៃអំពីការថែទាំព្យាបាលជំងឺកាមរោគ និងការបង្ការជំងឺនេះ,
- ការវាយតំលៃអំពីគ្រោះថ្នាក់នៃការមានផ្ទៃពោះ និងការបង្ការ ប្រសិនបើចាំបាច់,
- ការគាំទ្រនៃផ្លូវចិត្តនឹងសង្គម (ទាំងនៅពេលកំពុងមានវិបត្តិ និងរយៈពេលយូរក្រោយទៀត),
- សេវាសំរាប់ការពិនិត្យតាមដាននូវចំនុចទាំងអស់ខាងលើនេះ។



# ការបង្ការជាបន្ទាន់មិនអោយមានផ្ទៃពោះ

- ជំរើសទី ១ គឺ ការប្រើឱសថគ្រាប់ជាបន្ទាន់ បង្ការមិនអោយមានផ្ទៃពោះ (levonorgestrel) . គេអាចប្រើឱសថនេះរហូតដល់៥ថ្ងៃ ក្រោយពីការរំលោភរួមភេទដែលមិនបានប្រើមធ្យោបាយបង្ការមិនអោយមានផ្ទៃពោះ។
- ជំរើសទី ២ គឺការបញ្ចូលកងដាក់ក្នុងស្បូន ដែលមានជាតិទង់ដែង បន្ទាប់ពីការការចាប់រំលោភភ្លាម១ រយៈពេល៥ថ្ងៃ។ វិធីនេះនឹងបង្ការមិនអោយមានផ្ទៃពោះបានជាង៩៩ភាគរយ ។ កងដាក់ក្នុងស្បូន អាចដកចេញក្នុងពេលស្ត្រីមករដូវបន្ទាប់ពីនេះ ឬទុកសំរាប់បង្ការការមានផ្ទៃពោះក្រោយ១បន្តទៅទៀតបាន។ ប្រសិនបើ ជ្រើសរើស វិធីដាក់កងក្នុងស្បូន នេះ គេត្រូវពិនិត្យរករោគសញ្ញាជំងឺកាមរោគអោយច្បាស់លាស់សិន ដើម្បីផ្តល់ការព្យាបាលជំងឺកាមរោគពេញលេញ មុននឹងដាក់កងបញ្ចូលទៅក្នុងស្បូន។



# ការបង្ការជំងឺកាមរោគចំពោះមនុស្សពេញវ័យ ក្រោយពីការរំលោភផ្លូវភេទ

ការបង្ការជំងឺកាមរោគអាចត្រូវចាប់ផ្តើមនៅថ្ងៃជាមួយគ្នាដូចការបង្ការជាបន្ទាន់មិនអោយមាន ផ្ទៃពោះដែរ :

**១-ជំងឺស្វាយ:**

–**Benzathine penicillin** ២,៤លាន **IU** ចាក់សាច់ដុំតែម្តង ឬ

–**Doxycycline** ១00មក្រ លេប២ដងក្នុងមួយថ្ងៃ រយៈពេល១៤ថ្ងៃ (តែក្នុងករណីប្រតិកម្មជាមួយ penicillin)



# ការបង្ការជំងឺកាមរោគចំពោះមនុស្សពេញវ័យ ក្រោយពីការរំលោភផ្លូវភេទ

២-ជំងឺប្រមេះទឹកបាយ/**ជំងឺChancroid:**

- **Cefixime** ៤00មក្រ លេបតែម្តង **ឬ**
- **Ceftriaxone** ២៥0មក្រចាក់សាច់ដុំតែម្តង **ឬ**
- **Spectinomycin** ២ក្រ ចាក់សាច់ដុំតែម្តង

## ការបង្ការជំងឺកាមរោគចំពោះមនុស្សពេញវ័យ ក្រោយពីការរំលោភផ្លូវភេទ

៣-**ជំងឺប្រមេះទឹកថ្លា/ជំងឺហើមក្រលៀនៈ**

- **Azithromycin** ១ក្រ លេបតែម្តង **ឬ**
- **Doxycycline** ១០០មក្រ លេប២ដងក្នុងមួយថ្ងៃ រយៈពេល៧ថ្ងៃ, **ឬ**
- **Tetracycline** ៥០០មក្រ លេប៤ដងក្នុងមួយថ្ងៃ រយៈពេល៧ថ្ងៃ, **ឬ**
- **Erythromycin** ៥០០មក្រ លេប៤ដងក្នុងមួយថ្ងៃ រយៈពេល៧ថ្ងៃ

**៤-ជំងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាសៈ**

- **Metronidazole** ២ក្រ លេបតែម្តង **ឬ**
- **Tinidazolee** ២មក្រ លេបតែម្តង



## ការបង្ការជំងឺកាមរោគចំពោះកុមារក្រោយពីការរំលោភផ្លូវភេទ

**១-ជំងឺស្វាយៈ**

- **Benzathine penicillin** ៥០ ០០០ IU/គក្រ ចាក់សាច់ដុំតែម្តង **ឬ**
- **Erytromycin** ១២,៥មក្រ លេប៤ដងក្នុងមួយថ្ងៃ រយៈពេល១៤ថ្ងៃ

**២-ជំងឺប្រមេះទឹកបាយ/ជំងឺ**Chancroid**ៈ**

- **Ceftriaxone** ១២៥មក្រចាក់សាច់ដុំតែម្តង **ឬ**
- **Spectinomycin** ៤០មក្រ/គក្រ (ច្រើនបំផុត២ក្រ) ចាក់សាច់ដុំតែម្តង (.៤៥គក្រ, ប្រើពិធីការសំរាប់មនុស្សពេញវ័យ)



## ការបង្ការជំងឺកាមរោគចំពោះកុមារក្រោយពីការរំលោភផ្លូវភេទ

**៣-ជំងឺប្រមេះទឹកថ្លា/ជំងឺហើមក្រលៀន :**

- **Erythromycin** ១២,៥មក្រ/គក្រ លេប៤ដងក្នុងមួយថ្ងៃ រយៈពេល៧ថ្ងៃ( អាយុ១២ឆ្នាំឬ.១២ឆ្នាំ, ប្រើពិធីការសំរាប់មនុស្សពេញវ័យ)

**៤-ជំងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាស់ :**

- **Metronidazole** ៥មក្រ/គក្រ លេប៣ដងក្នុង១ថ្ងៃ រយៈពេល៧ថ្ងៃ ( អាយុ១២ឆ្នាំឬ.១២ឆ្នាំ, ប្រើពិធីការសំរាប់មនុស្សពេញវ័យ)



## ការបង្ការជំងឺផ្សេងៗទៀត ចំពោះមនុស្សពេញវ័យនិងកុមារ ក្រោយពីការរំលោភផ្លូវភេទ

- **ការបង្ការការឆ្លងមេរោគអេដស៍ (គោលការណ៍ណែនាំជាតិ)**
- **ការបង្ការជំងឺរលាកថ្លើមប្រភេទ បេ (ដោយចាក់វ៉ាក់សាំង)**
- **ការបង្ការជំងឺតេតាណូស**

# ម៉ូឌុលទី ៦.៤

## ការគ្រប់គ្រងព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ចំពោះអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍



## វត្ថុបំណងនៃការសិក្សា

នៅចុងបញ្ចប់នៃការសិក្សាម៉ូឌុលនេះ សិក្ខាកាមនឹងអាចៈ

១- កំណត់ពីវិធីសាស្រ្តដើម្បីរកអោយឃើញការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍

២-ពិភាក្សាពីវិធីគ្រប់គ្រងព្យាបាល ការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍



## ការរកឃើញនូវការឆ្លងមេរោគអេដស៍

- អ្នកជំងឺទាំងអស់ដែលស្វែងរកការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកាមរោគ ត្រូវធ្វើតេស្តរកការឆ្លងមេរោគអេដស៍ ។
- ការធ្វើតេស្តរកមេរោគគួរតែធ្វើជាទម្លាប់, ដោយមិនគិតថាតើអ្នកជំងឺ ត្រូវបានស្គាល់ ឬ សង្ស័យថាមានការប្រព្រឹត្តប្រឈមមុខខ្ពស់ទៅនឹងការឆ្លងមេរោគអេដស៍ ឬគ្មានទេ ។
- ដោយសារជំងឺកាមរោគជាច្រើនគ្មានរោគសញ្ញា, ការធ្វើតេស្តជាធម្មតារកជំងឺកាមរោគដែលអាចព្យាបាលជា (ឧ. ជំងឺស្វាយ, ជំងឺប្រមេះទឹកបាយ, និងជំងឺប្រមេះទឹកថ្លា) គួរតែត្រូវបានធ្វើយ៉ាងហោចណាស់មួយឆ្នាំម្តង ចំពោះអ្នកដែលមានសកម្មភាពផ្លូវភេទ (ចំពោះអ្នកប្រកបរបររកស៊ីផ្លូវភេទត្រូវធ្វើតេស្តក្នុងមួយខែម្តង) ។



## ការវាយតំលៃអ្នកជំងឺដែលមានផ្ទុកមេរោគអេដស៍លើកដំបូង

នៅក្នុងស្ថានភាពធម្មតា, ការវាយតំលៃអ្នកជំងឺដែលមានផ្ទុកមេរោគអេដស៍លើកដំបូង ជាទូទៅបញ្ចូលនៅចំនុចដូចខាងក្រោមៈ

- ប្រវត្តិជំងឺលំអិត, បញ្ចូលទាំងប្រវត្តិការរំលោភផ្លូវភេទ និងទ្រព្យសម្បត្តិ, ប្រវត្តិការចាក់វ៉ាក់សាំង, ជំងឺកាមរោគដែលមានពីមុន, និងរោគសញ្ញា ឬរោគវិនិច្ឆ័យដែលទាក់ទងទៅនឹងមេរោគអេដស៍,
- ការពិនិត្យរាងកាយ, បញ្ចូលទាំងការពិនិត្យរោគស្រ្តី ចំពោះអ្នកជំងឺស្រ្តី,
- ធ្វើតេស្តរកមេរោគប្រមេះទឹកបាយ និងមេរោគប្រមេះទឹកថ្លា (និងចំពោះស្រ្តី, ធ្វើតេស្ត Pap និងការពិនិត្យនឹងសភាពស្រស់នៃសដែលយកពី ទ្វារមាស),
- ការធ្វើតេស្តរកមេរោគស្វាយ

## ការឆ្លងរោគប្រមេះទឹកបាយ និងការឆ្លងរោគដែលមិនបង្កដោយមេរោគប្រមេះទឹកបាយ

- អ្នកជំងឺដែលមានការឆ្លងរោគប្រមេះទឹកបាយ និងជំងឺ រលាកបង្ហូរនោម មិនបង្កដោយមេរោគប្រមេះទឹកបាយ ហើយមានផ្ទុកមេរោគអេដស៍ ត្រូវព្យាបាលដូចគ្នានឹង អ្នកដែលគ្មានផ្ទុកមេរោគអេដស៍ដែរ ។
- អ្នកជំងឺដែលមានជំងឺរលាកមាត់ស្បូន ហើយមានផ្ទុកមេរោគអេដស៍ ត្រូវព្យាបាលដូចគ្នានឹងអ្នកដែលគ្មានផ្ទុកមេរោគអេដស៍ ។
- ការព្យាបាលជំងឺរលាកមាត់ស្បូនចំពោះស្ត្រីដែលផ្ទុកមេរោគអេដស៍ គឺជាការចាំបាច់ណាស់ ពីព្រោះជំងឺរលាកមាត់ស្បូន បង្កើនជំរករបស់មេរោគអេដស៍ នៅមាត់ស្បូន ។
- ការព្យាបាលជំងឺរលាកមាត់ស្បូនចំពោះស្ត្រីដែលផ្ទុកមេរោគអេដស៍បន្ថយ ការស្នាក់នៅនៃមេរោគអេដស៍នៅមាត់ស្បូន និងអាចបន្ថយការចំលង មេរោគអេដស៍ទៅដៃគូរួមភេទ ។



## Gonococcal infections






## Non-gonococcal infections






## ជំងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាស, កង់ឌីដា និងបាក់តេរីនៅនឹងទ្វារមាស

- អ្នកជំងឺដែលមានជំងឺបង្កឡើងដោយមេរោគទ្រីកូម៉ូណាស,បាក់តេរីនៅនឹង ទ្វារមាស, កង់ឌីដា ហើយមានផ្ទុកមេរោគអេដស៍ ត្រូវព្យាបាលដូចគ្នានឹងអ្នកដែលគ្មានផ្ទុកមេរោគអេដស៍ដែរ ។
- ទោះជាការព្យាបាលបង្ការជំងឺឱកាសនិយមចំពោះអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ក្នុងរយៈពេលយូរ ដោយប្រើឱសថ Fluconazole ២០០មក្រ មួយអាទិត្យម្តងមានប្រសិទ្ធភាពក្នុងការកាត់បន្ថយ ការរីកដុះដាលនៃមេរោគ កង់ឌីដាស អាល់ប៊ីកង់ និង រោគសញ្ញានៃជំងឺរលាកទ្វារមាសនិងយោនី ដោយមេរោគកង់ឌីដាសក៏ដោយ ក៏វិធីនេះមិនត្រូវបានណែនាំអោយប្រើសំរាប់ការបង្ការជាប្រចាំ ចំពោះស្ត្រីដែលមានផ្ទុកមេរោគអេដស៍ ទេ ប្រសិនបើស្ត្រីនោះគ្មានជំងឺរលាកទ្វារមាសនិងយោនី ដោយមេរោគកង់ឌីដាស ដែលកើតមានសារចុះសារឡើងនោះទេ ។



# Trichomoniasis, Candidiasis and Bacterial Vaginosis







# ជំងឺរលាកប៉ែលវីស

- តាមលទ្ធផលនៃការសិក្សាដែលផ្សព្វផ្សាយក្នុងគោលការណ៍ណែនាំស្តីពីការព្យាបាលជំងឺកាមរោគឆ្នាំ២០០២របស់អង្គការ / US-CDC បានបង្ហាញ ថាស្ត្រីដែលផ្ទុកមេរោគអេដស៍មានរោគសញ្ញាជំងឺរលាកប៉ែលវីសប្រហាក់ប្រហែលគ្នានឹងស្ត្រីដែលគ្មានផ្ទុកមេរោគអេដស៍ដែរ ។
- ការរកឃើញមេរោគចំពោះស្ត្រីដែលមានផ្ទុកមេរោគអេដស៍ និងគ្មានផ្ទុកមេរោគអេដស៍ គឺមានភាពស្រដៀងគ្នា, លើកលែងស្ត្រីដែលមានផ្ទុកមេរោគអេដស៍មានការកើតឡើងនៃអត្រាឆ្លងមេរោគ M. hominis កង់ឌីដា, ស្រ្តេបតូកូក, និងវីរុសជំងឺសិរមាន់ ខ្ពស់ជាង ហើយកោសិកាមិនធម្មតាដែលទាក់ទងទៅនឹងវីរុសជំងឺសិរមាន់ក៏មានច្រើនជាងដែរ ។



# Pelvic Inflammatory Disease (PID)






# ជំងឺស្វាយ

- -អ្នកជំងឺដែលមាន ផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ហើយមានជំងឺស្វាយដំណាក់កាលដំបូង អាចបង្កើនអោយមានផលវិបាកប៉ះពាល់ដល់សរសៃប្រសាទ ហើយអត្រា នៃការព្យាបាលបរាជ័យដោយប្រើរូបមន្តព្យាបាលថ្មីៗក៏មានច្រើនដែរបើប្រៀបធៀបជាមួយអ្នកជំងឺដែលគ្មានផ្ទុកមេរោគអេដស៍, ។
- -គ្មានរូបមន្តព្យាបាល ជំងឺស្វាយចំពោះអ្នកជំងឺផ្ទុកមេរោគអេដស/អ្នកជំងឺអេដស៍ណាមួយត្រូវបានបង្ហាញថាមានប្រសិទ្ធភាពជាងក្នុងការបង្ការមិនអោយជំងឺស្វាយប៉ះពាល់ដល់សរសៃប្រសាទ ជាងរូបមន្តព្យាបាលជំងឺស្វាយដែលប្រើសំរាប់អ្នកជំងឺដែលគ្មានផ្ទុកមេរោគអេដស៍នោះទេ ។ ការពិនិត្យតាមដានដោយយកចិត្តទុកដាក់បន្ទាប់ពីការព្យាបាលមានសារៈសំខាន់ណាស់ ។
- -ការព្យាបាលដោយប្រើ benzathine penicillin G ២,៤លាន IU ចាក់សាច់ដុំតែម្តងគត់ត្រូវបានណែនាំអោយប្រើ ចំពោះជំងឺស្វាយដំណាក់កាលដំបូង ។

# Primary syphilis







# Secondary syphilis







# ជំងឺ Chancroid

- ត្រូវពិនិត្យតាមដានការព្យាបាលអោយហ្មត់ចត់ ចំពោះអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ដែលមានជំងឺ Chancroid ពីព្រោះអ្នកជំងឺទាំងនោះអាចមានដំបៅដែលជាយ៉ាងយឺត១ ហើយជួនកាលអាចជួបបរាជ័យក្នុងការព្យាបាលច្រើនជាងដែលគ្មានផ្ទុកមេរោគអេដស៍ ។
- អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍អាចត្រូវប្រើរយៈពេលព្យាបាលដោយប្រើឱសថ យូរជាង រយៈពេលដែលប្រើឱសថសំរាប់អ្នកដែលគ្មានផ្ទុកមេរោគអេដស៍ ហើយបរាជ័យនៃការព្យាបាលនេះ អាចកើតឡើងដោយការប្រើរូបមន្តព្យាបាលមួយចំនួន។ អ្នកឯកទេសមួយចំនួនចូលចិត្តប្រើរូបមន្ត ព្យាបាលដោយប្រើឱសថ Erythromycin រយៈពេល៧ថ្ងៃ សំរាប់ព្យាបាលអ្នកដែលមានផ្ទុកមេរោគ អេដស៍។



# ការឆ្លងវីរុសបង្កអោយមានជំងឺពងបែកលើប្រដាប់បន្តពូជ

- អ្នកជំងឺដែលមានភាពស៊ាំចុះខ្សោយអាចមានការកើតមានជំងឺពងបែកលើ ប្រដាប់បន្តពូជ ជុំវិញរន្ធគូថ ឬនៅមាត់ ដែលអាចមានរយៈពេលយូរ ឬធ្ងន់ធ្ងរ។ ដំបៅដែលបង្កឡើងដោយវីរុសដែលបង្កអោយមានជំងឺពងបែកលើប្រដាប់បន្តពូជ ច្រើនជួបញឹកញាប់ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ /អ្នកជំងឺអេដស៍ ហើយអាចមានសភាពធ្ងន់ធ្ងរ, ឈឺចាប់ខ្លាំង, និងមានលក្ខណៈមិនច្បាស់លាស់។ ការលេចចេញជារោគសញ្ញា ចំពោះវីរុស បង្កអោយមានពងបែកលើប្រដាប់បន្តពូជ ចំពោះអ្នកដែលផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ ត្រូវបានសង្កេតឃើញកើតមានច្រើនជាងអ្នកដែលគ្មានផ្ទុក មេរោគអេសដ៏។
- អ្នកដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ងាយឆ្លងវីរុសបង្កអោយមានជំងឺពងបែកលើប្រដាប់បន្តពូជច្រើនជាងអ្នកដែល គ្មានផ្ទុកមេរោគអេសដ៏។
- រូបមន្តព្យាបាល ប្រចាំថ្ងៃ សំរាប់ការព្យាបាលបង្ការការកើតជំងឺពងបែកលើប្រដាប់បន្តពូជ ចំពោះអ្នកផ្ទុកមេរោគអេដស៍ /អ្នកជំងឺអេដស៍គឺ : **Acyclovir** ៤០០-៨០០មក្រ លេប២ទៅ៣ដងក្នុងមួយថ្ងៃ។

# ជំងឺសិរមាន់

- ពុំមានមធ្យោបាយពិសេសណាមួយសំរាប់ព្យាបាលជំងឺសិរមាន់ ដែលកើតនៅលើប្រដាប់បន្តពូជចំពោះអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ទេ ។
- ទោះជាយ៉ាងណាក៏ដោយ, អ្នកដែលមានភាពស៊ាំចុះខ្សោយ ដោយសារមេរោគអេដស៍ ឬក៏ដោយសារហេតុផលដ៏ទៃទៀត អាចមានដុះសិរមាន់ ធំជាង ឬច្រើនជាងអ្នកដែលគ្មានផ្ទុកមេរោគអេដស៍ ឬអាចមិនឆ្លើយតបទៅនឹងការព្យាបាលជំងឺសិរមាន់នៅលើប្រដាប់បន្តពូជ និងអាចមានការកើតជំងឺសិរមាន់នេះឡើងវិញជាញឹកញាប់ក្រោយពីការព្យាបាល ។



# ហើមក្រលៀន (LGV)

- អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍ដែលមានការឆ្លងរោគហើមក្រលៀន ត្រូវទទួលការព្យាបាលជំងឺនេះតាមរូបមន្តដូចគ្នាទៅនឹងអ្នកដែលគ្មានផ្ទុកមេរោគអេដស៍ដែរ ។
- អ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍អាចត្រូវការព្យាបាលបន្ថែមរយៈពេលយូរ ហើយការបាត់រោគសញ្ញាទៅវិញអាចពន្យាពេលយូរជាងធម្មតា ។

# ម៉ូឌុលទី ៧

## ការពិនិត្យតាមដាន និងការអភិបាល សេវាបង្ការ និងថែទាំព្យាបាល ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ



# វត្ថុបំណងនៃការសិក្សា

**នៅចុងបញ្ចប់នៃការសិក្សាម៉ូឌុលនេះ សិក្ខាកាមនឹងអាចៈ**

១- ពិពិណនាពីវត្ថុបំណងសំខាន់ៗនៃ ការពិនិត្យតាមដាន និងការអភិបាល សេវាបង្ការ និងថែទាំព្យាបាល ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ

២- ពិពិណនាពីវត្ថុបំណងជាក់លាក់នៃ ការពិនិត្យតាមដាន និងការអភិបាល

៣-កំណត់ពីវិធីសាស្ត្រនៃ ការពិនិត្យតាមដាន និងការអភិបាល

៤- អនុវត្តដំណើរការពិនិត្យតាមដាន និងការអភិបាល

៥- ប្រើប្រាស់បញ្ជីរផ្ទៀងផ្ទាត់ក្នុងការពិនិត្យតាមដាន និងការអភិបាល

៦- ប្រើប្រាស់បញ្ជីររបាយការណ៍ករណីជំងឺកាមរោគប្រចាំត្រីមាស



# សេចក្តីផ្តើម (១)

- នៅប្រទេសកម្ពុជា ការបង្ការ និងថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ជាសមាសភាពដ៏សំខាន់មួយនៃសកម្មភាពសុខភាពសាធារណៈ ជាពិសេស ចំពោះក្រុមប្រជាជនដែលប្រឈមមុខខ្ពស់ដូចជា ស្រ្តីរកស៊ីផ្លូវភេទ។
- បរាជ័យក្នុងការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺកាមរោគ នៅដំណាក់ការដំបូងអាចបង្ក អោយមានផលវិបាកធ្ងន់ធ្ងរ ដូចជា ភាពអារគ្មានកូន , កូនក្រៅស្បូន, មហារីកមាត់ស្បូន និងកូនស្លាប់ ជាដើម។
- ការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ អាចបង្កើនគ្រោះថ្នាក់នៃការឆ្លង ឬការចំលងមេរោគអេដស៏យ៉ាងខ្លាំងក្លា។



# សេចក្តីផ្តើម (២)

- ឆ្លើយតបទៅនឹងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជនៅក្នុងសង្គម មជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៏ សើស្បែក និងកាមរោគបានអនុវត្តនូវយុទ្ធសាស្ត្រនានា ដើម្បីធ្វើអោយកាន់តែប្រសើរនូវគុណភាពនៃសេវាថែទាំព្យាបាល នេះដោយសហការជាមួយ អង្គការមិនមែន រដ្ឋាភិបាលផ្សេងៗ ដែលផ្តោតយ៉ាងសំខាន់ទៅលើក្រុមដែលប្រឈមមុខខ្ពស់។
- មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៏ សើស្បែក និងកាមរោគផ្តល់សេវាថែទាំព្យាបាលការបង្ករោគ តាមការរួមភេទ និងប្រដាប់បន្តពូជតាមបណ្តាគ្លីនិកសុខភាពគ្រួសារខេត្ត-ក្រុងចំនួន៣២ សំរាប់ក្រុម ប្រជាជនដែលប្រឈមមុខ ខ្ពស់ដូចជាស្រ្តីរកស៊ីផ្លូវភេទដោយផ្ទាល់ ស្រ្តីរកស៊ីផ្លូវភេទដោយប្រយោល និងអតិថិជន របស់ពួកគេ ដោយសហការជាមួយនឹងគ្លីនិកចំនួន ២១ ទៀតរបស់អង្គការមិនមែន រដ្ឋាភិបាល។

# វត្ថុបំណងសំខាន់ៗ

## (Main objectives)

**វត្ថុបំណងសំខាន់ៗនៃការពិនិត្យតាមដាន និងអភិបាល លើសកម្មភាពបង្ការ និង ថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នៅតាមគ្លីនិក សុខភាពគ្រួសារតី ដើម្បីៈ**

- **ពិនិត្យតាមដានគុណភាពនៃការផ្តល់សេវាថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ នាពេលថ្មីៗ**
- **កំណត់ពីបញ្ហានានា ក្នុងការផ្តល់សេវាថែទាំព្យាបាលការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជ ដែលប្រកបដោយគុណភាព**
- **ធ្វើអោយប្រសើរនូវសមត្ថភាពនៃអ្នកផ្តល់សេវាថែទាំ ដែលបំរើការនៅគ្លីនិកសុខភាពគ្រួសារ តាមរយៈការណែនាំនិងបង្ហាត់បង្ហាញនៅនឹងកន្លែង ក្នុងពេលចុះអភិបាល ។**



# គោលដៅពិសេស

## (Specific objectives)

- ការធ្វើអោយប្រសើរនូវគុណភាពនៃការធ្វើរោគវិនិច្ឆ័យ និងការថែទាំព្យាបាលជំងឺកាមរោគ
- ការពិនិត្យនូវគុណភាព និងការផ្គត់ផ្គង់ឪសថអោយគ្រប់គ្រាន់សំរាប់ព្យាបាល ជំងឺកាមរោគ រួមទាំងប្រតិករសំរាប់ការធ្វើតេស្តមន្ទីរពិសោធន៏ផង
- ការពិនិត្យនូវគុណភាពនៃការរក្សាទុកដាក់សំណុំឯកសាររបស់អ្នកជំងឺ និងរបាយការណ៏នានា ដែលទាក់ទងទៅនឹង គ្លីនិកកាមរោគ
- ការធានាបាននូវសេវាបង្ការនិងថែទាំជំងឺកាមរោគដែលប្រកបដោយគុណភាពតាមរយៈមន្ត្រីជំនាញ ក្នុងការពិនិត្យនិងព្យាបាលជំងឺ និងការពង្រីកការគ្របដណ្តប់របស់សេវានេះទៅដល់ក្រុមគោលដៅ ។



# វិធីសាស្រ្ត (១)

## (Methodology)

- ក្រុមអភិបាលមានផ្នែកគ្រប់គ្រងព្យាបាលការបង្ករោគតាមការរួមភេទនិងប្រដាប់បន្តពូជ និងគ្លីនិកជាតិសើស្បែក និងកាមរោគ ដើម្បីចុះពិនិត្យតាមដាន និងអភិបាលការងារ ចំនួនពីរដងក្នុងមួយឆ្នាំ ។
- ត្រួតពិនិត្យគុណភាពសេវា, របាយការណ៏គ្លីនិក, និងជួបសំភាសបុគ្គលិកគ្លីនិក និងអតិថិជន (បើចាំបាច់) ។
- ការពិនិត្យតាមដាននិងការអភិបាលការងារ ត្រូវប្រកាន់នូវគោលការណ៏សំរបសំរួលនិងលើកទឹកចិត្ត ដើម្បីធ្វើការកែសំរួលនិងធ្វើអោយប្រសើរនូវគុណភាពនៃសេវាថែទាំព្យាបាល ។ ក្រុមអភិបាលមិនត្រូវរិះគន់ ឬស្តីបន្ទោសអ្នកផ្តល់សេវាទេ ទោះបីក្នុងករណីណាក៏ដោយ ។
- បញ្ជីផ្ទៀងផ្ទាត់ (Checklist) សំរាប់ការពិនិត្យ តាមដាននិងអភិបាល ត្រូវបានប្រើប្រាស់ជាសំភារៈសំខាន់ សំរាប់ក្រុមអភិបាល ។



# វិធីសាស្រ្ត (២)

## (Methodology)

- វាយតំលៃគុណភាពនិងសមត្ថភាពរបស់បុគ្គលិកគ្លីនិក តាមរយៈការសង្កេតកិច្ចការរបស់បុគ្គលិក
- ធ្វើការប្រជុំ ដោយអោយបុគ្គលិកគ្លីនិកធ្វើការវាយតំលៃខ្លួនឯង និង បន្តពិភាក្សាមួយអ្នកគ្រប់គ្រង និងបុគ្គលិកគ្លីនិក ដើម្បីស្តាប់ការបញ្ចេញយោបល់របស់ពួកគេ ។
- ការប្រជុំគឺជាឱកាសមួយដើម្បីៈ
  - លើកឡើងនូវសមិទ្ធផល
  - ស្វែងរកដំណោះស្រាយដើម្បីដោះស្រាយបញ្ហា និងការលំបាកដែលបានជួបប្រទះ
  - កំណត់តំរូវការបណ្តុះបណ្តាល

# ដំណើរការនៃការពិនិត្យតាមដាននិងការអភិបាល

## (Process of monitoring and supervision)

**<u>ការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ក្នុងពេលចុះអភិបាល  ដើម្បី :</u>**

— សំភាសន៍អ្នកទទួលបន្ទុកពិនិត្យជំងឺផ្ទាល់ និងសមាជិកក្រុមថែទាំព្យាបាលជំងឺ

— សង្កេតការពិគ្រោះជំងឺ, ការពិនិត្យ, ការព្យាបាលនិង សកម្មភាពផ្តល់ប្រឹក្សា

— ពិនិត្យឧបករណ៍ប្រើប្រាស់និងចំនួនឧបករណ៍នៅមាន

— សង្កេតការយកសារធាតុសរីរៈទៅពិនិត្យនៅមន្ទីរពិសោធន៍, នីតិវិធី (procedure) , លទ្ធផលតេស្ត និងការបកស្រាយលទ្ធផល

— ពិនិត្យ ឯកសារនៃការពិនិត្យជំងឺ និងឯកសារមន្ទីរពិសោធន៍ របស់អ្នកជំងឺ ។



# បញ្ជីផ្ទៀងផ្ទាត់សំរាប់ការពិនិត្យតាមដាន  និងការអភិបាល

## (Monitoring and Supervision Checklist)

**<u>A-ផ្នែកទី១ ( ការគ្រប់គ្រង)</u>**

១- ការទទួលសេវា

២- បុគ្គលិក

៣- អាគារ/បន្ទប់

៤- ការបង្ការការចំលងរោគ

៥- សំភារៈសំរាប់អប់រំ និងស្រោមអនាម័យ

៦- ការរក្សាទុកឯកសារ និងឯកសារដែលប្រើប្រាស់សំរាប់បង្ហាញភស្តុតាង

៧- ពិនិត្យសៀវភៅចុះឈ្មោះរបស់អ្នកជំងឺ និងកត់ត្រាតួលេខនៃត្រីមាសចុងក្រោយបង្អស់

៨- កត់ត្រាចំនួននៃករណីការបង្ករោគតាមការរួមភេទ និងប្រដាប់បន្តពូជដែលបានធ្វើរោគវិនិច្ឆ័យ នៅក្នុងត្រីមាសចុងក្រោយបង្អស់



# បញ្ជីផ្ទៀងផ្ទាត់សំរាប់ការពិនិត្យតាមដាន  និងការអភិបាល

## (Monitoring and Supervision Checklist)

**<u>ខ-ផ្នែកទី ២ ( គ្លីនិក)</u>**

១-ការស្រង់ប្រវត្តិជំងឺ

២-ការពិនិត្យអ្នកជំងឺ

៣-ការធ្វើរោគវិនិច្ឆ័យជំងឺ

៤-ការព្យាបាលជំងឺ

៥-ការវាយតំលៃការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺ

៦-ការអញ្ជើញដៃគូរួមភេទអោយមកទទួលការព្យាបាល/ការតាមដាន



# បញ្ជីផ្ទៀងផ្ទាត់សំរាប់ការពិនិត្យតាមដាន  និងការអភិបាល

## (Monitoring and Supervision Checklist)

**<u>គ-ផ្នែកទី៣( មន្ទីរពិសោធន៍)</u>**

១-ការបង្ការការចំលងរោគជាសកល

២-ដំនើរការនៃមន្ទីរពិសោធន៍ និងការធ្វើតេស្ត

៣-កត់ត្រាចំនួនករណីនៃការធ្វើតេស្តមន្ទីរពិសោធន៍នៅក្នុងត្រីមាសចុងក្រោយបង្អស់

**<u>ឃ-ដំណោះស្រាយបញ្ហា និងអនុសាសន៍</u>**

-បញ្ហាគ្រប់គ្រង

-បញ្ហាគ្លីនិក

-បញ្ហាមន្ទីរពិសោធន៍

## តារាងសង្ខេបសំរាប់វាយតំលៃពិន្ទុផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដោយពឹងផ្អែកលើគុណភាពនៃលទ្ធផលការងារ (PBSI)

( ទាក់ទងទៅនឹងការវាយតំលៃទំរង់ *P2:STI* )

| | គុណភាពនៃការគ្រប់គ្រងថែទាំនិងព្យាបាល ជំងឺបង្កតាមការរួមភេទ និងប្រដាប់បន្តពូជ | ចាស/បាទ/ ធ្វើបានល្អ ត្រឹមត្រូវ | ទេ/ធ្វើមិនសូវ បានល្អ ប៉ុន្តែអាច ទទួលយកបាន | ទេ/ មិនធ្វើសោះ | ផ្សេងៗ |
|---|---|---|---|---|---|
| | | ពិន្ទុ ២ | ពិន្ទុ ១ | ពិន្ទុ ០ | |
| ១ | បុគ្គលិកកំពុងបំរើការមានចំនួនគ្រប់គ្រាន់ | | | | |
| ២ | បុគ្គលិកកំពុងបំរើការមានសមត្ថភាពសមរម្យ សំរាប់មុខងារបច្ចុប្បន្នរបស់ពួកគេ | | | | |
| ៣ | បុគ្គលិកដែលកំពុងបំរើការបានទទួលការបណ្តុះបណ្តាល ត្រឹមត្រូវសំរាប់មុខងារបច្ចុប្បន្នរបស់ពួកគេ | | | | |
| ៤ | ស្ថានភាពទូទៅនៃគ្លីនិកមានភាពសមរម្យ (ភាពស្ងាត់កំបាំង, ភាពស្អាត/អនាម័យ) | | | | |
| ៥ | ផ្តល់ការថែទាំព្យាបាលជម្ងឺទៅតាមគោលការណ៏ណែនាំស្តង់ដាររបស់ជាតិ (National Guidelines) | | | | |
| ៦ | អនុវត្តតាមគោលការណ៏ណែនាំស្តង់ដារ (SOP) របស់មជ្ឈមណ្ឌលជាតិ | | | | |
| ៧ | ពេលម៉ោងធ្វើការផ្តល់សេវាអាចទទួលយកបាន សំរាប់ក្រុមប្រជាជនគោលដៅ (Target groups) | | | | |
| ៨ | ពិនិត្យស្រាវជ្រាវជាទៀងទាត់រកមើលជំងឺកាមរោគ ដល់គ្រប់ស្ត្រីរកស៊ីផ្លូវភេទដែលគ្មានរោគសញ្ញា | | | | |



## តារាងសង្ខេបសំរាប់វាយតំលៃពិន្ទុផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដោយពឹងផ្អែកលើគុណភាពនៃលទ្ធផលការងារ (PBSI)

( ទាក់ទងទៅនឹងការវាយតំលៃទំរង់ *P2:STI* )

| | គុណភាពនៃការគ្រប់គ្រងថែទាំនិងព្យាបាល ជំងឺបង្កតាមការរួមភេទ និងប្រដាប់បន្តពូជ | ចាស/បាទ/ ធ្វើបានល្អ ត្រឹមត្រូវ | ទេ/ធ្វើមិនសូវ បានល្អ ប៉ុន្តែអាច ទទួលយកបាន | ទេ/ មិនធ្វើសោះ | ផ្សេងៗ |
|---|---|---|---|---|---|
| | | ពិន្ទុ ២ | ពិន្ទុ ១ | ពិន្ទុ ០ | |
| ៩ | ឱសថកាមរោគសំខាន់ៗជាសារវ័ន្ត អាចរកបាន និងបានស្នើសុំទាន់ពេលវេលា | | | | |
| ១០ | ឧបករណ៏/សំភារៈសំរាប់ប្រើប្រាស់នៅគ្លីនិកស្ថិតក្នុង ស្ថានភាពល្អប្រសើរ | | | | |
| ១១ | ឧបករណ៏/សំភារៈសំរាប់ប្រើប្រាស់នៅមន្ទីរពិសោធន៍ ស្ថិតក្នុងស្ថានភាពល្អប្រសើរ | | | | |
| ១២ | ធ្វើតេស្ត Gram stain/Methylene blue ចំពោះ ស ស្រង់ពីមាត់ស្បូន | | | | |
| ១៣ | ធ្វើតេស្ត Gram stain ចំពោះ ស ស្រង់ពីទ្វារមាស | | | | |
| ១៤ | ធ្វើតេស្ត ដោយការពិនិត្យ ស ភ្លាមៗ | | | | |
| ១៥ | ធ្វើតេស្ត ដោយប្រើ KOH | | | | |
| ១៦ | ធ្វើតេស្ត RPR | | | | |
| ១៧ | ផ្តល់ការអប់រំ និងផ្តល់ប្រឹក្សាដល់អ្នកជំងឺ | | | | |
| ១៨ | ផ្តល់គំនិតផ្តួចផ្តើម ដល់អ្នកជំងឺ ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍ | | | | |
| **ពិន្ទុសរុប........./៣៦** | | .............ភាគរយ | | | |



## របាយការណ៍ប្រចាំត្រីមាសសំរាប់គ្លីនិកសុខភាពគ្រួសារ

**ប្រចាំខែ ............................................ ត្រីមាសទី .................................... ឆ្នាំ ២០០....**

**ឈ្មោះគ្លីនិក............................ ស្រុកប្រតិបត្តិ .......................... ខេត្ត-ក្រុង............................**

| | | ខែទី ១ | ខែទី ២ | ខែទី ៣ |
|---|---|---|---|---|
| ចំនួនសរុបនៃការពិនិត្យអ្នកជំងឺបុរស | ចំនួនបុរស សរុបទាំងអស់ | | | |
| | *ចំនួន MSM* | | | |
| ចំនួនសរុបនៃការពិនិត្យអ្នកជំងឺស្ត្រី ដែលមការប្រឈមមុខទាប | | | | |
| ចំនួនសរុបនៃការពិនិត្យលើកដំបូង សំរាប់ស្ត្រីបំរើសេវាកំសាន្ត (EW) | | | | |
| ចំនួនសរុបនៃការពិនិត្យតាមដានបន្ត សំរាប់ស្ត្រីបំរើសេវាកំសាន្ត (EW) | | | | |
| ចំនួនសរុបនៃការពិនិត្យលើកដំបូង សំរាប់ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ (ផ្ទះបន) | | | | |
| ចំនួនសរុបនៃការពិនិត្យតាមដានបន្ត សំរាប់ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ (ផ្ទះបន) | | | | |
| **ចំនួនសរុបនៃស្ត្រីបំរើសេវាកំសាន្ត (EW) ដែលបញ្ជូនមកដោយបណ្តាញស្ត្រីបំរើសេវាកំសាន្ត (EW networks)** | | | | |
| **ចំនួនសរុបនៃស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ (ផ្ទះបន) ដែលបញ្ជូនមកដោយបណ្តាញស្ត្រីបំរើសេវាកំសាន្ត (EW networks)** | | | | |



| | ខែទី ១ | ខែទី ២ | ខែទី ៣ |
|---|---|---|---|
| ចំនួនសរុបនៃការបញ្ជូនអតិថិជនគ្លីនិកសុខភាពគ្រួសារទៅធ្វើតេស្តឈាមរកមេរោគអេដស៍នៅ VCCT | | | |
| ចំនួនសរុបនៃការបញ្ជូនអតិថិជនគ្លីនិកសុខភាពគ្រួសារទៅទទួលសេវាពិនិត្យផ្ទៃពោះ (ANC) (ចំពោះស្ត្រីមានផ្ទៃពោះ) | | | |
| ចំនួនសរុបនៃការបញ្ជូនអតិថិជនគ្លីនិកសុខភាពគ្រួសារទៅទទួលសេវាពន្យារកំណើត (Family Planning) | | | |

| | ខែទី ១ | ខែទី ២ | ខែទី ៣ |
|---|---|---|---|
| ចំនួនសរុបនៃអតិថិជនដែលបញ្ជូនពីសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ VCCT មកគ្លីនិកសុខភាពគ្រួសារ | | | |
| ចំនួនសរុបនៃអតិថិជនដែលបញ្ជូនពីសេវាពិនិត្យផ្ទៃពោះ (ANC) (ចំពោះស្ត្រីមានផ្ទៃពោះ) មកគ្លីនិកសុខភាពគ្រួសារ | | | |
| ចំនួនសរុបនៃអតិថិជនដែលបញ្ជូនពីសេវាពន្យារកំណើត (Family Planning) មកគ្លីនិកសុខភាពគ្រួសារ | | | |

*កំណត់ចំណាំ :*

- *MSM : បុរសរួមភេទជាមួយបុរស*
- *VCCT : មណ្ឌលផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់*
- *EW (Entertainment Worker) : រួមមានស្ត្រីបំរើសេវាកំសាន្តនៅតាមកន្លែង Karoke, Massage parlor, Beer garden, ស្ត្រីបំរើស្រាបៀរ, ស្ត្រីរកភ្ញៀវនៅតាមសួនច្បារសាធារណៈ ។ល ។*

| បុរស ( ករណីថ្មី) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | អាយុ | | | | | | សរុប | |
| | | <15 | | 15-49 | | ≥ 50 | | | |
| | ចង្កោមរោគសញ្ញា | សរុប | MSM | សរុប | MSM | សរុប | MSM | សរុប | MSM |
| | ការហូរខ្ទុះតាមបង្ហួរនោម | | | | | | | | |
| | ការហូរខ្ទុះតាមគូថ | | | | | | | | |
| | ដំបៅលើប្រដាប់បន្តពូជ/គូថ | | | | | | | | |
| | សិរម៉លើប្រដាប់បន្តពូជ/គូថ | | | | | | | | |
| | ហើមពងស្វាស (Scrotum Swelling) | | | | | | | | |
| | ហើមក្រលៀន (LGV) | | | | | | | | |
| | សរុបករណីថ្មីនៃអ្នកជំងឺបុរស | | | | | | | | |



| ស្ត្រីដែលមការប្រឈមមុខទាប ( ករណីថ្មី) | | | | | |
|---|---|---|---|---|---|
| | | អាយុ | | | សរុប |
| | ចង្កោមរោគសញ្ញា | <15 | 15-49 | ≥ 50 | |
| | ការធ្លាក់ ស/ហូរខ្ទុះតាមទ្វារមាស | | | | |
| | - *រលាកទ្វារមាស* | | | | |
| | - *រលាកមាត់ស្បូន* | | | | |
| | - *រលាកទ្វារមាស + រលាកមាត់ស្បូន* | | | | |
| | រលាកប៉ែលវីស (PID) | | | | |
| | ដំបៅលើប្រដាប់បន្តពូជ/គូថ | | | | |
| | សិរម៉ លើប្រដាប់បន្តពូជ/គូថ | | | | |
| | សរុបករណីថ្មី | | | | |



| ស្ត្រីដែលមានការប្រឈមមុខខ្ពស់ ( ករណីថ្មី ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | <15 | | 15-49 | | > 50 | | Total | |
| | | DSW | EW | DSW | EW | DSW | EW | DSW | EW |
| **មកពិនិត្យលើកដំបូង** | ការធ្លាក់ ស/ហូរខ្ទុះតាមទ§ារមាស | | | | | | | | |
| | - *រលាកទ្វារមាស* | | | | | | | | |
| | - *រលាកមាត់ស្បូន* | | | | | | | | |
| | - *រលាកទ្វារមាស + រលាកមាត់ស្បូន* | | | | | | | | |
| | រលាកប៉ែលវីស (PID) | | | | | | | | |
| | ដំបៅលើប្រដាប់បន្តពូជ | | | | | | | | |
| | សិរមាន់ | | | | | | | | |
| | ស្វាយ ( តេស្ត RPR វិជ្ជមាន) | | | | | | | | |
| | ***សរុបករណីថ្មី មកពិនិត្យលើកដំបូង*** | | | | | | | | |
| **មកពិនិត្យតាមដានបន្ត** | ការធ្លាក់ ស/ហូរខ្ទុះតាមទ§ារមាស | | | | | | | | |
| | - *រលាកទ្វារមាស* | | | | | | | | |
| | - *រលាកមាត់ស្បូន* | | | | | | | | |
| | - *រលាកទ្វារមាស + រលាកមាត់ស្បូន* | | | | | | | | |
| | រលាកប៉ែលវីស (PID) | | | | | | | | |
| | ដំបៅលើប្រដាប់បន្តពូជ | | | | | | | | |
| | សិរមាន់ | | | | | | | | |
| | ***សរុបករណីថ្មី មកពិនិត្យតាមដានបន្ត*** | | | | | | | | |



| | | |
|---|---|---|
| **ថ្ងៃ.ខែ.ឆ្នាំ ធ្វើរបាយការណ៍** | **................../................./ ២០០....** | |
| **ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយកាណ៍** | | |
| **ឈ្មោះ និងហត្ថលេខាប្រធានគ្លីនិក** | | |

***កំណត់ចំណាំ :***

*DSW : Direct Sex Workerr : ស្ត្រីរកស៊ីផ្លូវភេទដោយផ្ទាល់ ( តាមផ្ទះបន)*

*EW: Entertainment Worker : រួមមានស្ត្រីបំរើសេវាកំសាន្តនៅតាមកន្លែង Karoke, Massage parlor, Beer garden, ស្ត្រីបំរើស្រាបៀរ,*

*ស្ត្រីរកភ្ញៀវនៅតាមសួនច្បារសាធារណ: ។ល ។*

*PID : Pelvic Inflammatory Disease ( ជម្ងឺរលាកប៉ែលវីស)*

បោះពុម្ពដោយថវិកា